ស.ប.ស.ខ

សមាគមបុគ្គលិកសិក្សាខ្មែរ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

* ចំណងមិត្តភាពនិងការឧបត្ថម្ភគ្នាទៅវិញទៅមក
* ការពង្រឹងនិងពង្រីកចំណេះដឹង និង វិជ្ជាជីវៈ
* ការការពារផលប្រយោជន៍គ្នាទាំងផ្លូវចិត្ត - សម្ភារៈ

៤៥

# ទស្សនាវដ្តី គ្រូបង្រៀន



**ផ្ទះគ្រូបង្រៀនខេត្តបាត់ដំបង**

**ត្រីមាសទី៤ ឆ្នាំ ២០១៤**

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ
១២៨B មហាវិថីព្រះនរោត្តម (ភ្នំពេញ)
ទូរស័ព្ទ : ០២៣ ២១៦ ១៨៤-០១២ ៦៣៨ ៨៨៩
អ៊ីម៉ែល : kta.amcek@gmail.com

# មាតិកា


| ល.រ | ចំណងជើងអត្ថបទ | ទំព័រ |
|---|---|---|
| ១ | វិចារណកថា (ការអប់រំសម្រាប់សតវត្សទី XXI) | ១ |
| ២ | អភិវន្ទន៍អបអរសាទរ « ទិវាគ្រូបង្រៀន ៥ តុលា | ២ |
| | **រាជកិច្ច** | |
| ២ | ច្បាប់ស្តីពីការអប់រំ (ត) | ៤ |
| | **វប្បធម៌ទូទៅ** | |
| ៣ | ពាក្យគន្លឹះក្នុងការងារផែនការអប់រំ) | ៦ |
| ៤ | ប្រភពនៃការអប់រំក្នុងពិភពលោក (ត) | ៩ |
| ៥ | អត្ថន័យនៃការសិក្សា | ១១ |
| | **ចិត្តវិទ្យាអប់រំ** | |
| ៦ | សម្បទា និង សម្បទាគរុកោសល្យរបស់គ្រូបង្រៀន(តចប់) | ១៣ |
| ៧ | មាតាបិតាពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុក តែជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា (ត) | ១៥ |
| | **ការអប់រំ និង គរុកោសល្យ** | |
| ៨ | អភិវឌ្ឍរបៀបធ្វើការជាក្រុម | ១៧ |
| ៩ | វេយ្យាករណ៍: របៀបប្រើពាក្យ (ត) | ១៩ |
| ១០ | សាលាធនធានជួយបង្កើនគុណភាពអប់រំនៅកម្ពុជា | ២០ |
| ១១ | គណិតវិទ្យា: រកឃើញចំណោទដែលទាក់ទងនឹងប្រមាណវិធី | ២២ |
| | **កំណាព្យ និង កំសាន្ត** | |
| ១២ | រមណីយដ្ឋានឆ្នេរកែប ( បទពាក្យប្រាំពីរ) | ២៦ |
| ១៣ | វិធីអាន( បទពាក្យ ប្រាំពីរ) (តចប់) | ២៨ |
| ១៤ | កតញ្ញូតាធម៌ ( បទកាកគតិ) | ៣០ |
| | **វេទិកាស្វែរិន** | |
| ១៥ | ពុទ្ធសាសនានៅប្រទេសកម្ពុជា | ៣១ |
| ១៦ | វេទិកាស្ត្រី: សាលារៀនគឺជាគ្រឹះស្ថានសង្គមមួយ | ៣៣ |
| | **ព័ត៌មាន** | |
| ១៧ | អំពីរបាប់ថ្ងៃ ខែ ឆ្នាំ ចន្ទគតិ និង សុរិយគតិ | ៣៦ |
| ១៨ | ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១២ (ត) | ៣៧ |
| ១៩ | ស្ថិតិសពខែ កញ្ញា - ធ្នូ ឆ្នាំ ២០១៣ | ៤០ |



## គណៈកម្មការរៀបរៀង និង និពន្ធ

- លោក ជ័យ សយ្យនា
- លោក ថោង ប៊ូរ៉ាន់
- លោកស្រី គុយ ផល្លា
- លោកស្រី ប្រាក់ សូលីដា
- លោក ជន ឈាងលី
- លោក ស្វាយ និត្យ
- លោកស្រី អ៊ឹម ប៊ុណ្ណារី
- លោក ព្រុំ សាមិត
- លោកស្រី ចាប់ នីសារ៉ៃ
- លោក អ៊ុំ ដា
- សមាជិកសមាជិកា ស. ប. ស.ខ

## គណៈកម្មការត្រួតពិនិត្យ

- លោក យស់ អ៊ាង
- លោកស្រី ទន់ សាអ៊ឹម
- លោក អ៊ិន ថេរ
- លោក រ័ត្ន ឃួត
- លោក សួង សារុណា
- លោក ស៊ុង វ៉ាន់ថន
- លោក ស៊ិន ស៊ឹម

## ការិកុំព្យូទ័រ

កញ្ញា មឿង ចាន់ផល្លី

## ក្របខាងក្រៅ

- ពីមុខ : សាលាបឋមសិក្សាអ៊ីរ៉ូហា ខេត្តបកណ្តាល
- ពីក្រោយ : ទស្សនាវដ្តីសម្រាប់គ្រូបង្រៀនលេខ ១ ឆ្នាំ ទី ១


## ទូរស័ព្ទផ្ទះគ្រូបង្រៀន

**ភ្នំពេញ** : ០៨៩ ៦៨៤ ០៨១
**ព្រះសីហនុ** : ០១២ ៦៥៩ ៥៦០
**សៀមរាប** : ០១២ ៦៧៥ ៦៤០
**កំពង់ចាម** : ០១១ ៧៤២ ២២៤
**ស្វាយរៀង** : ០៩៧ ២ ៦៥៥ ៩៨៧
**ព្រៃវែង** : ០១២ ៦៧១ ៦៤០
**កំពត** : ០១២ ៨៥៦ ៧២២
**កែប** : ០៩៧ ៨ ៧២១ ៨៨០
**តាកែវ** : ០៩៧ ៩ ៧៦១ ៥៨៨
**រតនគិរី** : ០៩៧ ៩ ០៤២ ៥៨៤
**ព្រះវិហារ** : ០១២ ២១៨ ២៨១

# វិចារណកថា

## ការអប់រំសម្រាប់សតវត្សទី XXI

ការកសាងមនុស្សគ្រប់វ័យដើម្បីឱ្យពួកគេមានអនាគត និងផលិតភាព គឺជាកាតព្វកិច្ចរបស់អង្គការយូណេស្កូ(UNESCO)ផ្នែកការអប់រំ ។ យើងដឹងថាកាលបរិច្ឆេទចុងក្រោយនៃគោលដៅអភិវឌ្ឍសហសវត្សរ៍ ជាពិសេស «ការអប់រំសម្រាប់ទាំងអស់គ្នា» គឺនៅដំណាច់ឆ្នាំ២០១៥ ។ ក្នុងវិស័យនេះផ្ដែផ្កានៃការប្រឹងប្រែងខិតខំរបស់គ្រប់ភាគីក្នុងឆ្នាំ ២០១៣ បានបង្ហាញពីលទ្ធផលលើកទឹកចិត្តជាមួយគ្នា និងការផ្តួចផ្តើមគំនិតថ្មីនៃចក្ខុវិស័យទាក់ទងនឹងការអភិវឌ្ឍ ការអប់រំនៅក្រោយឆ្នាំ ២០១៥ ។

### ១. ការបង្កើនការខិតខំឆ្ពោះទៅឆ្នាំ ២០១៥

យូណេស្កូជាមេបញ្ជាការខ្មែរ « ការអប់រំសម្រាប់ទាំងអស់គ្នា » ចាប់តាំងពីការប្រារព្ធសន្និសីទនៅ Jomtien (ប្រទេសថៃ) ក្នុងឆ្នាំ ១៩៩០ រហូតមកដល់ការប្រជុំពិភាក្សាអំពីការអប់រំនៅ ដាកា Dakar (ប្រទេស Sénégal) ក្នុងឆ្នាំ ២០០០ ក្នុងតួនាទីជាអ្នកសម្របសម្រួលទទួលខុសត្រូវលើការខិតខំរបស់គ្រប់ភាគីនៃការអប់រំសម្រាប់ទាំងអស់គ្នា ។ ជារៀងរាល់ឆ្នាំ របាយការណ៍ពិភពលោកទាក់ទងនឹងការតាមដានពិនិត្យ «ការអប់រំសម្រាប់ទាំងអស់គ្នា » បានវាយតម្លៃល្អអំពីវឌ្ឍនភាពនៃការអនុវត្តគោលដៅ នៃដាកា មានជាអាទិ ការធ្វើអត្តសញ្ញាណនិងការកែទម្រង់ប្រកបដោយប្រសិទ្ធភាពនៃគោលនយោបាយទាក់ទងនឹង«ការអប់រំសម្រាប់ទាំងអស់គ្នា » និង បានចាប់អារម្មណ៍ពីបញ្ហាប្រឈមដែលកើតមានឡើង។

មកដល់កាលបរិច្ឆេទកំណត់២០១៥ យូណេស្កូបន្តគាំទ្ររដ្ឋាភិបាល និងសហគមន៍អន្តរជាតិក្នុងការខិតខំប្រឹងប្រែង ដើម្បីពន្លឿនការឈានឡើងឆ្ពោះទៅសម្រេចគោលដៅទាំងនេះ ។

ក្នុងខែមីនា ឆ្នាំ២០១៣ បន្ទាប់ពីការប្រជុំពិភពលោកលើប្រធានបទ « ការអប់រំសម្រាប់ទាំងអស់គ្នា » ដែលរៀបចំធ្វើនៅប៉ារីស (PARIS)ក្នុងខែវិច្ឆិកា ឆ្នាំ២០១២យូណេស្កូបានផ្តួចផ្តើមគំនិត « ការជម្រុញខ្លាំងក្លា » ឈានទៅពង្រីកពង្រឹង ការខិតខំប្រឹងប្រែងនិងការពន្លឿនឆ្ពោះទៅសម្រេចគោលដៅ « ការអប់រំសម្រាប់ទាំងអស់គ្នា » ឱ្យបានមុនពេលបញ្ចប់ការកំណត់នៅដំណាច់ឆ្នាំ ២០១៥ ។

### ២. ការរៀបចំចក្ខុវិស័យសម្រាប់ការអប់រំនៅក្រោយឆ្នាំ ២០១៥

ក្នុងតួនាទីជាមន្ទីរពិសោធន៍អន្តរជាតិអំពីការផ្តួចផ្តើមគំនិត យូណេស្កូដាក់ចេញនូវលំនាំដែលមានគោលដៅពិចារណា ពីការសិក្សា និងការហាត់រៀនវិជ្ជាជីវៈ មុខរបរ នៅក្នុងពិភពលោកដែលកំពុងវិវត្តយ៉ាងស្មុគស្មាញ។

អគ្គនាយិកា Irina Bokova បានបង្កើតក្រុមអ្នកជំនាញការជាន់ខ្ពស់ដែលដឹកនាំដោយលោកស្រី Amina Mohammed ទីប្រឹក្សាពិសេសរបស់លោកអគ្គលេខា អ.ស.ប. ទទួលបន្ទុកផែនការអភិវឌ្ឍក្រោយឆ្នាំ ២០១៥ ។

ក្រុមអ្នកជំនាញការបានរួមប្រជុំលើកទី១ ដើម្បីរៀបចំរបាយការណ៍អំពីចក្ខុវិស័យនៃការអប់រំ និងផ្តល់យោបល់តាមរយៈយូណេស្កូ ក្នុងន័យផ្សព្វផ្សាយជាសង្ខេបថា « ទ្រព្យកំណប់ដែលកប់ក្នុងការអប់រំ » ។

ជាការផ្តួចផ្តើមគំនិត យូណេស្កូមានបំណងលើកទឹកចិត្តឱ្យពិភាក្សាលើគោលការណ៍មូលដ្ឋានដែលបញ្ជាក់យ៉ាងច្បាស់ពីចក្ខុវិស័យនៃការអប់រំសម្រាប់សតវត្សទី XXI ។

ថ្មីៗនេះ រាជរដ្ឋាភិបាលបានប្រកាសផ្សព្វផ្សាយគោលនយោបាយគ្រប់ផែនការសកម្មភាពជាតិស្តីពីការគាំពារនិងការអភិវឌ្ឍកុមារតូចសម្រាប់ជាត្រីវិស័យដើម្បីឈានទៅបន្តអនុវត្តឱ្យសម្រេចដោយជោគជ័យនូវគោលដៅ « ការអប់រំសម្រាប់ទាំងអស់គ្នា » និងគោលដៅដទៃទៀត ។

**គណៈកម្មាធិការស.ប.ស.ខ.**

# អភិវឌ្ឍន៍អបអរសាទរ « ទិវាគ្រូបង្រៀន៥តុលា »

ឆ្នាំ២០១៤ ជាខួបលើកទី១៧ថ្ងៃបង្កើត « **ទិវាគ្រូបង្រៀន៥ តុលា** »ក្រោមគំនិតផ្តួចផ្តើមរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងន័យលើកកម្ពស់គុណតម្លៃគ្រូបង្រៀន ដែលជាអ្នកកសាងមនុស្សគ្រប់វ័យ គ្រប់ភេទ ឱ្យក្លាយជាពលរដ្ឋល្អ មានអនាគតកាន់តែប្រសើរក្នុងការងារត្រឹមត្រូវ ដោយជ្រើសយកប្រធានបទ « **គ្រូបង្រៀន និងគុណភាពអប់រំ** » ។

បើយើងបិទភ្នែក រំលឹកឡើងវិញ នូវព្រឹត្តិការណ៍ក្នុងឆ្នាំ១៩៧៩ ពិសេសពាក្យស្លោកមួយប្រយោគ « **អ្នកចេះបង្រៀនអ្នកមិនចេះ អ្នកចេះច្រើនបង្រៀនអ្នកចេះតិច** » យើងប្រាកដជាជឿជាក់ថា វិស័យអប់រំបានចាប់ផ្តើមពីគ្មានអ្វីៗទាំងអស់ រាប់ទាំងអគារសិក្សា គ្រូបង្រៀន សៀវភៅសិក្សា សម្ភារឧបទេស សម្រាប់បង្រៀន និងរៀន ខណៈពេលដែលសិស្សានុសិស្សស្រេកឃ្លានចង់រៀនសូត្រ មានចំនួនច្រើនលើសលប់។

ជាក្រឹត្យក្រមនៃវឌ្ឍនភាព រដ្ឋាភិបាលពេលនោះ បានកំណត់គោលនយោបាយអំពីវិស័យអប់រំ ដែលមានក្រសួងអប់រំជាតិ ជាសេនាធិការ ដោយផ្តោតលើការឆ្លើយតបដល់សំណូមពររៀនសូត្ររបស់សិស្សានុសិស្សដ៏កុះករ ពោលគឺ ដោះស្រាយបញ្ហាបរិមាណជាអាទិភាពបន្ទាន់ ។ ទង្វើនេះ មិនមានន័យថា យើងមិនគិតគូរដល់បញ្ហាគុណភាពទេ ក៏ប៉ុន្តែកាលៈទេសៈនាពេលនោះ វាជាលទ្ធភាពគ្មានជម្រើស។

មកដល់បច្ចុប្បន្ន ដំណោះស្រាយផ្នែកបរិមាណអាចឆ្លើយតបសមល្មមនឹងតម្រូវការ នៃគ្រប់វិស័យរបស់ប្រទេសជាតិហើយ ខណៈពេលដែលយើងវាយតម្លៃថា គុណភាពអប់រំនៅមិនទាន់ឆ្លើយតបនឹងសំណូមពរទីផ្សារការងារទាំងក្នុង និងទាំងក្រៅប្រទេសនៅឡើយ។ ហេតុនេះ ចាំបាច់ត្រូវបន្តពង្រឹងបន្ថែមទៀត។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានជំរុញ និងលើកទឹកចិត្តឱ្យក្រសួងអប់រំ យុវជន និងកីឡាបន្តកែទម្រង់លើប្រព័ន្ធអប់រំ ដោយសង្កត់លើបញ្ហាគុណភាពអប់រំជាចម្បង។

និយាយពីគុណភាពអប់រំ គឺនិយាយពីសមត្ថភាពប្រកួតប្រជែងដើម្បីអ្វីមួយ ដែលអ្នកចូលរួមដណ្តើមបានដោយជោគជ័យនៅទីលានក្នុង និងក្រៅប្រទេស។ ដូចនេះ តួអង្គដែលមានកាតព្វកិច្ច និងភារកិច្ចក្នុងការលើកកម្ពស់គុណភាពនេះ គឺសាលារៀន គ្រួសារ និងសង្គមក្រោមបរិបទនយោបាយលើវិស័យអប់រំរបស់រាជរដ្ឋាភិបាល។

**សមាគមបុគ្គលិកសិក្សាខ្មែរ ហៅកាត់ថា ស.ប.ស.ខ.** សូមចូលរួមជាគំនិតមួយចំនួនជុំវិញ **ប្រធានបទនៃទិវាគ្រូបង្រៀន ៥ តុលា ២០១៤ « គ្រូបង្រៀន និងគុណភាពអប់រំ »** ដោយយកតួអង្គសាលារៀន ជាតួសំខាន់មកវិភាគ ដែលមានខ្លឹមសារ ដូចតទៅ ៖

**១. ប្រភពជ្រើសរើសបេក្ខជន** ដើម្បីបណ្តុះបណ្តាលជាគ្រូបង្រៀនល្អ បេក្ខជនត្រូវតែជាសិស្សនិស្សិតពូកែ មានចរិយាមារយាទល្អ និងកាយសម្បទារឹងមាំ ។ ប្រការនេះ មិនពិបាកយល់ទេ បើកសិករប្រើពូជស្រូវល្អ គួបផ្សំនឹងកត្តាបន្ទាប់បន្សំ នោះផលស្រូវទទួលបានក៏ខ្ពស់ដែរ ។ ដើម្បីទាក់ទាញសិស្សនិស្សិតពូកែឱ្យជ្រើសរើសការងារជាគ្រូបង្រៀន បញ្ហា២ ត្រូវយកចិត្តទុកដាក់ ៖

+ ការឱ្យតម្លៃចំពោះវិជ្ជាជីវៈគ្រូបង្រៀន ដោយសិស្សានុសិស្ស មាតាបិតា និងសង្គម ។

+ ការគិតគូរដល់លក្ខខណ្ឌនៃការរិវត្តអាជីព និង របៀបរស់សមរម្យ ។

**២. កម្មវិធីសិក្សា**ត្រូវតែឆ្លើយតបនឹងតម្រូវការទីផ្សារការងារក្នុង និងក្រៅប្រទេស ។ និស្សិតផ្ទឹមគឺជាមុខសញ្ញាដែលយើងត្រូវជំរុញ និង បង្កលក្ខណៈឱ្យគេក្លាយជាបណ្ឌិត ជាអ្នកស្រាវជ្រាវ...។

**៣. សម្ភារឧបទេស**សម្រាប់បំរើការបង្រៀន និងរៀនគឺជាអ្វីដែលចាំបាច់និងគ្រប់គ្រាន់ ដូចជាសៀវភៅសិក្សា បណ្ណាល័យ ទីពិសោធន៍ ក្រុមហ៊ុនពាងចក្រ សហគ្រាស មន្ទីរពេទ្យ សម្រាប់ធ្វើកម្មសិក្សា ។

**៤. ការរៀបចំបរិយាកាសសាលារៀន** ក្នុងរង្វង់គណៈគ្រប់គ្រង គ្រូបង្រៀន គណៈកម្មការទ្រទ្រង់សាលារៀន ឱ្យស្មើដៃគ្នា ដើម្បីធ្វើឱ្យសាលារៀនក្លាយជាកន្លែង ដែលសិស្សនិស្សិតចង់រៀន ដែលមាតាបិតា អាណាព្យាបាលចង់ជួបប្រាស្រ័យ និងចង់រួមចំណែកអភិវឌ្ឍ ។

ដូចនេះការពង្រឹងគុណភាពអប់រំ ត្រូវតែអនុវត្តក្រោមផែនការសកម្មភាពដែលទាមទាររយៈពេលវែង និងមធ្យោបាយបច្ចេកទេសហិរញ្ញវត្ថុគ្រប់គ្រាន់ លើប្រព័ន្ធអប់រំទាំងមូល ចាប់ពីបឋមសិក្សា ដល់ឧត្ដមសិក្សា ក្រោយឧត្ដមសិក្សា និងសិក្សាឯកទេស ដោយយោងលើពាក្យស្លោក « **ត្រូវចេះដឹកកាយយកកំណាប់មហាសាល ពីការអប់រំ** »។

សូមអត្ថន័យ និងគោលបំណងនៃ « **ទិវាគ្រូបង្រៀន៥តុលា** » និងឧបការៈនៃអ្នកផ្ដើមគំនិតបង្កើតទិវានេះស្ថិត នៅក្នុងសន្ដានចិត្ត នៃប្រជាជនកម្ពុជាគ្រប់ៗរូបជារៀងរហូត ។

សមាគមបុគ្គលិកសិក្សាខ្មែរ សូមយកឱកាសដ៏ប្រពៃនេះ ថ្លែងការកោតសរសើរដោយស្មោះចំពោះលោកគ្រូ អ្នកគ្រូទាំងអស់ អំពីទឹកចិត្តស្រឡាញ់ និងចង់អោយសិស្សរៀនចេះចាំគ្រប់ៗគ្នាដែលនេះគឺជាស្មារតីពិតប្រាកដរបស់គ្រូបង្រៀន ។

**គណៈកម្មាធិការកណ្ដាល ស.ប.ស.ខ.**

## សេចក្ដីអំណត់ គង់បានសម្រេចដូចប្រាថ្នា

-បើចង់ឱ្យស្រួចដូចបន្លា
ត្រូវតែឧស្សាហ៍ដុសដែកដុល
ទោះមានកុសលអកុសល
ពុំចាំសេសផលនោះជួយជូន ។
-ត្រូវតែខិតខំទ្រាំនឿយហត់
ខំមាត់អត់ធន់រៀនច្បាប់ក្បួន
វិជ្ជាសារពើនេះនាំខ្លួន
ពីងពួនមិនឱ្យក្រតាមទាន់ ។
-បើយើងសង្គ្រោះមនុស្សតោកយ៉ាក
ក្រីក្រលំបាកក្នុងបច្ចុប្បន្ន
ទេវតាចារក្នុងផែនសុវណ្ណ
យើងមានអាសន្នលោកជ្រោមជ្រែង។
-ការក្រិគ្រប់មុខបន្ទុកលើ
ត្រូវធ្វើឱ្យរួចពីមុខឯង
ទើបអ្នកទាំងឡាយគេស្ញប់ស្ញែង
កោតក្រែងថ្វីដៃនិងប្រាជ្ញា ។
-តែឱ្យប្រើឯងម្ដងបន្តិច
ចង់តែសម្រេចដូចប្រាថ្នា
ប៉ុន្តែឥឡូវត្រូវចាប់ការ
លោកថានឿយមុនស្រណុកក្រោយ។

ម៉ុក សំឱក
មូលវិជ្ជាខេមរៈវិជ្ជា

# ច្បាប់ស្តីពីការអប់រំ (ត)

ចំពោះនីតិបុគ្គលត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ២០.០០០.០០០ (ម្ភៃលាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដង នៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ។

បើអំពើដូចបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ ខាងលើ ប្រព្រឹត្តដោយនីតិបុគ្គលដែលជាស្ថាប័នអប់រំ ឬ គ្រឹះស្ថានសិក្សា ហើយស្ថិតក្នុងករណីមិនរាងចាល ត្រូវព្យួរជាបណ្តោះអាសន្ន ឬ ដកហូតជាស្ថាពរនូវអាជ្ញាប័ណ្ណអប់រំរបស់ស្ថាប័នអប់រំ ឬ គ្រឹះស្ថានសិក្សានោះ ។

### មាត្រា ៥៣.- ការផ្សព្វផ្សាយ និង ការឃោសនាពីតិមានអប់រំខុសច្បាប់

គ្រប់អំពើផ្សព្វផ្សាយ ឬ ឃោសនាព័ត៌មានអប់រំដោយគ្មានការអនុញ្ញាត ឬ ដោយបន្លំបោកប្រាស់តាមរូបភាពណាក៏ដោយ ដែលផ្ទុយនឹងបញ្ញត្តិនៃមាត្រា ៤២ នៃច្បាប់នេះ ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួនទ្វេដងនៃប្រាក់ពិន័យអន្តរការណ៍ខាងលើ ។ នីតិបុគ្គលដែលជាស្ថាប័នអប់រំ ឬ គ្រឹះស្ថានសិក្សា ត្រូវព្យួរជាបណ្តោះអាសន្ន ឬ ដកហូតជាស្ថាពរនូវអាជ្ញាប័ណ្ណអប់រំ ។

## ជំពូកទី ១០

## អន្តរប្បញ្ញត្តិ

### មាត្រា ៥៤.- បញ្ញត្តិអន្តរកាល

បន្ទាប់ពីច្បាប់នេះចូលជាធរមាន ស្ថាប័នអប់រំ និងគ្រឹះស្ថានសិក្សាណា ដែលកំពុងដំណើរការខុសពីបញ្ញត្តិនៃច្បាប់នេះ ត្រូវបំពេញបែបបទឱ្យបានត្រឹមត្រូវក្នុងរយៈពេល ០២(ពីរ)ឆ្នាំ ។

(នៅមានត)



# ពាក្យគន្លឹះក្នុងការធ្វើផែនការអប់រំ

## ១. ផែនការ

ផែនការគឺជា ឯកសារដែលកើតឡើងពីការរៀបចំផែនការ ។ នៅក្នុងផែនការមានរាយរ៉ាប់មធ្យោបាយនានាដែលត្រូវអនុវត្តតាម ដើម្បីសម្រេចគោលដៅ វត្ថុបំណង និងចំណុចដៅ ។ នៅក្នុងផែនការមានកំណត់ពីអ្វីដែលចង់បាន នៅពេលណា តាមវិធីណា ត្រូវការធនធានបញ្ចូល (input) អ្វីខ្លះ និងប្រភពក្នុងការប្រមូលធនធានព្រមទាំងវិធីសាស្ត្រក្នុងការគ្រប់គ្រងការអនុវត្ត ។

### ១.១. ប្រភេទនៃផែនការ

ផែនការមានច្រើនប្រភេទ អាស្រ័យទៅតាម ***រយៈពេល***និង ***កម្រិតនៃខ្លឹមសារ*** របស់វា។

- ផែនការរយៈពេលវែង : ជាទូទៅមានរយៈពេលចាប់ពី ១០ឆ្នាំឡើងទៅ។ ផែនការរយៈពេលវែងមានបញ្ជាក់អំពីគោលដៅ និងវត្ថុបំណងជារួម និងជាទូទៅ ។
- ផែនការរយៈពេលមធ្យម : ជាទូទៅមានរយៈពេលចាប់ពី ៣ ទៅ ១០ ឆ្នាំ ។ ផែនការរយៈពេលមធ្យមមានបញ្ជាក់ពីយុទ្ធសាស្ត្រ មានកំណត់ពីវត្ថុបំណង និងចំណុចដៅដែលអាចវាស់វែងបាន កំណត់ពីអាទិភាព និងលើកឡើងពីវិធីសាស្ត្រក្នុងការអនុវត្ត ។
- ផែនការរយៈពេលខ្លី : ជាទូទៅមានរយៈពេលចាប់ពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងផ្សារភ្ជាប់ទៅនឹងវដ្តនៃថវិកាសាធារណៈ(ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម) ។ ផែនការនេះលើកឡើងអំពីសេចក្តីលំអិតនៃកម្មវិធីសកម្មភាព (រួមបញ្ចូលទាំងផែនការហិរញ្ញវត្ថុលំអិតផងដែរ)។

### ១.២. ការកសាងផែនការ

ដំណើរការកសាងផែនការ ធ្វើឡើងទៅតាមជំហានបន្តបន្ទាប់គ្នា រួមមាន:

- ការវិភាគស្ថានភាព (finding the facts): ជាការវិភាគស្ថានភាពរបស់វិស័យអប់រំនាពេលបច្ចុប្បន្ន ដោយធ្វើការវិភាគលើវិស័យ តាមរយៈការពិនិត្យឡើងវិញលើវិស័យឬការធ្វើអង្កេតនានា។
- ការកំណត់ពីស្ថានភាពនៅពេលអនាគត (mapping the future) : ជាការកំណត់ពីទិសដៅគោលនយោបាយ កំណត់វត្ថុបំណង និងចំណុចដៅជាយុទ្ធសាស្ត្រ ប៉ាន់ស្មានតម្រូវការធនធាននិងធនធានដែលមាន កំណត់អាទិភាពនិងរៀបចំយុទ្ធសាស្ត្រអនុវត្ត។
- ការរៀបចំផែនការអនុវត្ត : គឺជាការកសាងផែនការអនុវត្តលំអិត។

## ២. គោលនយោបាយអប់រំ( Educational Policy)

## ២.១. និយមន័យ

គោលនយោបាយអប់រំ គឺជាផែនការឬជាចង្កោមនៃសកម្មភាព ដែលរាជរដ្ឋាភិបាល ឬក្រសួងអប់រំបានកំណត់ឡើង ដើម្បីធ្វើឱ្យមានការប្រែប្រួល ឬកំណត់ពីសេចក្តីសម្រេចចិត្ត និងសកម្មភាពនានាដើម្បីដោះស្រាយនូវបញ្ហាផ្សេងៗ។ និយមន័យមួយទៀតគឺជា ការសម្រេចចិត្ត ឬជាបណ្តុំនៃការសម្រេចចិត្តដែលបានកំណត់ឡើងនូវទិសដៅរួម សម្រាប់បង្កើតជាសេចក្តីសម្រេចចិត្ត និងការរៀបចំសកម្មភាពជាបន្តបន្ទាប់ទៀត (UNESCO, 2000)។

វាបង្ហាញពីបំណង និង ការអនុម័តជាផ្លូវការរបស់រាជរដ្ឋាភិបាល និងបង្ហាញពីសង្គតិភាព[1]នៃសកម្មភាពទាំងឡាយនៅក្នុងការងារ។

គោលនយោបាយ មិនមានលក្ខណៈឋិតថេរ(Static) នោះទេប៉ុន្តែគោលនយោបាយអាចត្រូវបានគេផ្លាស់ប្តូរទៅតាមអង្គភាព បរិបទ និងពេលវេលាណាមួយ ។ គេសង្កេតឃើញថាមូលហេតុដែលនាំឱ្យមានការផ្លាស់ប្តូរគោលនយោបាយរួមមានៈ

- កត្តាសេដ្ឋកិច្ច : ទាក់ទងនឹងចំណាយក្នុងវិស័យអប់រំ ឬសេដ្ឋកិច្ចអប់រំ
- កត្តាប្រជាសាស្ត្រៈ និន្នាការនៃកំណើនប្រជាជនមានការប្រែប្រួល
- កត្តមនោគមវិជ្ជា :អត្ថន័យនៃពាក្យ « ការអប់រំល្អ» ត្រូវបានផ្លាស់ប្តូរ

## ២.២. ការអនុវត្តគោលនយោបាយ

គោលនយោបាយអប់រំ អាចអនុវត្តបានតាមទម្រង់ផ្សេងៗគ្នា និងអាចផ្លាស់ប្តូរផងដែរ ជួនកាលត្រូវបានចាត់ទុកជាមោឃៈ ទៅតាមមូលហេតុនានាដូចជាៈ

- គោលនយោបាយអប់រំ និងច្បាប់អប់រំ : ច្បាប់ បញ្ញត្តិបទបញ្ជា ។ល។
- គោលនយោបាយអប់រំ និងថវិកាអប់រំ : ការបង្កើតគោលនយោបាយអប់រំគឺជាការងារមួយដោយឡែកពីការគ្រោងថវិកាសម្រាប់អនុវត្តគោលនយោបាយអប់រំ ។ គោលនយោបាយក្នុងការគ្រោងថវិកាអាចធ្វើឱ្យមានភាពប្រែប្រួល ភាពយឺតយ៉ាវ និងមិនអាចឱ្យអនុវត្តគោលនយោបាយអប់រំបាន។
- ការអនុវត្តគោលនយោបាយអប់រំៈ ភាពជោគជ័យនៃការអនុវត្តគោលនយោបាយអប់រំគឺ អាស្រ័យលើបុគ្គលដែលអនុវត្តផ្ទាល់ ដូចនេះគោលនយោបាយអាចត្រូវបានកែសម្រួលទៅតាមកម្រិតបុគ្គល និងបរិបទ ជួនកាលអាចត្រូវបានគេបំភ្លេចចោលផងដែរ។

  ២.៣. ដំណើរការរៀបចំគោលនយោបាយ

  ជំហាននានាក្នុងការរៀបចំគោលនយោបាយ រួមបញ្ចូលទាំង ការគិតគូរ ការរៀបចំ និងការវាយតម្លៃគោលនយោបាយអប់រំ ។

- ការកំណត់បញ្ហា
- ការកំណត់ពីរបៀបវារៈ
- ការរៀបចំគោលនយោបាយ
- ការធ្វើសេចក្តីសម្រេចចិត្តលើគោលនយោបាយ
- ការអនុវត្តគោលនយោបាយ
- ការវិភាគឬបកស្រាយពីលទ្ធផលនៃការអនុវត្ត

1. ការរាប់រកគ្នា - ការរាប់អានគ្នា - ការរួបរួមគំនិតគ្នា - ការជួបប្រសប់ - ការប្រជុំ

### ២.៣. បញ្ហានានានៅក្នុងគោលនយោបាយអប់រំ

ជាទូទៅការអនុវត្តគោលនយោបាយអប់រំពាក់ព័ន្ធជុំវិញនឹងកត្តាសង្គម និងកត្តានានាដូចជាៈ

- ភាពខ្វែងគំនិតគ្នាៈ គោលនយោបាយអប់រំខ្លះធ្វើឱ្យមានភាពខ្វែងគំនិតគ្នាមួយចំនួន។
- កត្តាសាធារណៈ : បញ្ហាសង្គមដែលស្ថិតនៅក្រៅគោលនយោបាយសាធារណៈ។

## ៣. យុទ្ធសាស្ត្រ (Strategy)

### ៣.១.និយមន័យ

យុទ្ធសាស្ត្រគឺជា ទិសដៅ (direction) និង***វិសាលភាព*** របស់អង្គភាព***រយៈពេលវែង*** ដែលរៀបចំឡើងដើម្បីសម្រេច ***ផលប្រយោជន៍***(advantage)សម្រាប់អង្គភាព តាមរយៈការកែតម្រូវ ***ធនធាន*** នៅក្នុង ***បរិស្ថានដែលត្រូវពុះពារ*** ដើម្បីសម្រេចបានតាម ***ទិសដៅគោលនយោបាយ***និងការរំពឹងទុករបស់***អ្នកពាក់ព័ន្ធ*** ។

- ទិសដៅៈ គឺជាអ្វីដែលអង្គភាពព្យាយាមសម្រេចឱ្យបាន ក្នុងរយៈពេលវែង។
- វិសាលភាពៈ គឺជាក្រុមមុខសញ្ញាដែលអង្គភាពកំណត់យក និងប្រភេទសកម្មភាពដែលត្រូវអនុវត្ត ។
- ផលប្រយោជន៍ៈ គឺជាអ្វីដែលអង្គភាពកំណត់ ដើម្បីមើលឱ្យឃើញពីការប្រែប្រួល ។
- ធនធានៈ គឺជាអ្វីដែលត្រូវការសម្រាប់ប្រើប្រាស់នៅក្នុងការអនុវត្ត ដូចជា ធនធានមនុស្ស សម្ភារៈ ។ល ។
- បរិស្ថានៈ គឺជាកត្តាខាងក្រៅដែលអាចមានភាពប៉ះពាល់ដល់ការអនុវត្ត ។
- អ្នកពាក់ព័ន្ធៈ គឺជាក្រុមដែលគេរំពឹងទុក ថានឹងទទួលលទ្ធផល ឬផលប៉ះពាល់ពីការអនុវត្ត។

ការជ្រើសរើសយុទ្ធសាស្ត្រ (Strategic choice) ទាមទារឱ្យមានការយល់ដឹងស៊ីជម្រៅលើការរំពឹងទុករបស់អ្នកពាក់ព័ន្ធ(the "ground rules")ដោយស្មើភាពគ្នា។ បន្ទាប់មកធ្វើការកំណត់ជម្រើសយុទ្ធសាស្ត្រធ្វើការវាយតម្លៃ និងជ្រើសរើសយកយុទ្ធសាស្ត្រដែលសមស្រប ។

នៅពេលដែលយុទ្ធសាស្ត្រមួយត្រូវបានវិភាគគេត្រូវតែប្រែក្លាយយុទ្ធសាស្ត្រនោះទៅជាសកម្មភាពអនុវត្ត។

### ៣.២. ប្រភេទផ្សេងៗនៃយុទ្ធសាស្ត្រ

យុទ្ធសាស្ត្រដែលត្រូវបានបង្កើតនៅក្នុងវិស័យ ឬអង្គភាពមួយមានកម្រិតខុសៗ គ្នារាប់បញ្ចូលទាំងកម្រិតថ្នាក់ជាតិរហូតដល់សាលារៀន ។

***យុទ្ធសាស្ត្រថ្នាក់ជាតិ :*** ទាក់ទងនឹងវត្ថុបំណងទូទៅ និងវិសាលភាពរបស់វិស័យ ដែលត្រូវរៀបចំឡើងដើម្បីសម្រេចបានតាមការរំពឹងទុករបស់អ្នកពាក់ព័ន្ធទូទៅ ។ នៅកម្រិតនេះ យុទ្ធសាស្ត្រមានឥទ្ធិពលខ្លាំងទៅលើការវិនិយោគនានា និងដើរតួជាការសម្រេចចិត្តបែបយុទ្ធសាស្ត្រនៅក្នុងវិស័យ ។ ជាទូទៅយុទ្ធសាស្ត្រថ្នាក់ជាតិត្រូវបានគេលើកឡើងមានលក្ខណៈស្រដៀងនឹង លក្ខណៈបេសកកម្ម (mission statement) ។

***យុទ្ធសាស្ត្រតាមអនុវិស័យ :*** ត្រូវបានរៀបចំឡើងដើម្បីសម្រេចលទ្ធផលនៅក្នុងវិស័យណាមួយ ។ យុទ្ធសាស្ត្រប្រភេទនេះទាក់ទងនឹងសេចក្ដីសម្រេចចិត្តបែបយុទ្ធសាស្ត្រក្នុងការជ្រើសរើសសកម្មភាព វិសាលភាពជាក់លាក់ ដើម្បីសម្រេចបានតាមការរំពឹងទុករបស់អ្នកពាក់ព័ន្ធមួយក្រុមណានោះ ។

***យុទ្ធសាស្ត្រប្រតិបត្តិ :*** ទាក់ទងនឹងវិធីសាស្ត្រដែលអង្គភាពអនុវត្តរៀបចំឡើង ដើម្បីដំណើរការសកម្មភាពទៅតាមទិសដៅជាយុទ្ធសាស្ត្រ ។ ជាទូទៅយុទ្ធសាស្ត្រប្រតិបត្តិទាក់ទងនឹងការរៀបចំធានា ដំណើរការ និងអ្នកអនុវត្ត។ល។

**ឯកសារនាយកដ្ឋានផែនការ**

(នៅមានត)

# ប្រវត្តិនៃការអប់រំក្នុងពិភពលោក (ត)

**គ. ចំណេះដឹងជាឧបករណ៍**

ពួកសូហ្វីសអះអាងថា គេអាចអប់រំសិស្សរបស់គេឱ្យទទួលបាន ការពិភាក្សាជាសាធារណៈតាមការបង្រៀនពួកគេ

១. របៀបប្រើប្រាស់ចិត្តវិទ្យាក្នុងពួកមនុស្ស ដើម្បីដឹងពីអ្វីដែលនឹងសុំ ឬអំពាវនាវដល់ទស្សនិកជន ។

២. របៀបរៀបចំអំណះអំណាង ដែលប្រកបដោយការជឿជាក់ និងបញ្ចុះបញ្ចូល ។

៣. បំណិនក្នុងការនិយាយជាសាធារណៈ គឺដោយដឹងថា អ្វីជាពាក្យ ឧទាហរណ៍ និងប្រភេទនៃហេតុផល ដើម្បីយកមកប្រើប្រាស់ឱ្យទទួលបានការពិភាក្សា ឬករណីរឿងណាមួយ បានជោគជ័យ ។

ប្រសិនបើពួកគេនៅរស់ដល់សព្វថ្ងៃ ពួកសូហ្វីសទំនងជាអះអាងថា គោលវិធីរបស់ពួកគេ ផ្ដល់ឱ្យមនុស្សនូវអ្វីដែលគេចង់បាន គឺបំណិនរៀបចំគំនិត និងដើម្បីបង្ហាញពួកគេ ដោយមានប្រសិទ្ធិភាពខ្លាំងពេកហួតដល់មនុស្ស នឹងត្រូវបានគេបញ្ចុះបញ្ចូលឱ្យទទួលយកការប្រកាសរបស់ពួកគេ ។ ទោះជាយ៉ាងណាក៏ដោយ ការរិះគន់របស់ពួកសូហ្វីសបានចោទប្រកាន់ពួកគេ ពីការសង្កត់ធ្ងន់ផ្នែកបច្ចេកទេសដែលទទួលបានការអះអាង ទៅលើការស្វែងរកសច្ចភាពនៃបញ្ហាដែលនៅជិតៗ ឬហៀបនឹងកើតឡើង ។

ពួកសូហ្វីស ប្រៀបដូចជាអ្នកបង្កើតរូបភាពសម័យទំនើប ដែលប្រើប្រាស់ប្រព័ន្ធឃោសនា ដើម្បីក្ដោបយកបេក្ខជនខាងនយោបាយ និងវិស្សុតជន (celebrities)។ ថ្វីបើការពិភាក្សាខាងនយោបាយនាពេលសព្វថ្ងៃនេះ និងការពិភាក្សាបេក្ខជន កើតមានឡើងតាមទូរទស្សន៍ ជាជាងរស់នៅក្នុងមជ្ឈមណ្ឌលក្រុងអាថែននោះ ពួកសូហ្វីសនឹងអះអាងពីបច្ចេកទេសរបស់ពួកគេ នៅតែមានភាពរឹងមាំ ។ វានៅតែមានសារៈសំខាន់ ដើម្បីយល់ដឹងពីទស្សនិកជន ដើម្បីអំពាវនាវសុំពីតម្រូវការរបស់គេ និងដើម្បីប្រើប្រាស់ការបញ្ចុះបញ្ចូលប្រកបដោយបំណិន ដើម្បីធ្វើឱ្យពួកគេជឿជាក់ ។ ពួកគេគួរតែពិចារណាទៅលើក្រុមដែលមានការផ្ដោតអារម្មណ៍ ការស្ទង់មតិមហាជនជាសាធារណៈ ហើយនិងឧបករណ៍បញ្ចុះបញ្ចូលដែលមានប្រយោជន៍កំពុងផ្សព្វផ្សាយជាអវិជ្ជមាន ។

**ឃ. វិធីProtagoras**

តាមមធ្យោបាយជាច្រើន ពួកសូហ្វីស បានអភិវឌ្ឍគោលវិធីទំនើបគួរទាក់ទាញអារម្មណ៍ចំពោះការអប់រំ ។ Protagoras (485-414 B.C)ដែលជាពួកសូហ្វីសដ៏សំខាន់បំផុតម្នាក់នោះ បានអភិវឌ្ឍល្បិចបង្រៀន ៥ ជំហានប្រកបដោយប្រសិទ្ធភាពខ្ពស់[2]៖

១. ផ្ដល់សម្ដី ឬ សុន្ទរកថា(Speech)ដ៏ចំណានដើម្បីឱ្យសិស្សយល់ដឹងថា គ្រូរបស់គេអាចធ្វើអ្វី នៅពេលដែលគាត់មានបំណងនឹងបង្រៀនគេ ។ សម្ដីឬ សុន្ទរកថានេះក៏ផ្ដល់ឱ្យគេនូវគំរូមួយអាចអនុវត្តតាម។

២.ឱ្យសិស្សពិនិត្យមើលសម្ដី សុន្ទរកថាដ៏អស្ចារ្យនៃវាគ្មិនដ៏ល្បីល្បាញ (famous orators) ដើម្បីបរិយាយគំរូទាំងឡាយដែលអាចយកទៅប្រើប្រាស់បាន ។

៣. សិក្សាប្រធានបទគន្លឹះនៃតក្កវិទ្យា វេយ្យាករណ៍និង វោហារសាស្ត្រ ។

៤. ផ្ដល់ការប្រតិបត្តិនៃសុន្ទរកថា(Oration) ដែលគាត់អាចវាយតម្លៃ ដើម្បីផ្ដល់ព័ត៌មានត្រឡប់ទៅសិស្ស ។

៥. វាគ្មិនដែលជាសិស្សផ្ដល់សុន្ទរកថា ជាសាធារណៈ ។

2. Edward Schiappa, *Protagoras and Logos: A Study in Greek Philosophy and Rhetoric* (Columbia: University of South Carolina Press, 2003; also see L.Glen Smith, *Livesin Education: People and Ideas in the Development* of teaching (Ames, lowa: Education Study Press,1984),pp.7-9

វិធីរបស់ Protagoras ប្រដូចកម្មវិធីអប់រំគ្រូនាពេលសព្វថ្ងៃ ដែលក្នុងនោះអនាគតគ្រូបង្រៀន សិក្សាសិល្បៈសេរី និងមុខវិជ្ជាដែលទាក់ទងនឹងវិជ្ជាជីវៈ សិក្សាល្បិចបង្រៀនផ្សេងៗ និងធ្វើកម្មសិក្សា នៅក្រោមការដឹកនាំពីគ្រូដែលជួយសហប្រតិបត្តិការប្រកបដោយបទពិសោធ ។

**ង. សច្ចភាពដែលស្ថិតនៅស្ថិតស្ថេរ ឬសច្ចភាពមិនមានភាពរឹងមាំ**

ការបង្ហាញខ្លួនរបស់ពួកសូហ្វីស នៅឆាកឱ្យគេមើលឃើញក្នុងសម័យបុរាណ បានលើកឡើងនូវបញ្ហាអប់រំដ៏សំខាន់ ដែលចម្លើយនាំទៅដល់វិវាទរហូតដល់សព្វថ្ងៃនេះ។ពួកសូហ្វីសគឺជាពួកដែលមានសច្ចភាពខាងសីលធម៌មិនរឹងមាំ (moral relativists)ដែលបានអះអាងថា អ្វីដែលយើងចាំបាច់យល់ដឹងអាស្រ័យទៅលើកាលៈទេសៈ ដែលយើងរស់នៅ។ សូក្រាត ប្លាតុង និងអារីស្តូត បានប្រឆាំងនឹងសច្ចភាពមិនរឹងមាំរបស់គេ ហើយបានទទូចចង់បានអត្ថិភាពនៃសច្ចភាពស្ថិតស្ថេរ ដែលយើងត្រូវតែយល់ដឹង ។ Isocrates ដែលជាគ្រូសិល្បៈខាងការថ្លែងសុន្ទរកថា បានព្យាយាមដោះស្រាយវិវាទ ដោយនិយាយថា យើងចាំបាច់ត្រូវយល់ដឹងអ្វីដែលជាការពិត ប៉ុន្តែក៏អនុវត្តវាផងដែរ ទៅនឹងស្ថានភាពដែលយើងរស់នៅ ។ យើងនឹងពិភាក្សាទស្សនៈ នៃទស្សនវិទូទាំង៤នាក់នេះ។

**៥.២. Socrates :ការអប់រំតាមការស្វ័យពិនិត្យ**

**ក. គោលការណ៍សកល**

មិនដូចជាពួកសូហ្វីស ដែលបានអះអាងថា ចំណេះដឹងអាស្រ័យទៅលើស្ថានភាព ដែលមនុស្សប្រើវា ។ សូក្រាត (៤៦៩-៣៩៩មុនគ.ស.) ជឿជាក់ថា ចំណេះដឹង គឺត្រូវផ្អែកទៅលើអ្វីដែលជាសច្ចភាពសកល គឺគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ។ គំនិតសូក្រាត មានសារៈសំខាន់ក្នុងប្រវត្តិអប់រំ ពីព្រោះគាត់បានការពារយ៉ាងរឹងមាំថា សេរីភាពខាងការសិក្សាដើម្បីគិត សួរ និងបង្រៀន ។ គាត់ក៏មានសារៈសំខាន់ផងដែរ ក្នុងនាមជាគ្រូរបស់ Platon ដែលក្រោយមកបានធ្វើឱ្យគំនិតរបស់ Socrates ជាច្រើនមានលក្ខណៈជាប្រព័ន្ធ[3]។

**ខ. ឧត្តមភាពសីលធម៌**

ទស្សនវិជ្ជា Socrates សង្កត់ធ្ងន់ទៅលើគោលការណ៍សីលវិទ្យា ដែលមនុស្សម្នាក់គួរតែខិតខំសម្រាប់ឧត្តមភាពសីលធម៌រស់នៅដោយវាងវៃ និងធ្វើសកម្មភាពប្រកបដោយវិចារណញ្ញាណ ។ Socrates ជឿជាក់ថា ឧត្តមភាព សីលធម៌មានភាពកំពូលខ្លាំងជាងការបណ្តុះបណ្តាលបច្ចេកទេសរបស់ពួកសូហ្វីស ។

**គ. តួនាទីគ្រូរបស់សូក្រាត**

បញ្ញត្តិរបស់សូក្រាតនៃគ្រូបង្រៀន ខុសប្លែកពីពួកសូហ្វីស ។ គាត់មិនបានជឿថា ចំណេះដឹងឬគតិបណ្ឌិតអាចផ្ទេរពីគ្រូទៅសិស្សម្នាក់បានទេពីព្រោះគាត់បានជឿជាក់ថា បញ្ញត្តិនៃចំណេះដឹងពិត មានពិតមែន តែវាបានកប់បាត់នៅក្នុងចិត្តមនុស្ស ។ គ្រូត្រូវតែសួរសំណួរឱ្យបានត្រឹមត្រូវ ដើម្បីឱ្យសិស្សគិតឱ្យបានល្អិតល្អន់ អំពីសំណួរសំខាន់ៗ។ ការអប់រំប្រកបដោយសេរីភាពពិតប្រាកដមួយនឹងភ្ញោចសិស្សឱ្យ ស្រាវជ្រាវរកគំនិត ដោយនាំទៅដល់ញាណនូវការពិតដែលមាន តែមិនទាន់បញ្ចេញឱ្យឃើញនៅក្នុងចិត្តរបស់គេ។ (នៅមានត)

**លោកអនុបណ្ឌិត សូ សុធីរ**

| | | |
|---|---|---|
| *បើចង់ស្រាលខ្លួន* | *រៀនសូត្រឱ្យមួន* | *ឱ្យមាំឱ្យស្ទាត់* |
| *កុំចេះស្ទាក់ស្ទើរ* | *ល្ងីល្ងើឥតបទ* | *បើចេះប្រាកដ* |
| | *ប្រាក់រត់តាមហៅ ។* | |

*ច្បាប់ល្បើកថ្មី (ក្រមង៉ុយ)*

[3] Gary Alan scott, Plato’s Socrates as Educator(Albany : State University of ew York Press.2000),pp.1-12. Also see Alven Neiman, Ironic Schooling: Socrates, Pragmatism and Higher Leaning, Educational Theory (Fall 1991),pp.371-384

# អត្ថន័យនៃការសិក្សា

ការសិក្សាជាគ្រឿងអលង្ការមួយបែបសម្រាប់តាក់តែងមនុស្សឱ្យបានជាមនុស្សពេញលក្ខណៈ មានសមត្ថភាពបរិបូរណ៍គិតគូរដល់ការងារ និងសម្រាប់ធ្វើមនុស្សឱ្យមានគុណធម៌ដ៏ល្អ ឱ្យចេះគ្រប់គ្រងជីវិតទាំងជាមធ្យោបាយសម្រាប់សាងខ្លួនឱ្យបានជាពលរដ្ឋល្អ ។

ហេតុនេះ ទើបបណ្ឌិតទាំងឡាយ បានពន្យល់អត្ថន័យរបស់ការសិក្សាទុកច្រើនយ៉ាងដូចតទៅ ៖

ក. ដើម្បីអប់រំចិត្តរបស់ក្មេងឱ្យចេះដឹង ជ្រើសរើសយកសេចក្ដីល្អទាំងពួង

ខ. ដើម្បីជាមធ្យោបាយសម្រាប់សាងខ្លួន ទប់ទល់ជីវិតគ្រប់យ៉ាងឱ្យសមដល់សមត្ថភាព

គ. ដើម្បីចែកសេចក្ដីចេះដឹងដល់មនុស្ស ឱ្យយកសេចក្ដីចេះដឹងនោះ ទៅប្រកបកិច្ចការផ្សេងៗឱ្យត្រូវតាមគោលវិទ្យាសាស្ត្រ

ឃ. ដើម្បីមនុស្សមានសេចក្ដីល្អវិសេស ប្រាសចាកសេចក្ដីអាក្រក់ ដោយប្រកបកិច្ចការទាំងពួងត្រឹមត្រូវតាមលក្ខណៈគ្រប់យ៉ាង។

អ្នកប្រាជ្ញទាំងឡាយបានពន្យល់អត្ថន័យរបស់ការសិក្សាទុកច្រើនពេកហួសវិស័យនឹងដកស្រង់យកមកពោលឱ្យសព្វគ្រប់ជូនលោកអ្នកនាងស្ដាប់ក្នុងឱកាសនេះ ។ សរុបសេចក្ដីឱ្យខ្លី ការសិក្សាជាកិច្ចមួយប្រចាំជីវិតរបស់មនុស្សគ្រប់រូបមិនថាប្រុសឬស្រីទេនឹងខានពុំបានឡើយ ដើម្បីធ្វើសេចក្ដីអង់អាចដែលមាននៅប្រចាំកាយស្រាប់ឱ្យចម្រើនឡើង ដើម្បីប្រយោជន៍ខ្លួន និងប្រយោជន៍ជាតិឱ្យបានសម្រេចដោយល្អ បានសេចក្ដីសុខ ព្រមទាំងរក្សាសេចក្ដីសុខរបស់សង្គមឱ្យប្រព្រឹត្តទៅបានស្រួល។

ឯការសិក្សាត្រូវប្រកបដោយអង្គផ្សេងច្រើនប្រការ តែក្នុងទីនេះសូមរៀបរាប់ដោយសង្ខេប គឺត្រូវប្រកបដោយអង្គ៤ គឺ ៖

១. វិជ្ជាសិក្សា ៖ បានខាងការសិក្សាផ្លូវវិជ្ជា គឺចំណេះគ្រប់យ៉ាងដើម្បីឱ្យកើតសេចក្ដីចេះដឹងឈ្លាសវៃក្នុងការប្រកបអាជីវៈឱ្យសម្រេចផលល្អ ។ ឧទាហរណ៍ ៖ ការរៀនវិជ្ជាផ្សេងៗតាមគោលសូត្រ អក្សរសាស្ត្រ សព្ទសាស្ត្រ ភាសាសាស្ត្រ ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ រហូតដល់វិទ្យាសាស្ត្រ ។

២. កម្មន្តសិក្សា ៖ បានខាងការចុះពិសោធធ្វើការងារគ្រប់បែប តាមចំណេះវិជ្ជាដែលបានសិក្សាមកហើយនោះ ឱ្យស្ទាត់ជំនាញផ្ទាល់ខ្លួន ។ ដូចរៀនវិជ្ជាកសិកម្មក្ដី ឧស្សាហកម្មក្ដី បានចេះដឹងហើយបានធ្វើការនោះដោយខ្លួនឯង ឱ្យបានប្រឹកតាមចំណេះដែលបានរៀន ។

៣. ពលសិក្សា ៖ បានខាងការសិក្សាផ្លូវកាយ អាហារ ឬអត្តពលកម្មឱ្យមានរាងកាយមាំទាំការពារមិនឱ្យមានរោគភ័យ ឈឺចាប់ឱ្យបានសុខកាយសប្បាយចិត្ត ចម្រើនកម្លាំងពលំ និងសាច់ដុំ។ ឧទាហរណ៍ដូចការហាត់ប្រាណ រត់ លោតហែលទឹក លេងយោលទៅយោលមក ... រហូតដល់កីឡាផ្សេងៗដែលជាការហ្វឹកហាត់រាងកាយឱ្យមាំមួន។

៤. ចរិយាសិក្សា ៖ បានខាងសិក្សាអប់រំខាងផ្លូវកាយ វាចា ចិត្ត ឱ្យបានជាអ្នកដឹងច្បាប់ខុសត្រូវ តាំងនៅក្នុងសីលធម៌ដ៏ល្អ ដើម្បីជាឧបករណ៍ដឹកនាំឱ្យកើតសេចក្ដីសុខ សេចក្ដីចម្រើនដល់ខ្លួន ដល់ក្រុមគ្រួសារ ឬដល់សង្គម និងដល់ប្រទេសជាតិ ។

និយាយដោយខ្លី គឺការសិក្សាឱ្យបានជាមនុស្សមានចំណេះដឹង ធ្វើការងារតាមចំណេះ សេចក្ដីប្រព្រឹត្តត្រឹមត្រូវល្អ និងជាមនុស្សមានរាងកាយមាំទាំរឹងប៉ឹង ។

អង្គ៤របស់ការសិក្សានេះត្រូវអាស្រ័យគ្នាជានិច្ចខ្វះពុំបាន បើខ្វះអង្គណាមួយមិនរាប់ថាការសិក្សាពេញអង្គបានឡើយ ព្រោះថាបើខ្វះអង្គណាមួយ រមែងជាឧបសគ្គដល់ការចិញ្ចឹមជីវិត ។ សូមលើកឧទាហរណ៍មកប្រៀបឱ្យងាយយល់ ដូចជាអ្នកមានវិជ្ជាចេះដឹងខ្ពស់ មានសេចក្ដីប្រព្រឹត្តល្អ ថែមទាំងចុះអនុវត្តធ្វើការងារដោយល្អផងទៀត ។ តែជាមនុស្សមានរោគប្រចាំកាយ ឈឺជានិច្ច ឬជាទុព្វលភាព ក៏មិនអាចមានកម្លាំងល្មមនឹងប្រកបអាជីវកម្មពេញមុខក្រសួងបានឬមានសេចក្ដីប្រព្រឹត្តល្អ មានកម្លាំងពលំគ្រាន់បើ ទាំងមានការព្យាយាមធ្វើការងារទៀត ។ តែវិជ្ជាក៏រមែងប្រកបការបំពេញមុខក្រសួងឱ្យកើតផលពុំបាន ឬមួយមានសេចក្ដីចេះដឹងល្អ មានកម្លាំងពលំមាំមួន ទាំងបានព្យាយាមធ្វើការហើយ តែសេចក្ដីប្រព្រឹត្តមិនល្អមិនមានអ្នកណាសេពគប់ជឿស្ដាប់តាម ក៏រមែងប្រកបអាជីវកម្មមិនស្រួល បំពេញការងារជូនក្រសួងមិនបានល្អ មិនបានចម្រើនឡើយ ។

ហេតុដូចបរិយាយមកនេះ លោកទាំងមូលទើបកំណត់ឱ្យយុវជន យុវនារីរាល់រូប ទទួលការសិក្សាទាំង ៤ ចំណែកដូចពោលមកហើយនោះ ដោយសេចក្ដីប្រឹងប្រែង ដើម្បីឱ្យមានវិជ្ជាល្អ ចរិយាល្អ មានការងារល្អ មានកម្លាំងកាយល្អព្រមទាំងឱ្យមានទឹកចិត្តជាអ្នកកីឡាតាមសមគួរ ដល់អាជីពរបស់ខ្លួន ។

ប្រទេសណាមួយបរិបូរណ៍ដោយការសិក្សាពេញអង្គទាំង ៤ ទូទៅគ្រប់ទីតំបន់ និគមជនបទ ប្រទេសនោះជា « **អារ្យប្រទេស** » បានចម្រើនរុងរឿងដោយអរិយធម៌ វប្បធម៌ និងសម្បត្តិគ្រប់យ៉ាងពិតៗ ។ ប្រទេសណាប្រាសចាកការសិក្សាទាំង ៤ផ្នែកនេះ ប្រទេសនោះជា « អនារ្យប្រទេស » ព្រោះខ្សត់ខ្សោយអារ្យធម៌ វប្បធម៌ និងសម្បត្តិគ្រប់យ៉ាង ប្រជាជាតិក្នុងប្រទេសទាំងមូលជាអនារ្យជន ។

ប្រទេសនីមួយៗ ទោះធំក្ដី តូចក្ដី លុះតែបរិបូរណ៍ដោយពលរដ្ឋមានវិជ្ជាល្អ ការងារល្អ សុខភាពល្អ ចរិយាល្អផង បរិបូរណ៍ដោយគ្រឹះស្ថាន ផ្លូវថ្នល់ ទឹកភ្លើងភ្លឺប្រាលន្ទាលឆ្អិនឆ្អៅទូទៅគ្រប់ទីកន្លែងផង ទើបឈ្មោះថាអារ្យប្រទេសពេញលក្ខណៈបាន។

ព្រោះហេតុនេះបានជាប្រមុខរាជរដ្ឋាភិបាល ខិតខំដោយផ្ទាល់ផង ណែនាំប្រជាពលរដ្ឋគ្រប់ប្រភេទ គ្រប់ឋានៈផង ស្ថាបនានូវស្ថាបត្យកម្មទាំងឡាយច្រើនជាអនេកប្បការ មានការសិក្សាវិជ្ជាផ្សេងៗ ទាំងខាងអាណាចក្រ ទាំងខាងពុទ្ធចក្រ គ្រឹះស្ថានសិក្សា មន្ទីររាជការសាធារណៈ ផ្លូវថ្នល់ ។ល។ ព្រមទាំងស្ថាបនាខាងផ្នែកសេដ្ឋកិច្ច កសិកម្ម មានទំនប់ទឹកសម្រាប់ប្រជាពលរដ្ឋធ្វើស្រែចម្ការ ច្បារដំណាំជាដើម ។ កសាងប្រទេសកម្ពុជាឱ្យបានជាអារ្យប្រទេសជឿនលឿនអស់កាលយូរអង្វែងទៅ ។

**លោក ថែម ផាន**

## មនុស្ស និង សត្វ

កើតជាមនុស្សសត្វឆ្កែតែមានបុណ្យចាស់ នាំឱ្យឆ្កែនោះមានម្ចាស់ស្រឡាញ់
កន្លែងនៅស្អាតចំណីឆ្ងាញ់ ៗ សម្បូរសាច់ខ្លាញ់សុខជាងមនុស្សខ្លះ។
កើតមកជាមនុស្សបុណ្យស្ទើរតែគ្មាន ក្រខ្សត់អត់ឃ្លានលំបាកក្រៃណាស់
រងទុក្ខជាងសត្វដែលមានបុណ្យខ្លះ កើតមកជួបម្ចាស់អ្នកមានចិត្តធម៌ ។
តែទោះយ៉ាងណាជាតិមនុស្សឧត្ដម ព្រោះអាចសន្សំសីលទានបន្ត
តិរច្ឆានពុំអាចសាងអំពើល្អ បើមនុស្សឥតធម៌អន់ជាងសត្វហើយ។

**គុយ សុធន**



# ចិត្តវិទ្យាអប់រំ

## សម្បទា និងសម្បទាគរុកោសល្យរបស់គ្រូបង្រៀន (តចប់)

### ១. សញ្ញាណទូទៅ

**១.១. សម្បទាគរុកោសល្យជាសម្បទាពិសេសមួយ**

សម្បទាគរុកោសល្យជាសម្បទាប្រាកដមួយ ដែលមានអត្ថន័យធំធេងចំពោះសង្គម ហើយមានរចនាសម្ព័ន្ធស្មុគស្មាញព្រោះជាសម្បទាមានចរិតសង្គមកម្រិតខ្ពស់ ។

**ឧទាហរណ៍ ៖** បណ្តុះបណ្តាលយុវជន ដើម្បីក្លាយទៅជាមនុស្សថ្មី ក្នុងសង្គមប្រជាធិបតេយ្យ ។

សម្បទាគរុកោសល្យជាលក្ខណៈនៃបុគ្គលិកលក្ខណៈដែលឆ្លើយតបនឹងតម្រូវការសកម្មភាពគរុកោសល្យ និងធានាឱ្យសកម្មភាពគរុកោសល្យផ្តល់លទ្ធផល និងគុណភាពខ្ពស់ ។

សម្បទាជាផ្នែកមួយនៃរចនាសម្ព័ន្ធរបស់បុគ្គលិកលក្ខណៈ ។ ឯសម្បទាគរុកោសល្យជាផ្នែកមួយនៃរចនាសម្ព័ន្ធបុគ្គលិកលក្ខណៈរបស់អ្នកអប់រំ និងគរុវិទូ ។

ការបណ្តុះបណ្តាល និងការអភិវឌ្ឍសម្បទាគរុកោសល្យត្រូវផ្អែកលើបុគ្គលិកលក្ខណៈរបស់គ្រូ ។ ចំណុចគ្រឹះសំខាន់នៃសម្បទាគរុកោសល្យមាន ៖

- កម្រិតវប្បធម៌ - សញ្ចេតនា - ឆន្ទៈរីកចម្រើន - អត្តចរិត ។ល។

សម្បទាទូទៅ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងសម្បទាពិសេស ។ សម្បទាទូទៅ រួមមានលក្ខណៈល្អនៃសកម្មភាពបញ្ញា ប្រតិកម្មសរីរាង្គឥន្ទ្រីយ៍ « រាងរែងចាប់ទទួលបានរំញោច ... » ការសង្កេតល្អិតល្អន់ លំនឹកល្អ រូបារម្មណ៍ ច្នៃប្រឌិត ការគិតល្អ ... ។ បញ្ញា និងការគិតច្នៃប្រឌិតជាធាតុគ្រឹះក្នុងការបណ្តុះបណ្តាល និងការអភិវឌ្ឍសម្បទា ។ ទាំងអស់នេះជាពន្លករបស់សម្បទាពិសេស ហើយក៏ជាពន្លកនៃសម្បទាគរុកោសល្យដែរ ។

**១.២. សម្បទាទាំងបីក្នុងវិជ្ជាជីវៈគ្រូបង្រៀន**

គ្រូជាអ្នកបង្រៀនផង និងជាអ្នកអប់រំផង បានន័យថា គ្រូជាអ្នកផ្តល់ចំណេះដឹងផង និងអប់រំបុគ្គលិកលក្ខណៈរបស់ក្មេងជំនាន់ក្រោយ ទៅតាមគំរូមនុស្សដែលសង្គមនីមួយៗចង់បានផង ។ ដើម្បីបំពេញបេសកកម្មដ៏ធ្ងន់ធ្ងរនេះ គ្រូត្រូវតែមានសម្បទាបីយ៉ាងដូចតទៅ ៖

**ក. សម្បទាក្នុងការបង្រៀន ៖** ក្នុងការបង្រៀន គ្រូត្រូវស្គាល់សមត្ថភាពសិស្ស និងមានសមត្ថភាពផ្តល់ឬផ្ទេរចំណេះដឹងរបស់ខ្លួនដល់សិស្ស ព្រមទាំងកម្រិតនៃការដឹកនាំការសិក្សារបស់សិស្ស ។ ក្នុងករណីនេះគ្រូត្រូវមាន ៖

- សម្បទាក្នុងការស្គាល់វិសេសភាពចិត្តរបស់សិស្ស ដូចជាស្គាល់តម្រូវការ ទំនោរ និងកម្រិតសមត្ថភាពរបស់សិស្ស ។
- សម្បទាក្នុងការបំប្លែងឯកសារ ឬមេរៀន។ គ្រូត្រូវចេះរៀបចំមេរៀន ឬ ឯកសារសិក្សាឱ្យសមស្របតាមកម្រិតយល់ដឹងរបស់សិស្ស ។

•សម្បទាក្នុងការច្នៃប្រឌិតខ្លឹមសារមេរៀនតាមបែបបទ និងធ្វើឱ្យងាយយល់ សម្បទានេះ ជាសមត្ថភាពដឹកនាំមេរៀន និងពញ្ញាក់សកម្មភាពចិត្តរបស់សិស្សឱ្យធ្វើសកម្មភាព ។

• សម្បទាផ្នែកចំណេះដឹងទូទៅ ដើម្បីបង្កើតចំណេះដឹងរបស់ខ្លួន គ្រូត្រូវឆ្លៀតពេលសិក្សាវិជ្ជាថ្មីៗថែមទៀត គឺស្គាល់វប្បធម៌ អរិយធម៌ ជំនឿ សាសនា ក្នុងបណ្ដាប្រទេសផ្សេងៗលើពិភពលោក ចេះតាមដានព័ត៌មានវិទ្យាសាស្ត្រ និងព្រឹត្តិការណ៍ផ្សេងៗ ។

**ខ. សម្បទាក្នុងការអប់រំ**

ដើម្បីក្លាយជាអ្នកអប់រំដ៏ស្ទាត់ជំនាញ និងមានភាពទន់ភ្លន់ គឺត្រូវមាន ៖

• សម្បទាក្នុងការស្គាល់សិស្ស គឺជាសមត្ថភាពយល់ដឹងលក្ខណៈចិត្តរបស់សិស្ស ពិសេសយល់ដឹងច្បាស់អំពីបុគ្គលិកលក្ខណៈ ។ ដូចនេះ ត្រូវរិះរកវិធីអប់រំបុគ្គលិកលក្ខណៈរបស់សិស្សដូចជា អប់រំឫកពា អត្តចរិត អាកប្បកិរិយា ចិត្តរំភើប ទំនោរ និងចំណង់ ។

• សម្បទាក្នុងការបំប្លែងសញ្ចេតនា គឺជាសកម្មភាពទាក់ទាញសញ្ចេតនា និងឆន្ទៈសិស្សឱ្យមានទំនុកចិត្តលើខ្លួនឯង និងការទទួលខុសត្រូវ ។

• សម្បទាក្នុងទំនាក់ទំនង គឺជាសកម្មភាព ឬ ការប៉ិនប្រសប់ក្នុងការរិះរកល្បិច បង្កើតទំនាក់ទំនងជិតស្និទ្ធរវាងគ្រូ និងសិស្ស ។

• មានរូបារម្មណ៍គរុកោសល្យ គឺត្រូវមានរូបតំណាងនៃអនាគតបុគ្គលិកលក្ខណៈសិស្សម្នាក់ៗជិតជាប់នៅក្នុងមនសិការ ។ និយាយរួម គ្រូដែលប្រកបដោយសម្បទាគរុកោសល្យ គឺអ្នកចេះប្រមើលឃើញរូបភាព និងទម្រង់នៃបុគ្គលិកលក្ខណៈរបស់សិស្សមុននឹងដាក់វិធានការអប់រំ ។ ក្នុងករណីនេះ គ្រូត្រូវ ៖

- ក្ដាប់ឱ្យបាននូវទិសដៅអប់រំ
- យល់ឱ្យបានច្បាស់នូវគោលដៅអប់រំ និងរបៀបអនុវត្ត
- ចេះទ្រឹស្ដីគរុកោសល្យ ដើម្បីងាយស្រួលក្នុងការជ្រើសរើសវិធីក្នុងការអប់រំ ។

**គ. សម្បទាក្នុងការដឹកនាំ**

គឺជាសមត្ថភាពក្នុងការដឹកនាំសិស្សឱ្យចេះយកចំណេះដឹងទៅអនុវត្តនិងចេះធ្វើសកម្មភាពដោយខ្លួនឯង។សមត្ថភាពដឹកនាំសិស្សឱ្យចេះធ្វើការងារជាក្រុម និងមានការងារឯកភាពគ្នា ។

**២. វិក្រឹតការសម្បទាគរុកោសល្យ**

សម្បទាគរុកោសល្យរីកលូតលាស់ទៅតាមច្បាប់នៃការបណ្ដុះបណ្ដាល និងរីកចម្រើននៃសម្បទា។ ដើម្បីបណ្ដុះបណ្ដាលសម្បទាគរុកោសល្យ គ្រូត្រូវធ្វើការយ៉ាងសកម្មជាប់ជានិច្ច តាមរយៈសកម្មភាពគរុកោសល្យ ។

កត្តាដែលជំរុញការបណ្ដុះបណ្ដាល និងការអភិវឌ្ឍគរុកោសល្យ គឺវិក្រិតការ ក្នុងនោះមានការសិក្សាទ្រឹស្ដី ការហ្វឹកហ្វឺន និងអនុវត្តជាក់ស្ដែងក្នុងសង្គម ។ វិក្រិតការ ស្វ័យសិក្សា និងស្វ័យហ្វឹកហ្វឺនមានអត្ថន័យសំខាន់ណាស់ ចាប់ពីពេលដែលគេប្រកបវិជ្ជាជីវៈគ្រូបង្រៀនរហូតជាប់ជានិច្ច ។

សម្បទាគរុកោសល្យនឹងកើតមានតែក្នុងករណីណា ដែលយើងផ្សារភ្ជាប់លំនាំបណ្ដុះបណ្ដាល និងវិក្រឹតការទៅនឹងលំនាំស្វ័យហ្វឹកហ្វឺន និងស្វ័យសិក្សា ។ ក្នុងករណីនេះគរុសិស្សត្រូវសម្រេចឱ្យបានតាមកម្មវិធីបណ្ដុះបណ្ដាល ដែលកំណត់ដោយសាលាគរុកោសល្យនិងក្រសួងអប់រំ ដោយប្រែក្លាយទ្រឹស្ដីឱ្យទៅជាសកម្មភាពជាក់ស្ដែង ។

នៅពេលដែលយើងក្លាយទៅជាគ្រូ យើងត្រូវសម្រេចឱ្យបានល្អនូវកម្មវិធីវិក្រឹតការ ដែលសមស្របទៅនឹងពេលវេលារបស់ក្រសួងបានកំណត់ ។ ប៉ុន្តែបញ្ហាសំខាន់ គឺស្វ័យសិក្សា និងស្វ័យវិក្រឹតការ ។ ខ្លឹមសារស្វ័យសិក្សានិងស្វ័យវិក្រឹតការត្រូវផ្អែកលើតម្រូវការនៃសកម្មភាពចិត្តគរុកោលស្យ ។

**ឯកសារនាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ**

# មាតាបិតា ពុំមែនជាតុលាការ ពុំមែនជាឆ្មាំគុក តែជាអ្នកនាំផ្លូវសម្រាប់បុត្រធីតា(ត)

**សម្ដីល្អគួរប្រព្រឹត្ត សម្ដីអគតិនាំមកនូវក្ដីអាស្រូវ**!

ដើម្បីបញ្ចៀសភាពវង្វេងគ្រោះនេះ តើគួរធ្វើយ៉ាងណា ?

គួរកុំបដិសេធន៍ ឬកុំគេចវេះពីការប្រើសម្ដី អហិង្សា ចំពោះបុត្រធីតា ។ ក្នុងឬក្រោយពេលធ្វើសង្គ្រាមពាក្យសម្ដីដែលជាជម្លោះពាក្យសម្ដីទៅលើកូន តើអ្នកធ្លាប់ទទួលបានការ តបតយ៉ាងព្រហើនកោងកាចរបស់កូនមកលើយើងវិញទេ? ឬ ក៏កូនបែរជាមានភាពភ័យខ្លាច ឬមិងមាំង ។ តើហេតុអ្វីបានជាដូច្នេះ? អ្នកមានចម្ងល់ឬទេ នៅពេលដែលអ្នកជួបវិបត្តិនេះកើតឡើង? ការធ្វើអំពើហិង្សាលើកូន ប្រៀបដូចអ្នក***គប់ដុំថ្មទៅជញ្ជាំង គប់ខ្លាំងប៉ុណ្ណា ខ្ទាតមកវិញខ្លាំងប៉ុណ្ណោះដែរ !***

**មិងមាំង** កិ. វិ. ឬ គុ. ដែលងេងងោងស្រឡាំងកាំងស្ទាក់ស្ទើរអារម្មណ៍មិនជាក់លាក់ៈ ឈរមិងមាំង ; គំនិតមិងមាំង (ម.ព មមិងមមាំងទៀតផង)។ *(វចនានុក្រមខ្មែររបស់សម្ដេចសង្ឃរាជ ជួន ណាត បោះពុម្ពចម្លងឆ្នាំ ១៩៨១ ដោយអ្នកស្រីយ៉ាម៉ាដាបូផាណា ទំព័រ ៨៨៧)*។

ឪពុកម្ដាយគ្រប់រូបគឺគ្មាននរណាម្នាក់ចង់បានប្រតិកម្មជូរចត់ ឬចង់ឱ្យកូនមានទង្វើអាក្រក់ដូចនេះឡើយ។ ពីព្រោះអ្វី ?

- អ្នកត្រូវឈឺចាប់ ! អ្នកត្រូវខ្មាស់កូន ដោយតម្លៃការគ្រប់គ្រងឋានៈជាម្ដាយឪពុកត្រូវអន់ថយ ឬបាត់អំណាច ។ យើងប្រើកំហឹងដើម្បីបង្ហាញសក្ដានុពលនៃអំណាច តែអំណាចយើងគ្មានឥទ្ធិពល គឺបរាជ័យ ។ នៅពេលនោះយើងបានឃើញជាក់ប្រាកដថា ការធ្វើសង្គ្រាមសម្ដីពុំមែនជាតួនាទីរបស់ម្ដាយឪពុក។ ពីព្រោះអំពើបែបនេះ វាបង្ហាញចេញកាន់តែច្បាស់នូវសមត្ថភាពទន់ខ្សោយ ឬ អសមត្ថភាពរបស់អ្នក ដែលជាសេចក្ដីអាម៉ាស់តែប៉ុណ្ណោះ ។

តើតួនាទីម្ដាយឪពុកចំពោះបុត្រធីតាយ៉ាងណាដែលពិតប្រាកដ ។ ក្ដីសង្ឃឹមរបស់បុត្រធីតាគឺ ផ្ញើទៅលើម្ដាយឪពុកនេះហើយ ។ ម្ដាយឪពុកជាប្រភពកក់ក្ដៅផ្ដល់ឱ្យកូនមិនចេះរីងស្ងួត ដែលកូនត្រូវការជាងនរណាៗផ្ដល់ឱ្យទាំងអស់ តើពិតមែន ឬទេ? ។ ការប្រើពាក្យសម្ដីហិង្សាជាអចិន្ត្រៃយ៍ គឺមិនទទួលបានផលល្អ ដែលយើងជាមាតាបិតាគួរគប្បីត្រូវជៀសវាង។

**ហិង្សា** (ន.) (សំ.)(បា)(ហិង-ស)(ហឹសា) ការបៀតបៀន, ការពាធា, ការធ្វើអាក្រក់រកគ្នា,មនុស្សត្រូវកុំឱ្យមានហិង្សារកគ្នា។ *(វចនានុក្រមខ្មែររបស់សម្ដេចសង្ឃរាជ ជួន ណាត បោះពុម្ពចម្លងឆ្នាំ ១៩៨១ ដោយអ្នកស្រីយ៉ាម៉ាដាបូផាណា ទំព័រ ១៥១៦*។

តើដូចម្ដេចដែលជាសម្ដីប្រពៃ និងឱ្យមានកម្រិតទម្ងន់សម្រាប់ប្រាស្រ័យទាក់ទាញជាមួយបុត្រធីតា ?

ជាការពិតមែនហើយ ការចៀសវាងប្រើសម្ដី **ហិង្សា** គឺមានតែសម្ដី **អហិង្សា** ប៉ុណ្ណោះគ្មានជម្រើសណាក្រៅពីនេះឡើយសម្រាប់អ្នកជាមាតាបិតា ។

ចំណែកការស្ដីប្រដៅ ឬការទូន្មាន វាពុំអាចខ្វះបាននូវភាពហិង្សាខ្លះៗតាមរយៈឥរិយាបថ តែគ្មានពាក្យប្រមាថ។

ទស្សនៈស្វែងយល់អំពីផលវិបាកនៃសម្ដីហិង្សា ការជេរប្រមាថខាងលើ បង្ហាញពីផលអវិជ្ជមាន ដែលយើងធ្លាប់ជួបប្រទះ និងមិនត្រូវការឱ្យកើតមានក្នុងក្រុមគ្រួសារថ្លៃថ្នូរ ឆ្ពោះទៅកាន់លក្ខណៈស៊ីវិល័យទៀតផង ។ ប្រសិនបើកើតមានហិង្សាហើយ តើយើងគួរជ្រើសរើសវិធីប្រតិបត្តិបែបណា ដើម្បីឱ្យមានគុណប្រយោជន៍សម្រាប់លោកអ្នកជាមាតាបិតា ក្នុងការអប់រំបុត្រធីតា? ឧបមាថាកូនលោកអ្នកបានប្រព្រឹត្តខុសឆ្គងមិនតាមគន្លងដំបូន្មាន ។ ខណៈនោះអ្នកមានការមិនសប្បាយចិត្ត ដែលចាំបាច់ណាស់ត្រូវតែស្ដីប្រដៅ និងកើតទោសៈទៀតផង ។ តើធ្វើយ៉ាងណា ដើម្បីចៀសចេញផុតពីពាក្យសម្ដីជេរប្រមាថ ? សូមគិតថា **ការជេរប្រមាថ ពុំមែនជាការទូន្មាន ឬការស្ដីប្រដៅនោះឡើយ** ។ ប្រសិនបើលោកអ្នកយល់

ខុស និងប្រព្រឹត្តច្រឡំ វាជាកម្លាំងជំរុញឱ្យកូនដុះដាលចរិតឆេវឆាវ ជាអ្នកទុទិដ្ឋិនិយម និងធ្លាក់ចូលក្នុងគន្លងជីវិតព្រៃផ្សៃតែប៉ុណ្ណោះ ។ ឯការទូន្មាន ឬការស្តីប្រដៅ វាជាខ្លឹមសារបញ្ញត្តិមួយដែលត្រូវតែមានប្រសិទ្ធភាព ។ តើមានអ្វីដែលជួយឱ្យមានប្រសិទ្ធភាព ?

នៅពេលនោះអ្នកត្រូវធ្វើអ្វី ? ជំហានដំបូងគួរតែស្តាប់កូននិយាយ(មានន័យថាយើងបានផ្តល់សេរីភាពឱ្យកូនក្នុងការនិយាយ ឬ លើកកម្ពស់សិទ្ធិរបស់មនុស្ស)។ បន្ទាប់ពីបានស្តាប់ហើយ យើងពិចារណាបន្ថែម តើធ្វើអ្វីដើម្បីឱ្យកូនដឹងពីទុក្ខកង្វល់របស់យើង ? យើងក៏ដូចកូនសុទ្ធតែពុំអាចដឹងសព្វគ្រប់នូវរឿងហេតុក្នុងបេះដូងផងគ្នា (មិនមែនជាព្រះទ្រង់ញាណ) តែមាតាបិតាអាចយល់ពីការខុសឆ្គងរបស់កូន ។ តើធ្វើដូចម្តេចដើម្បីបានដឹងទាំងអស់គ្នា មានតែមួយគត់ គឺប្រាប់គ្នាទៅវិញទៅមក ។ នេះជាភាពកក់ក្តៅមួយដែលកូនទទួលបានពីលោកអ្នក។ ប្រសិនបើកូនលោកអ្នកបានស្តាប់ បានដឹងពីការពិតនៃទុក្ខកង្វល់របស់អ្នក កូនអាចមានទឹកមុខស្រពាប់ស្រពោន ជួនកាលអាចហូរទឹកភ្នែកដោយក្តីអាណិតចំពោះលោកអ្នក ។ សូមរំឭកនឹកពីអតីតកាលរបស់អ្នកកាលនៅជាកូនវិញម្តង តើធ្លាប់ទទួល និងមានប្រតិកម្មអ្វីខ្លះជារបស់អ្នក ។ សូមចងចាំថា កុំអាងអំណាចជាមាតាបិតា និយាយឱ្យតែកូនស្តាប់ និងមិនស្តាប់កូននិយាយវិញនោះឱ្យសោះ។ ការមិនស្តាប់កូននិយាយប្រាប់ ឬមិនទុកឱកាសឱ្យកូននិយាយ ចូរកុំបីមាន ។ ទោះបីលោកអ្នកប្រើសំដីផ្អែមល្ហែម ឬដាក់ទោសទណ្ឌបែបណាក៏ដោយ ប្រសិនបើមិនស្តាប់កូននិយាយ នុះពិតជាមានផលអវិជ្ជមានយ៉ាងជាក់ប្រាកដ។ លោកអ្នកនឹងធ្លាក់ក្នុងស្ថានភាពដែលថាមាតាបិតា មានលក្ខណៈមិនពេញលេញចំពោះបុត្រធីតា ពីព្រោះថាទង្វើបែបនេះ បាននាំកូនលោកអ្នកឱ្យបាត់បង់នូវភាពជំនឿលើខ្លួនឯងហើយ។ កូនលោកអ្នកគ្មានសតិរឹងប៉ឹង រញ្ជរា មួហ្មង អស់សង្ឃឹមរវើរវាយហួសហេតុ (ឡប់ៗ) រង់ចាំតែការសម្រេចពីអ្នកដទៃ ឬអាចបែរជាមានភាពព្រៃផ្សៃផ្សេងៗទៀតក៏ថាបាន។ល។ វាក៏អាចជាមរតកបន្តវេនសម្រាប់អ្នកជំនាន់ក្រោយ ប្រសិនមិនទទួលបានការអប់រំចំណេះដឹង វប្បធម៌ពីសង្គម ឬពីសាសនា ឬពីសាលារៀន ។ យ៉ាងណាមិញបើកូនលោកអ្នកធ្លាក់ក្នុងស្ថានភាពបែបនេះ សូមកុំស្តីថា កូននេះអន់ណាស់ គ្មានកំណើត ឬចង្រៃក្នុងគ្រួសារឱ្យសោះ ។

ការពិចារណារកហេតុផលជាក់លាក់បានហើយ គប្បីលោកអ្នកណែនាំតម្រង់ទិស បញ្ជាក់ច្បាស់ពីកំហុស ដែលត្រូវឱ្យកូនទទួលស្គាល់ ដោយរង់ចាំស្តាប់សម្តីឆ្លើយតបពីកូនថា អំពើនេះពិតជាខុសមែន និងចៀសវាង ។ ពន្យល់ហើយពន្យល់ទៀត ដោយសម្តីធូន់ស្រាលតាមការដែលអាចធ្វើទៅបានចម្លើយ ឬអាចគ្មានចម្លើយ តែឥរិយាបថ និងសកម្មភាពលើសពីនេះទៀត លោកអ្នកត្រូវស្និតល្អិត ស្និទ្ធស្នាល និងប្រព្រឹត្តនូវភាពជាគំរូល្អ ឱ្យកូនលោកអ្នកបានឃើញ និងអាចធ្វើតាម ។ ឧទាហរណ៍: ព្យាយាមនាំកូនធ្វើការងារផ្ទះ, អានសៀវភៅ. នាំកូនទៅសាលារៀន-ទទួលយកមកផ្ទះវិញ ឬដើរជាប់ជាមួយ (កូននៅកុមារភាព)។ល។ កាលបើឃើញកូនខុស កុំប្រានកូនឱ្យឃ្លាតឆ្ងាយពីខ្លួន កុំខ្លាចថោកខ្លួនព្រោះកូន ។ ការឃ្លាតឆ្ងាយពីកូនប៉ុនណា កូនក៏ឃ្លាតឆ្ងាយពីយើងប៉ុណ្ណោះដែរ (ភាពមិនរវីរវល់/ការមិនយកចិត្តទុកដាក់)។ យើងជិតស្និទ្ធកូនប៉ុនណា ឯកូនវិញក៏ជិតស្និទ្ធយើងវិញប៉ុណ្ណោះដែរ ។ ការឃ្លាតឆ្ងាយរបស់យើង ក្នុងករណីកូនខូច អាចថាខ្លាចខ្លួនអាម៉ាស់ ចង់ល្អតែឯង គេចវេះពីការពិតនៃការទទួលខុសត្រូវ និងអសមត្ថភាពអប់រំរបស់ខ្លួន ។ អំពើបែបនេះ យើងមិនបានអ្វីទាំងអស់ និងកាន់តែធ្វើឱ្យយើងទទួលរងនូវភាពខ្លោចផ្សា ។ មិនតែប៉ុណ្ណោះបើញាតិគេដឹងការពិតវិញ កាន់តែទទួលក្តីអាម៉ាស់ធ្ងន់ធ្ងរបំផុត ។ មនុស្សដែលមានគុណតម្លៃ គឺជាមនុស្សដែលត្រូវក៏ទទួល ខុសក៏ទទួល (ភាពទទួលខុសត្រូវ) ។ មនុស្សបែបនេះ ជាមនុស្សដែលញាតិគោរពស្រឡាញ់សង្គមជាតិត្រូវការបំផុត បើជាមាតាបិតាវិញ គឺជាម្លប់ដ៏សុខក្សេមក្សាន្តនិងដ៏កក់ក្តៅបំផុតរបស់បុត្រធីតា ។ គួរប្រានកូនចេញពីផ្ទះដែរឬទេ ?

(នៅមានត)

**លោក ផេង កែន**

**ប្រធានការិយាល័យរដ្ឋបាល មន្ទីរអ.យ.កខេត្តកំពង់ឆ្នាំង**

✎📖✍




# អភិវឌ្ឍរបៀបធ្វើការជាក្រុម

**១. ដូចម្ដេចដែលហៅថាធ្វើការជាក្រុម** (What is working as a team)

ជាការគួរឱ្យស្ដាយដែលនៅសាលារៀនភាគច្រើននាយកសាលានិងបុគ្គលិកធ្វើការបែកគ្នា (separate)មិនទាក់ទងគ្នា (independent)។ នាយកសាលាចំណាយពេលធ្វើការងារផ្ទាល់ខ្លួនដូចជា ធ្វើរបាយការណ៍ ចូលរួមប្រជុំជាមួយថ្នាក់លើ ជូនព័ត៌មានទៅថ្នាក់លើ ។ ពួកគាត់មានពេលតិចតួចនិងនិយាយផ្ទាល់ជាមួយបុគ្គលិក ហើយជាធម្មតា ការប្រាស្រ័យទាក់ទងជាមួយមន្ត្រីក្រោមឱវាទច្រើនធ្វើតាមនាយករង ឬលេខាសាលា។ គាត់តែងនិយាយថាៈ «**ខ្ញុំរវល់ណាស់**» ចំណែកមន្ត្រីនានារបស់សាលាវិញក៏តែងធ្វើការមិនទាក់ទងគ្នា ទាំងរវាងមន្ត្រីដូចគ្នាក៏ដូចជាមួយនាយករបស់ខ្លួន។ លោកគ្រូ អ្នកគ្រូមួយចំនួនតែងពោលថា « ម៉ោងធ្វើការរបស់ខ្ញុំគឺដប់ប្រាំម៉ោងក្នុងមួយសប្ដាហ៍ ។ *ខ្ញុំពុំមានពេលថែមទៀតសម្រាប់ធ្វើការជាមួយគ្រូដទៃទៀតទេ។ វាជាពេលផ្ទាល់ខ្លួនរបស់ខ្ញុំ* »។ របៀបធ្វើការបែបនេះមិនមែនរបៀបធ្វើការជាក្រុម (Team work)ទេ ប៉ុន្តែគ្រាន់តែជាក្រុមនៃបុគ្គល (group of individuals)តែប៉ុណ្ណោះ ។ អ្វីដែលខុសពីរបៀបធ្វើការជាក្រុមនោះគឺក្រុមនៃបុគ្គលពុំមានភារកិច្ចរួមរបស់ក្រុម(group tasks) សមាជិកម្នាក់ប្រកែកតវ៉ាត្អូញត្អែរ និងទិទៀនគ្នា។ ពួកគេផ្ដោតអារម្មណ៍ជាទូទៅតែលើផលប្រយោជន៍ផ្ទាល់ខ្លួន ហើយលទ្ធផលនាំទៅរកហាយនៈសម្រាប់ក្រុម ។ វាមិនខុសពីក្រុមកីឡាបាល់ទាត់មួយដែលកីឡាករ ពូកែលេងតែម្នាក់ឯងដើម្បីបង្ហាញនូវភាពអស្ចារ្យរបស់ខ្លួន ឬក្នុងល្បែងបៀមួយដែលគេឱ្យតម្លៃតែលើសន្លឹកធំដូចជា អាត់ កញ្ចាស់ ក្រមុំ ។ របៀបលេងបែបនេះមិនគួរឱ្យចាប់អារម្មណ៍ ក្រុមមិនរីកចម្រើន ហើយក៏មិនអាចឈានទៅរកជ័យជំនះបានដែរ ។

របៀបធ្វើការជាក្រុម (team work) ខុសគ្នាពីក្រុមនៃបុគ្គល(group of individuals) ។ ក្នុងក្រុម (team) សមាជិកក្រុមទាំងអស់មានគំនិតឯកភាពគ្នាដើម្បីធ្វើឱ្យសម្រេចនូវ ភារកិច្ចរួម (common task)របស់ក្រុមក្នុងក្រុមកីឡាបាល់ទាត់ ភារកិច្ចរួមរបស់គេ គឺស្វែងរកជ័យជំនះឱ្យក្រុម ។ កីឡាករម្នាក់ៗលេងដោយសហការគ្នាអាស្រ័យទាក់ទងគ្នាទៅវិញទៅមក មានទំនាក់ទំនងជិតស្និទ្ធជាមួយគ្នា ស្ដាប់គ្នានិងស្ដាប់គ្រូបង្វឹក។ *ធ្វើការរបៀបជាក្រុម* (working as a team)គឺយ៉ាងនេះឯង។ សមាជិកម្នាក់ៗសហការគ្នា យ៉ាងស្អិតរមួតដើម្បីឈានទៅសម្រេចភារកិច្ចរបស់ក្រុម ។ សាលារៀនក៏ដូចជាក្រុមបាល់ទាត់ដែរ ។ បុគ្គលិកម្នាក់ៗរបស់សាលាត្រូវតែជាសមាជិកក្រុម (team member)ហើយនាយកសាលាជាគ្រូបង្វឹក។ ដើម្បីសម្រេចបានដោយជោគជ័យនូវទិសដៅរបស់សាលារៀន បុគ្គលិកម្នាក់ៗត្រូវកសាងនូវទំនាក់ទំនងជិតស្និទ្ធរវាងគ្នានឹងគ្នា ធ្វើការប្រាស្រ័យទាក់ទងគ្នាឱ្យបានល្អ និងរំលែកគំនិតនិងបំណិនរវាងគ្នានឹងគ្នា ។ ក្នុងក្រុមសមាជិកក្រុមម្នាក់ៗ មានភាពសំខាន់របស់ខ្លួន ។ តម្លៃតែមួយនិងជាសារវន្តរបស់គេគឺ *ជោគជ័យរបស់ក្រុម*។

**២. តើត្រូវកសាងក្រុមដោយវិធីណា** (How to build Team Work)

ធ្វើការតាមបែបជាក្រុម(Team work )ល្អណាស់ប៉ុន្តែការកសាងជាក្រុមការងារជាការលំបាកពិសេសក្នុងស្ថានភាពនៃសាលារៀនរបស់យើងបច្ចុប្បន្ននេះ ។ ការបង្កើតក្នុងសាលារៀននូវវប្បធម៌នៃទំនាក់ទំនងបែបសហការ អន្តរទំនាក់ទំនងរវាងបុគ្គលិកនិងបុគ្គលិក បុគ្គលិកនិងនាយក ពិតជាមិនមែនជាការងាយស្រួលទេ ប៉ុន្តែយើងគ្មានជម្រើស ។ វាជាលក្ខខ័ណ្ឌចាំបាច់សម្រាប់ការផ្តល់នូវការអប់រំមួយប្រកបដោយប្រសិទ្ធភាពជូនកុមារ ។ នាយកសាលាត្រូវទទួលស្គាល់ថាខ្លួនគាត់គប្បីជាចលករ(stimulus)នៃការធ្វើការជាក្រុមក្នុងសាលា ។ ក្នុងលំនាំនេះ គាត់ត្រូវតែសម្តែងជាតួនាទីគន្លឹះនៃអ្នកដឹកនាំក្រុមដ៏ល្អ ។

ក្នុងឋានៈជាអ្នកដឹកនាំក្រុម នាយកសាលាត្រូវតែបង្ហាញគំរូនៃការធ្វើការជាក្រុម។គាត់គប្បីស្វែងរកឱកាសនិយាយជាមួយនាយករងរបស់គាត់អំពីការកែលម្អសាលារៀន ។ គាត់ត្រូវតែបង្ហាញខ្លួនជាប់ជានិច្ចក្នុងសាលា ជុំវិញសាលាក្នុងទីធ្លា ហើយធ្វើការបែបសហការជាមួយគ្រូបង្រៀន។គាត់គួរតែរៀបចំការប្រជុំឱ្យបានទៀងទាត់ជាមួយបុគ្គលិកនិងស្តាប់យោបល់របស់ពួកគេ ចូលរួមក្នុងការប្រជុំដែលត្រូវបានចាត់ចែងឡើងដោយបុគ្គលិក។ល។ប្រការដែលគួរឱ្យស្តាយគឺ នាយកសាលាពិតជានឹងពោល*ថា គាត់រវល់ណាស់ មិនមានពេលធ្វើគ្រប់ការងារទាំងនេះទេ* ។ ប៉ុន្តែនាយកសាលាត្រូវយល់ថា ជាអ្នកដឹកនាំក្រុមគាត់ត្រូវតែធ្វើការងារទាំងអស់នេះ ។ គាត់ត្រូវតែមានភាពទន់ភ្លន់ ចេះរំលែកពេលវេលា និងចេះធ្វើប្រតិភូកម្មនូវភារកិច្ចជាមួយបុគ្គលិករបស់ខ្លួន ។

ដើម្បីលើកកម្ពស់ការចូលរួមសហប្រតិបត្តិការក្នុងសាលារៀន នាយកសាលាត្រូវតែបង្ហាញនូវ ទំនុកចិត្តចំពោះបុគ្គលិកទាំងអស់និងគ្រូបង្រៀន ។ សូមផ្តល់នូវទំនុកចិត្តលើមន្ត្រីទាំងអស់ដោយមិនមានការរើសអើង មិនមែនទុកចិត្តត្រឹមអាត់ កញ្ចាស់ និងក្រមុំទេ ។ ប៉ុន្តែត្រូវទុកចិត្តផងដែរចំពោះពួក ពីរគ្រាប់ បីគ្រាប់ និងបួនគ្រាប់ ។ *ប្រសិនបើយើងទុកចិត្តគេ គេនឹងទុកចិត្តយើង !*

ទៅព្រមនឹងការបង្ហាញនូវទំនុកចិត្តចំពោះបុគ្គលិក នាយកសាលាត្រូវតែស្មោះត្រង់ជាមួយបុគ្គលិករបស់ខ្លួនដោយធ្វើការបែបបើកចំហ និងប្រកបដោយតម្លាភាព ។ មានទំនុកចិត្តលើបុគ្គលិក និងមានតម្លាភាពជាមួយពួកគេនឹងធ្វើឱ្យគេមានទំនុកចិត្តលើខ្លួនឯងផ្ទាល់ ហើយប្រការនេះក៏ជួយលើកកម្ពស់ការចូលរួមនិងការសហការរបស់ពួកគេក្នុងការងារសាលាទៀតផង ។

លក្ខខណ្ឌមួយទៀតសម្រាប់ធានាឱ្យបានរឹងមាំនូវក្រុមការងារល្អក្នុងសាលា(a good school team)គឺត្រូវធ្វើឱ្យគ្រូបង្រៀននិងបុគ្គលិកទាំងអស់ដឹងថា ពួកគេត្រូវបានរំពឹងទុកថា នឹងធ្វើការតាមបែបជាក្រុម ។ ប្រការនេះនាយកសាលាគប្បីពន្យល់ពួកគេនូវមូលហេតុ ជាសារវន្តដែលតម្រូវឱ្យគេធ្វើការតាមបែបជាក្រុម ព្រមទាំងបង្ហាញពួកគេនូវលក្ខណៈវិនិច្ឆ័យសម្រាប់ឱ្យសមាជិកម្នាក់ៗក្លាយជាសមាជិកក្រុមដ៏ល្អ ។ (នៅមានត)

**លោក អ៊ុំ សារីក់**

## *អំពើអាក្រក់ឆក់ចិត្តឱ្យងាយធ្វើ*

| | | |
|---|---|---|
| *សាធុជន* | *ស្រឡាញ់បុណ្យ* | *ងាយធ្វើបុណ្យ* |
| *ឯទុរជន* | *ចិត្តទម្រន់* | *ធ្វើពុំកើត* |
| *បើបាបវិញ* | *គេងាយធ្វើ* | *ពុំញញើត* |
| *អ្នកប្រាជ្ញឆើត* | *ធ្វើពុំកើត* | *ព្រោះខ្ពើមបាប ។* |

*វត្តឧណ្ណាលោម ក្រុងភ្នំពេញថ្ងៃពុធ ទី២៤កក្កដា២៥១២/១៩៦៨*

*សម្តេចព្រះសង្ឃរាជជួនណាតជោតញ្ញាណោ*

# វេយ្យាករណ៍

## របៀបប្រើពាក្យ(ត)

ពាក្យ **នានា** ជានិបាតសព្ទ គឺជាពាក្យបាលី និង សំស្រ្កឹតសុទ្ធសាធ បានសេចក្ដីថា **ផ្សេងៗ ទីទៃៗ** ប្រើដាក់នៅខាងដើមពាក្យដែលហៅថានាមសព្ទ តាមក្បួនវេយ្យាករណ៍បាលី ។

ឧ.នានាជាតិ -នានានុក្រម - ពួកអ្នកនានាប្រទេស - មនុស្សនានាប្រទេស - មនុស្សនានា សំវាសនានាជាតក... ។

តែសព្វថ្ងៃយើងយកពាក្យនេះមកនិយមប្រើជាពាក្យសាមញ្ញ ដាក់រៀងនៅខាងចុងនាមសព្ទវិញក៏មាន « ដើម្បីជំនួសពាក្យ ផ្សេងៗ ទីទៃៗ » ។

ឧ. ប្រទេសនានា - អង្គទូតនានា - អន្តរជាតិនានា - បក្សីនានា - ព្រឹក្សានានា - ...។

តែចំពោះការសរសេរវិញ មិនត្រូវសរសេរលេខទោ « ៗ » ជំនួសពាក្យខាងចុងទេ ។

ឧ. គុណចំនួននាៗ នឹង ៥ ។

- អង្គទូតនាៗបានទៅទស្សនាប្រាសាទអង្គវត្ត ហើយមានសេចក្ដីស្ងើចសរសើរដល់ស្នាដៃរបស់បុព្វបុរសខ្មែរជំនាន់នោះ ។

ម្យ៉ាងទៀតពាក្យ « **នានា** » នេះច្រើនប្រើក្នុងកំណាព្យកាព្យឃ្លោង ដែលរាប់ឈ្មោះចំនួនប្រជុំវត្ថុអ្វីមួយមិនរ៉ាយរ៉ាប់ឈ្មោះវត្ថុនោះដោយច្រើនពេក ក៏ដាក់ពាក្យ « **នានា** » នេះមកជំនួសវិញ។

ឧ. ស្ដេចទ្រង់យាត្រាតាមដងព្រៃ ព្រះនេត្រវំពៃទតព្រឹក្សា នូវអស់បក្សីផងនានា ក្សត្រាអ្នកនឹកដល់ក្សត្រី.......។

កំណត់សម្គាល់៖ ក្នុងការប្រើពាក្យ« នានា » មិនត្រូវប្រើលេខទោ ដាក់ជំនួសឱ្យទៅជា**នាៗ -នាមៗ** ឡើយ ។

### របៀបប្រើពាក្យ ក៏ និង ក

**ក៏** កាលណាគេដាក់លេខអាស្ដា (៏) ពីលើពាក្យនោះជានិបាតត្រូវអាន សំឡេង កញ្ចក់ខ្លី កន្លះមាត្រា ដូចពាក្យថាៈ ក៏ដោយ ក៏បានក៏ទៅ ...។ ប៉ុន្តែបើ ក ក្នុង ពាក្យអញ្ចស នោះគ្មានលេខអស្ដាទេដូចពាក្យថាៈ កកាយ កកេរ ...

លើកលែងតែពាក្យ ករ មួយម៉ាត់ជាភាសាបាលីប្រែថា ដៃ ដូចពាក្យថា លើក ករ ប្រណម្យ ។

### ពាក្យខ្លះដែលត្រូវដាក់ស្រះ (ិ)

ពាក្យទាំងឡាយដែលគេត្រូវដាក់ស្រះ (ិ) គឺពាក្យនោះច្រើនតែមានសព្ទ ដូចជា ការប្រព្រឹត្តសេចក្ដីអនុញ្ញាតច្បាប់បញ្ញត្តិ សេចក្ដីបរិសុទ្ធ ។ ប៉ុន្តែបើពាក្យទាំងនោះទៅជាកិរិយាសព្ទវិញគេពុំត្រូវដាក់ស្រះ (ិ) ទេ ដូចជា លោកគ្រូបានអនុញ្ញាតច្បាប់ មនុស្សនេះប្រព្រឹត្តត្រឹមត្រូវ ។ លើកលែងតែពាក្យ (ប្រតិបត្តិ) ចេញដែលគេត្រូវសរសេរមិនតាមប្រែប្រួល។

### ម្ដេចក៏សៅរ៍មាន ៍ រាំងរានៅខាងមុខ

«សៅរ៍» នេះមិនមែនជាពាក្យខ្មែរយើងទេ គឺជាពាក្យសំស្ក្រឹត ដែលជាឈ្មោះផ្កាយនព្វគ្រោះទី៧ឬជាឈ្មោះថ្ងៃទី៧នៃសប្ដាហ៍ ។ ដើម្បីកុំឱ្យបាត់សព្ទដើមនៃភាសា ហើយកុំឱ្យច្រឡំក្នុងការអានផងនោះ គេត្រូវសរសេរដាក់ទណ្ឌឃាតលើព្យញ្ជនៈ **រ** ដូច្នេះ ។ សញ្ញាទណ្ឌឃាត មានអំណាចចំពោះតែក្នុងពាក្យណាដែលយើងខ្ចីមកពីភាសាដទៃ ដូចជាភាសាបាលី ឬ សំស្រ្កឹតជាដើម ។ សញ្ញានេះសម្រាប់ប្រើឃាត់ព្យញ្ជនៈមិនឱ្យមានសំឡេង។

ពាក្យ « **សៅរ៍** » នេះមិនខុសគ្នាពីពាក្យ « **ទោសពៃរ៍** » ទេ ។ សៅរ៍ មកពីសំស្រ្កឹតថា **សៅ** ឬ **សៅរ៍** ។ **ពៃរ៍** ឬ មកពីសំស្រ្កឹតថា **វៃរ** ។

(នៅមានត)

**លោក ចែម ផាន**

✍📖✍

# សាលាធនធាន ជួយបង្កើនគុណភាពអប់រំនៅកម្ពុជា

## I.សេចក្តីផ្តើម

នៅក្នុងយុគសម័យសកលភាវូបនីយកម្ម និងបច្ចេកវិទ្យាព័ត៌មានចំណេះដឹងបានក្លាយជាដើមទុនដ៏សំខាន់បំផុតសម្រាប់សង្គមជាតិ និងជាកម្លាំងចលករ ដែលជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងធានាបាននូវនិរន្តភាពនៃជីវភាពរស់នៅប្រចាំថ្ងៃ។ក្នុងបរិបទនេះ ការអប់រំគឺជាវិស័យអាទិភាពមួយ ដែលរដ្ឋាភិបាលផ្តោតយកចិត្តលើការបណ្តុះបណ្តាលធនធានមនុស្សឱ្យសមស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា ព័ត៌មានវិទ្យានិងនិន្នាការនៃការអប់រំពិភពលោក។

ឆ្នាំ២០០៥ ក្រសួងអប់រំយុវជននិងកីឡា ក៏បានបង្កើតអគារធនធានតាមរយៈគម្រោងបង្កើនគុណភាពអប់រំ (Enhancing Education Quality Project (EEQP)ដោយផ្តោតទៅលើការពង្រឹងគុណភាពអប់រំវិទ្យាសាស្ត្រនៅកម្រិតមធ្យមសិក្សាចំនួន ៣៦ ដើម្បីជួយគាំទ្រដល់សាលាមធ្យមសិក្សាចំណេះទូទៅ។ ការបង្កើតអគារធនធាន និងសាលាបណ្តាញនេះឡើងក្នុងគោលបំណងពង្រឹងការគ្រប់គ្រងការធ្វើផែនការអភិវឌ្ឍសាលា ការលើកកម្ពស់សមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន ។ ការសិក្សានានាដែលជាបណ្តាញ ប៉ុន្តែផែនការនេះមិនទាន់បានសម្រេចជោគជ័យទាំងអស់នោះទេ ។ ម្យ៉ាងវិញទៀតអគារដែលបានកំពុងដំណើរការដល់បច្ចុប្បន្ននេះ គឺវិទ្យាល័យ ដែលមានអគារធនធានចំនួន ២៩ ជាទូទៅអាចមួយខេត្តមាន ០១ ឬ ០២ ហើយមិនទាន់បានល្អូនដូចគ្នាទាំងអស់ដែរ ដោយសារកង្វះខាតធនធាន គ្រូបង្រៀន ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធទឹក ភ្លើង ។ល។ ទាំងអស់នេះជាកត្តាដែលមិនអាចធានាបាននូវនិរន្តរភាព និងលទ្ធផលពីអគារធនធានបានទាំងស្រុងនោះឡើយ ។

ក្រសួងអប់រំយុវជន និង កីឡា តែងតែបានយកចិត្តទុកដាក់ការបណ្តុះបណ្តាលនូវអ្នកវិទ្យាសាស្ត្រវ័យក្មេង ដោយដាក់បញ្ចូលកម្មវិធីសិក្សាព័ត៌មានវិទ្យា ភាសាអង់គ្លេស ដែលជាមូលដ្ឋាននៃការស្រាវជ្រាវវិទ្យាសាស្ត្រ (អ.យ.ក.២០១០)។ លទ្ធភាពនេះនាំឱ្យមានកំណើនចំនួនសិស្សមធ្យមសិក្សាកាន់តែច្រើនឡើងៗចាប់អារម្មណ៍ និងសម្រេចចិត្តសិក្សា និងប្រឡងថ្នាក់វិទ្យាសាស្ត្រ ។ បច្ចុប្បន្ននេះ ក្រសួងអប់រំបានកសាងសាលាមធ្យមសិក្សាចំណេះទូទៅ ១៦៨៨ ក្នុងនោះអនុវិទ្យាល័យចំនួន១២៤៤(ឯកជនចំនួន៣៥)និងវិទ្យាល័យចំនួន៤៤៤(ឯកជនចំនួន៨៧) (របាយការណ៍អ.យ.ក.២០១៤)។ ជាមួយគ្នានេះដែរ វិទ្យាល័យធនធានចំនួន២៩កំពុងដំណើរការជាសកម្មភាពបង្រៀន និងរៀនដែលរួមមានបន្ទប់កុំព្យូទ័រ បន្ទប់ពិសោធផ្នែកវិទ្យាសាស្ត្រ បណ្ណាល័យ សាលប្រជុំ បន្ទប់សោតទស្សន៍ បណ្តាញទឹក បណ្តាញភ្លើង បន្ទប់គ្រូ និងសម្ភារៈបរិក្ខាជាច្រើនទៀត ដើម្បីអភិវឌ្ឍសមត្ថភាពសិក្សារបស់សិស្សមធ្យមសិក្សាចំណេះទូទៅលើមុខវិជ្ជាវិទ្យាសាស្ត្រដូចជា ៖ រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា ឈានទៅចាប់យកជំនាញឯកទេសនៅមហាវិទ្យាល័យ សាកលវិទ្យាល័យ និងគ្រឹះស្ថាននានាស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ២០៣០ គឺប្រែក្លាយពលករកម្ពុជាដែលប្រើកម្លាំងពលកម្មឱ្យទៅជាពលករបច្ចេកទេសសម្រាប់បម្រើទាំងក្នុងនិងក្រៅប្រទេស។

## II. លក្ខណៈទូទៅនៃអគារធនធាន

គម្រោងលើគុណភាពអប់រំ(Enhancing Education Quality Project)(EEQP)បានចាប់ផ្តើមនៅឆ្នាំ២០០៥។ ក្រសួងអប់រំយុវជន និងកីឡាក៏បានបង្កើតអគារធនធានតាមវិទ្យាល័យទូទាំងប្រទេសតាមគោលការណ៍ដែលបានកំណត់។ អគារធនធាន គឺដៅទៅលើអគារបានបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវន្ត (អគារសិក្សា សាលប្រជុំ បន្ទប់ពិសោធន៍ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ និងបន្ទប់គ្រូបង្រៀន) ហើយក្រសួងអប់រំយុវជន និងកីឡាក៏បានធ្វើសេចក្តីណែនាំមួយ លេខ ០៦ អ.យ.ក.សណ.ចុះថ្ងៃទី១៤មករា ២០១០ស្តីពីការប្រើប្រាស់ និងថែទាំអគារធនធាន។

សាលាមធ្យមសិក្សាធនធាននឹងចែកចាយនូវបទពិសោធន៍ក្នុងការប្រើធនធានទាំងអស់នោះដល់សាលាបណ្ដាញនានា។ សាលាមធ្យមសិក្សាធនធាននឹងជំរុញការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ចែករំលែកបទពិសោធន៍ក្នុងការបង្រៀន និងការរៀន ការគ្រប់គ្រងណែនាំកសាង និងអនុវត្តផែនការ អភិវឌ្ឍសាលារៀន និងអភិវឌ្ឍសមត្ថភាពគ្រូ ។ សាលាធនធាននឹងក្លាយជាសមាសភាគដ៏រឹងមាំមួយនៃយុទ្ធសាស្រ្តគន្លឹះរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលធ្វើឱ្យសាលាមធ្យមសិក្សាអភិវឌ្ឍតាមរយៈភាពជាអ្នកដឹកនាំនៃសាលាមធ្យមក្នុងបណ្ដាញ ។ រដ្ឋាភិបាលកម្ពុជាបានចំណាយថវិកាសរុបចំនួន ៣៣.៣៩លានដុល្លាសហរដ្ឋអាមេរិក។ ការចំណាយនេះសម្រាប់លើគម្រោងលើកកម្ពស់គុណភាពអប់រំ ដែលជាជំនួយឥតសំណងចំនួន២៧.១លានដុល្លាពីធនាគារអភិវឌ្ឍអាស៊ី និងថវិកាចំនួន៦.២៩លានដុល្លាពីរាជរដ្ឋាភិបាលកម្ពុជា។ ជំនួយរបស់ធនាគាអភិវឌ្ឍអាស៊ីរួមទាំងការកសាងអគារមធ្យមសិក្សាធនធាន(អ.ម.ធ)

អគារធនធានក្នុងវិទ្យាល័យព្រះរាជសម្ភារ ខេត្តកំពត

**ក. គោលដៅ**

គម្រោងមានគោលដៅពង្រឹងគុណភាពអប់រំនៅតាមសាលារៀនដោយផ្ដោតលើការគាំទ្រជាសំខាន់ចំពោះការអភិវឌ្ឍ និងគ្រប់គ្រងប្រព័ន្ធអប់រំ អភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ការពង្រឹងការអប់រំនៅមធ្យមសិក្សា។

**ខ. ឥទ្ធិពល**

ឥទ្ធិពលនៃគម្រោងគឺជាកំណើនចំនួនប្រជាជនដែលបានទទួលការអប់រំ និងមានជំនាញកាន់តែប្រសើរឡើងនៅក្នុងគ្រប់មជ្ឈដ្ឋានរបស់ប្រជាជនកម្ពុជា ជាពិសេសសិស្សមកពីតំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។

(នៅមានត)

**លោក គួយ សុគាន**

# គណិតវិទ្យា

## រកឃើញចំណោទដែល ទាក់ទងទៅនឹងប្រមាណវិធី

**វត្ថុបំណង**

- បកស្រាយព័ត៌មានផ្សេងៗ ។
- សម្គាល់បម្រាប់ជាលេខ និងប្រមាណវិធីដែលទាក់ទងទៅនឹងស្ថានភាពចំណោទមួយ។
- បកស្រាយអត្ថបទមួយតាមរយៈល្បះលេខ។

### I. គោលបំណងរបស់សលាកប័ត្រ

- ទាក់ទាញបម្រុងប្រយ័ត្នរបស់សិស្សលើការប្រើប្រាស់បម្រាប់ជាលេខ និងប្រមាណវិធីទាំងបួន ជាពិសេសទៅលើន័យនៃប្រមាណវិធី។
- អភិវឌ្ឍសមត្ថភាពសិស្សលើទំនាក់ទំនងរវាងអត្ថបទ និងល្បះលេខ។

ចំណោទ ៖

លោកគ្រូបានសរសេរល្បះលេខលើក្តារខៀនដូចតទៅ ៖

៦៦x ២២ =

គាត់បានឱ្យសិស្សតាក់តែងចំណោទមួយដោយផ្តើមចេញពីល្បះលេខនេះ ។ ខាងក្រោមនេះជាចម្លើយរបស់សិស្ស ៣នាក់ ៖

□ ដានី : ខ្ញុំត្រូវធ្វើដំណើរចម្ងាយ ៦៦ គម ។ ខ្ញុំធ្វើដំណើរបាន ២២គម ហើយ។ តើនៅសល់ចម្ងាយប៉ុន្មាន គីឡូម៉ែតទៀតដែលខ្ញុំត្រូវធ្វើដំណើរ ?

□ សុភា : ថ្នាក់រៀនមួយមានសិស្ស ២២ នាក់។សិស្សម្នាក់ៗមានបំពង់បឺត ៦៦ ដើម ។ តើសិស្សទាំងអស់មានបំពង់បឺតប៉ុន្មាន ?

□ សេង : ខ្ញុំមានគ្រាប់ឃ្លី ២២ គ្រាប់ ។ នៅពេលចេញលេង ខ្ញុំលេងឈ្នះ ៦៦ គ្រាប់ ។ តើខ្ញុំមានគ្រាប់ឃ្លីប៉ុន្មានគ្រាប់ឥឡូវនេះ ?

តើចម្លើយអ្នកណាត្រូវ ? ចម្លើយអ្នកណាខុស ? ចូរផ្ទៀងផ្ទាត់ និងពន្យល់បញ្ជាក់ ?

### II. ការរៀបចំរបស់គ្រូ

ចម្លងប្រធានចំណោទដាក់លើក្តារខៀនមុនម៉ោងបង្រៀន ឬ សរសេរលើផ្ទាំងក្រដាសធំ បើមានលទ្ធភាព ។

### III. លំនាំនៃការបង្រៀន

**ដំណាក់ទី ១ ៖ អំណាន និងការយល់អត្ថន័យនៃអត្ថបទ**

- ឱ្យសិស្សអានអត្ថបទចំណោទដោយស្ងៀមស្ងាត់ ។
- ទុកពេលគ្រប់គ្រាន់ឱ្យសិស្សអាន
- គ្រូសួរ :

« តើមានចំណោទប៉ុន្មាន ? » (មានចំណោទ ៣)

« តើគេឱ្យអ្នកធ្វើអ្វី ? » (រកចំណោទណាដែលទាក់ទងនឹងល្បះលេខដែលឱ្យ)

- ឱ្យសិស្សឆ្លើយឱ្យបានច្រើនអ្នក។
- ឱ្យសិស្សផ្ទៀងផ្ទាត់និងកែតម្រូវ។
- គ្រូសួរបន្ត : « តើល្បះនេះទាក់ទងទៅនឹងចំណោទទាំង ៣ដែរ ឬទេ? »
- ឱ្យសិស្សឆ្លើយឱ្យបានច្រើននាក់ ប៉ុន្តែមិនចាំបាច់ឱ្យផ្ទៀងផ្ទាត់ និងកែលម្អទេ ។

**ដំណាក់ទី ២ ៖ ការស្រាវជ្រាវរបស់សិស្ស**

- ឱ្យសិស្សរកជាបុគ្គល ដោយឱ្យកត់ត្រាតែឈ្មោះអ្នកតាក់តែងចំណោទដែលគេយល់ថាត្រូវនៅលើក្តារឆ្នួន ។
- ទុកពេលគ្រប់គ្រាន់ឱ្យសិស្សរក ។
- គ្រូដើរត្រួតពិនិត្យការងាររបស់សិស្ស

✷បើមានសិស្សមិនទាន់យល់ច្បាស់ គ្រូត្រូវផ្អាកការងារគេសិន ហើយឱ្យអានឡើងវិញដោយប្រុងប្រយ័ត្ននូវសំណួមពរ និងចំណោទទាំង ៣ ។ បន្ទាប់មកឱ្យគេបកស្រាយអត្ថន័យរបស់ចំណោទទាំង ៣ ដោយផ្ទៀងផ្ទាត់ជាមួយនឹងល្បះលេខ។ បន្ទាប់មកទៀតឱ្យសិស្សបន្តធ្វើការងារជាក្រុម ២នាក់ៗ ។

**ដំណាក់ទី ៣ ៖ ការបូកសរុប**

ក្នុងការបូកសរុប គ្រូត្រូវទាញការប្រុងប្រយ័ត្នរបស់សិស្សឱ្យ យល់ច្បាស់ថា ៖

+ ដើម្បីដោះស្រាយចំណោទមួយ គេត្រូវប្រើប្រាស់ប្រមាណវិធីណាដែលទាក់ទងទៅនឹងសំណួរ ។
+ អត្ថបទចំណោទមួយអាចបកស្រាយចេញពីល្បះលេខមួយបាន ។

- គ្រប់ចម្លើយដែលសិស្សរកឃើញ គឺត្រូវឱ្យសិស្សធ្វើអំណះអំណាង ឬគ្រូចោទជាសំណួរ « ហេតុអ្វីបានជាអ្នកយល់ឃើញថា ចំណោទនេះទាក់ទងទៅនឹងប្រមាណវិធីដែលសួរ ? តើសញ្ញាណាខ្លះដែលបញ្ជាក់ប្រាប់ថាត្រឹមត្រូវ ? »
- ឱ្យសិស្សលើកក្តារឆ្នួន ។
- ឱ្យសិស្សផ្ទូរផ្ទង់ចម្លើយ និងផ្ទៀងផ្ទាត់គ្នាទៅវិញទៅមក ដើម្បីរកចម្លើយដូចគ្នា ។
- គ្រូកត់ត្រាចម្លើយផ្សេងគ្នារបស់សិស្សលើក្តារខៀន (ឈ្មោះសិស្ស)។
- ឱ្យសិស្សម្នាក់មកក្តារខៀនបកស្រាយចំណោទដែលខ្លួនរកឃើញ ដោយផ្ទៀងផ្ទាត់ទៅនឹងល្បះលេខ រួចឱ្យសិស្សដែលមានចម្លើយផ្សេងឡើងមកបកស្រាយបង្ហាញដូចអ្នកមុន ។
- ឱ្យសិស្សផ្ទៀងផ្ទាត់ ប្រៀបធៀបរកចម្លើយដែលត្រឹមត្រូវដោយធ្វើអំណះអំណាងផង ។
- ឱ្យសិស្សគូសខ្វែងនៅខាងមុខចំណោទដែលទាក់ទងនឹងល្បះលេខ រួចធ្វើការគណនាយ៉ាងឆាប់បំផុតនៅលើក្តារខៀន និងសិស្សឯទៀតធ្វើលើក្រដាសព្រាង ។
- ផ្ទូរផ្ទង់ចម្លើយនិងកែតម្រូវ ។

✷ចំពោះចំណោទ ២ផ្សេងទៀតគ្រូត្រូវឱ្យសិស្សម្នាក់ៗ សរសេរប្រមាណវិធីលើក្រដាសព្រាង។

- ទុកពេលឱ្យសិស្សរកចម្លើយ ។
- ឱ្យសិស្សម្នាក់មកបង្ហាញប្រមាណវិធីនៃចំណោទនីមួយ ៗ។

- ឱ្យសិស្សផ្ទៀងផ្ទាត់ចម្លើយនិងកែតម្រូវ ។

**ដំណាក់ទី ៤ ៖ សន្និដ្ឋាន**

- គ្រូសួរៈ

  « តើអ្នកយល់ដឹងអ្វីខ្លះអំពីចំណោទ ? »

  « បន្ទាប់ពីបានសិក្សារួចមក តើអ្នកបានទទួលចំណេះដឹងអ្វីខ្លះបន្ថែម ? » (ប្រធានចំណោទមួយទាក់ទងនិងប្រមាណវិធីមួយ)

  « កាលណាយើងមានចំណោទមួយ តើគេត្រូវធ្វើដូចម្ដេច ? » (អាន យល់ ជ្រើសរើសប្រមាណវិធីដែលទាក់ទងទៅនឹងចំណោទ )

- គ្រូធ្វើសំយោគដោយបង្ហាញអត្ថបទ « គួរចងចាំ » ។

**គួរចងចាំ**

យល់ស្ថានភាពចំណោទមួយ គឺជាការចេះភ្ជាប់ប្រធានចំណោទទៅនឹងចម្លើយដែលស្នើឡើង។ ចំពោះបញ្ហានេះ គឺត្រូវចេះប្រើប្រាស់សញ្ញាសម្គាល់ផ្សេងៗ (Indices):

- ប្រមាណវិធីដែលត្រូវប្រើ
- ចំនួន និងឯកតារបស់វា និងបកស្រាយប្រធានចំណោទតាមរយៈល្បះលេខផងដែរ ។

## IV. ចម្លើយ

- ចម្លើយរបស់សុភាត្រូវ ព្រោះថា ដើម្បីរកចំនួនបំពង់ប៊ីតទាំងអស់គេត្រូវប្រើប្រមាណវិធីគុណ ។

  ៦៦ x ២២= ១៤៥២ បំពង់ប៊ីត

- ចម្លើយរបស់ដានីខុស ព្រោះសំណួរដានីត្រូវប្រើប្រមាណវិធីដក ។

  ៦៦ - ២២ = ៤៤ គម

- ចម្លើយរបស់សេងខុស ព្រោះសំណួរសេងត្រូវប្រើប្រមាណវិធីបូក ។

  ៦៦ + ២២ = ៨៨ គ្រាប់

## V.កំណត់សម្គាល់

ការងារបែបនេះអាចធ្វើជាថ្មីឡើងវិញតាមរបៀបដូចគ្នា ។ គ្រូបង្រៀនអាចប្រើប្រាស់ចំណោទដែលមាននៅក្នុងសៀវភៅរបស់ក្រសួងនិងកែសម្រួល ដើម្បីកសាងសមត្ថភាពគំរូនេះ (ចំណោទទី១ខាងក្រោមត្រូវដាក់ឱ្យសិស្សធ្វើនៅក្នុងថ្នាក់នាពេលបន្ទាប់នេះ)។

គេអាចលើកឡើងនូវល្បះលេខ ២ ឬ ៣ ដើម្បីឱ្យសិស្សតាក់តែងជាអត្ថបទចំណោទដែលទាក់ទងទៅនឹងល្បះលេខនោះ ។ ចំណោទទី ២ និងទី ៣ ខាងក្រោមត្រូវដាក់ឱ្យសិស្សធ្វើនៅក្នុងថ្នាក់ ឬនៅផ្ទះ ។

**ចំណោទ**

១. ចូរជ្រើសរើសចំណោទណាមួយដែលទាក់ទងនឹងល្បះលេខក្នុងចំណោមចំណោទទាំង ៣ខាងក្រោម ៖

១៧២ + ៥៥ = ......

**ក.** សាលារៀនមួយរៀបចំដឹកសិស្សទៅធ្វើទស្សនកិច្ចសិក្សានៅភ្នំតាម៉ៅ ។ ក្នុងចំណោមសិស្ស ២២៧ នាក់ សិស្ស ១៧២នាក់ បានស្ថិតនៅក្នុងរថយន្តពីរ រួចជាស្រេច ។ សិស្សដែលនៅសល់ត្រៀមឡើងរថយន្តទី ៣ ។ តើសិស្សប៉ុន្មាននាក់ដែលត្រូវឡើងជិះរថយន្តទី ៣ ?

**ខ.** សាលារៀនមួយរៀបដឹកនាំសិស្សទៅធ្វើទស្សនកិច្ចសិក្សានៅភ្នំតាម៉ៅ ។ សិស្ស ១៧២នាក់ស្ថិតនៅក្នុងរថយន្តពីរ និងសិស្ស ៥៥នាក់ ដែលនៅសល់ឡើងរថយន្តទី ៣ ។ តើចំនួនសិស្សប៉ុន្មាននាក់ដែលត្រូវធ្វើដំណើរតាមរថយន្ត?

**គ.** សាលារៀនមួយរៀបដឹកនាំសិស្សទៅធ្វើទស្សនកិច្ចសិក្សានៅភ្នំតាម៉ៅ ។ សិស្ស ១៧២នាក់ស្ថិតនៅក្នុងរថយន្តពីរ និងសិស្ស ៥៥នាក់ ដែលនៅសល់ត្រូវត្រឡប់ទៅផ្ទះវិញ ព្រោះខ្វះរថយន្ត ។ តើមានចំនួនសិស្សប៉ុន្មាននាក់នៅក្នុងរថយន្តនីមួយៗ ?

**២.** ចូរតាក់តែងចំណោទមួយដែលទាក់ទងនឹងល្បះលេខខាងក្រោម ៖

| |
|---|
| ៦០០ X 5 = ....... |

**៣.** ចូរតាក់តែងចំណោទមួយដែលទាក់ទងនឹងល្បះលេខខាងក្រោម ៖

| |
|---|
| ( ៨x ១៨ ) - ៦ = ..... |

**ដកស្រង់ដោយអ្នកស្រី ម៉ិន សារ៉ន**

## ទសបារមី

គឺជាការកសាងបារមីទាំង១០ របស់ព្រះពោធិសត្វដោយត្រឹមត្រូវ មុនពេលបានត្រាស់ដឹងជាព្រះពុទ្ធដែលបានចែងក្នុងទសជាតកនោះគឺ ៖

| | |
|---|---|
| ១. តេមិយជាតក | សាងនេក្ខម្មបារមី |
| ២. មហាជនកជាតក | សាងវីរិយបារមី |
| ៣. សុវណ្ណសាមជាតក | សាងមេត្តាបារមី |
| ៤. នេមិរាជជាតក | សាងអធិដ្ឋានបារមី |
| ៥. មហោសថជាតក | សាងបញ្ញាបារមី |
| ៦. ភូរិទត្តជាតក | សាងសីលបារមី |
| ៧. ចន្ទកុមារជាតក | សាងខន្តីបារមី |
| ៨. នារទព្រហ្មជាតក | សាងឧបេក្ខាបារមី |
| ៩. វិធុរជាតក | សាងសច្ចៈបារមី |
| ១០. វេស្សន្តរជាតក | សាងទានបារមី ។ |

ទសជាតក




# រមណីយដ្ឋានឆ្នេរកែប

« បទពាក្យប្រាំពីរ»

១. ឆ្នេរកែបបត់បែនដែនសមុទ្រ ទេសភាពល្អផុតអស់ទឹកដី
តំបន់ធម្មជាតិមានទឹកប្រៃ សមុទ្រស្ដឹមស្ដៃជាប់ជួរភ្នំ ។
២. សម្រស់ជលស័យព្រឹក្សព្រៃវល្លិ៍ ឆ្នេរខ្សាច់បវរស្ថានមនោរម្យ
ក្រុងប្រសើរគាប់ជាប់ជើងភ្នំ គ្រឹះស្ថានកុះកុំភ្នំប្រួលប្រែ ។
៣. ជារមណីយដ្ឋានល្អប្រណិត ទេសចរណ៍ឆ្ងាយជិតច្រើនហូរហែ
មិនថាអ្នកក្រុងចំការស្រែ បរទេសដង្ហែខ្សែរថយន្ត ។
៤. ដងផ្លូវចង្អៀតឆ្លៀតពិនិត្យ តូបស្នាក់មូលមិត្តច្រើនពេកពន់
សម្រាកហូបចុកជានិរន្តរ៍ មុខម្ហូបគ្រប់គ្រាន់មានឆ្អិនឆៅ ។
៥. ខ្លះថាតូបស្បូវល្អត្រជាក់ ខ្លះជាប់ជំពាក់អ្នកតាមហៅ
នារីស្រស់ស្អាតឆ្លាតចៅរៅ ប្រាប់ពីគោលដៅសេវាកម្ម ។
៦. ខ្លះជាប់ហូបបាយស្ដាយពន្លឹក ឃើញគេងូតទឹកយ៉ាងសស្រាំ
ខ្លះដើរខ្លះរត់ជាសកម្ម ស្វែងរកអ្នកចាំជួលឧបករណ៍ ។
៧. ចំពេលរដូវមានជំនោរ រលកឱ្យសួរពេញលំហ
អ្នកចង់ទៅឆ្ងាយពុំត្រេកអរ គ្មានទូកបើកបរជូនទៅមក។
៨. អ្នកខ្លះហ៊ានជិះពោះវៀនឡាន ប្រឹងហែលរុញប្រានផ្ទាំងរលក
វិលវង់មុជងើបកាត់ទៅមក ជួនត្រូវខ្យល់បោកបបូតដៃ ។
៩. បរទេសសាច់សដេកសន្ធឹង លើឆ្នេរសម្ងឹងពន្លឺថ្ងៃ
កុមារតូចៗប្រឹងកាយដី ខ្សាច់សើមជាតិប្រៃពូនជាភ្នំ ។
១០. រីឯតាយាយវ័យចំណាស់ ទឹកចិត្តថ្លាជ្រះអង្គុយជុំ
នៅលើខឿនថ្មដោយសុខដុម ម្ហូបផ្ទៃត្រសុំត្រសាយក្រៃ ។
១១. អ្នកខ្លះដក់ចិត្តជិតអារម្មណ៍ សញ្ជឹងគយគន់បែបកវី
រំភើបរីករាយមិនចេញស្ដី ប៉ះជំនោរថ្មីរំពៃឆ្ងាយ ។
១២. ឃើញផ្ទៃសមុទ្រស្លុតស្មារតី រលកជំក្រៃបែកទឹកខ្វាយ
មានកោះតូចធំវែងអន្លាយ រំពេររោយក្នុចមេត្រី ។
១៣. ពេលគ្មានជំនោរទឹកប្ដូរផ្លាស់ ផ្ទៃមេឃស្រឡះមានរស្មី

ព្រះសូរ្យចិញ្ចែងឆ្លុះព្រឹក្សព្រៃ ដលជីរសប្រៃផ្ទៃនឹងថ្កល់ ។
១៤. សមុទ្រដោរនាចពណ៌ខៀវស្រស់ គ្រប់ទីកៀនកោះអាចទៅដល់
ទូកចែវទូកយន្តចេញរចល់ ដោយក្តីកង្វល់នឹងការងារ ។
១៥. អ្នកធ្លាប់ទទួលជួលឧបករណ៍ ជូនភ្ញៀវទេសចរណ៍ឥតរួញរា
កាណូតអូរបិរបានជានា ដឹកឆ្លងជលសាទៅដល់កោះ ។
១៦. ទន្សាយល្បីឈ្មោះកោះសប្បាយ ឃើញហើយមិនណាយស្តាយស្រណោះ
សម្បត្តិធម្មជាតិល្អឥតខ្ចោះ ពេញដោយសម្រស់កោះប្រិមប្រិយ ។
១៧. ខ្លះនេសាទត្រីក្តាមបង្គា ភោគផលនានារៀងរាល់ថ្ងៃ
ហូបចុកលក់ដូរយកកម្រៃ លើកស្ទួយតម្លៃក្រុមគ្រួសារ ។
១៨. អ្នកមានថ្វីដៃច្នៃរបស់ តម្លៃមិនខ្ពស់ស្រស់សោភា
សំបកក្រែងខ្យងមិនភោក្តា ផលិតរចនាលក់គ្រប់គ្រា ។
១៩. ឆ្នេរកែបរមណីយដ្ឋានទេសចរណ៍ រន្ទឺខ្ទាយខ្ចរពេញរដ្ឋា
ស្ទួយសេដ្ឋកិច្ចជាតិនិងគ្រួសារ រុងរឿងថ្លៃថ្លាអភិវឌ្ឍន៍ ។
២០. គប្បីពលរដ្ឋខ្មែរគ្រប់វ័យ អ្នករកកម្រៃចងចាំស្មាត់
ខូចបរិស្ថាននាំ ក្រខ្សត់ ចេះថៃប្រាកដកើតទ្រព្យ ។

**លោក ប្រាក់ សាធាត់**

(អតីតប្រធានការិយាល័យអប់រំយុវជន និង កីឡា ស្រុកបន្ទាយមាស ខេត្តកំពត )

## *ឱ្យអភ័យជានិច្ច*

*ការឱ្យអភ័យជាសេចក្តីល្អមួយដ៏ចាំបាច់ណាស់ក្នុងការសមាគមជាមួយនឹងមនុស្ស ព្រោះមនុស្សចំនួនច្រើនដែលតែងតែមានការខូចខាតនូវចំណុចនេះ ចំណុចនោះ ពោលគឺនៅមានកំហុសដោយចំពោះ មនុស្សដែលរស់នៅក្នុងកាមតណ្ហា គឺពិតជាមិនខ្វះនូវឱកាសនៃការភ្លាំងភ្លាត់ឡើយ ។*

*បើយើងតាំងចិត្តសេពគប់សមាគមជាមួយអ្នកណាៗហើយនោះ យើងត្រូវត្រៀមខ្លួនជានិច្ច ដើម្បីឱ្យអភ័យ បើមិនដូច្នេះទេយើងមិនអាចសេពគប់ជាមួយអ្នកណាបានឡើយ ។ មនុស្សខ្លះមានកំហុសត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះ បើយើងប្រកាន់យកជារឿងធំ យើងនឹងបែកចិត្ត សឹងជាមិនល្អទៀតផង ។*

*ដកស្រង់ចេញពីសៀវភៅ ៤៨ ធម្មទស្សន៍*

# វិធីអាន(តចប់)

(បទពាក្យប្រាំពីរ)

២១. មួយទៀត**អាកាសមិនស្អុះថប់** ឬញ័រចំប្រប់ងោពេក
មួយសោតគឺ**ក្លិនល្អអនេក** មិនអាក្រក់ប្លែកនាំរំខាន។
២២. វិធីមួយទៀត**មិនឱ្យហត់** មិនបាច់ខំអត់នាំឈឺប្រាណ
គឺត្រូវព្យាយាមធ្វើឱ្យបាន ក្នុងពេលអំណានត្រូវឧស្សាហ៍
២៣. **ដូរក្រសែភ្នែក**មើលនាយអាយ នោះនឹងរសាយអស់ទុក្ខា
ភ្នែកនឹងបាត់ហត់ហើយកាលណា កាលនោះចាត់ការបន្តអាន ។
២៤. សូមចាំកុំភ្លេចកុំចង្អៀត នេះ **គឺជាស្នៀតនាំអំណាន**
ដែលខ្ញុំរកឃើញអំបាលមាណ ទុកជូនជាទានដ៏កម្រ។
២៥. ខ្មែរយើងភាគច្រើនមិនរវល់ អ្នកខ្លះតែងខ្វល់គ្មានអំណរ
ថាអានបន្តិចតាំងមិនល្អ ឈឺក្បាលវឹកវរគួរឱ្យខ្មាស់។
២៦. ទំលាប់អានសព្វមិនរើសមុខ អានហើយចាំទុកគឺល្អណាស់
ចំណេះចេះដឹងច្រើនល្អល្អះ អ្នកខ្មាស់គឺអ្នកដែលខ្ជិលអាន។
២៧. អ្នកខ្លះរូបស្អាតមានទាំងទ្រព្យ ធំមុខធំគាប់ល្អតែប្រាណ
ពេលហាស្ដីឡើងស្ដាប់មិនបាន ព្រោះខួរក្បាលគ្មានចំណេះដឹង ។
២៨. ហេតុនេះហៃអស់អនុជន មិនត្រូវទម្រន់ទម្លាប់ប្រឹង
ទម្លាប់អានច្រើនឱ្យបានដឹង ដំណឹងរាក់ជ្រៅកាន់តែឆ្ងាយ ។
២៩. កុំឱ្យគេថាខ្មែរល្ងង់ខ្លៅ ងាយបោកឆាឆៅឱ្យអន្តរាយ
មើលឃើញតែជិតខ្លួនរៀងអាយ ទុក្ខទំលើកាយមិនដឹងខ្លួន ។
៣០. ក្មេងក្លាងគ្រាន់បើម្នាក់ឯកគត់ មានការក៏រត់រកទីពួន
ដោយអត់អ្វីអាងធំមាំមួន មិនខុសពីសួនមានតែដី ។
៣១. វិជ្ជាជាទ្រព្យលម្អមនុស្ស អាវុធស្វាញស្អុះស័ក្ដិសិទ្ធិក្រៃ
អ្នកមានវិជ្ជាមិនដែលភ័យ រឿងតូចធំក្ដីដោះស្រាយបាន ។
៣២. អ្នកចេះទោះទៅដល់ទីណា តែងនាំអាត្មាឱ្យសុខសាន្ត
ស្របខ្លួនបានលឿននឹងមជ្ឈដ្ឋាន គ្មានអ្វីរំខានឱ្យធំដុំ។
៣៣. វិជ្ជាអភិវឌ្ឍញាណទាំងប្រាំ ថែមចេះចងចាំជាសំណុំ
ឱ្យរីកចម្រើនកាន់តែធំ អំណាចប្រក់ព្រំលើធម្មជាតិ ។
៣៤. ញាណមួយគឺភ្នែកកាន់តែមុត មើលឆ្ងាយឃើញសុទ្ធមិនភ្លាត់ស្នៀត
ឃើញកាន់តែជ្រៅខ្ពស់ថែមទៀត តូចពេកក៏ជៀតមើលឃើញច្បាស់។
៣៥. ឃើញរាប់លានឆ្នាំកន្លងហើយ ទៅមុខជាត្រើយដែលឆ្ងាយណាស់
ក៏អាចនឹងឃើញមិនក្រឡះ ក្រឡាប់ផ្ដេសផ្ដាស់ខុសម្ដងទេ ។
៣៦. ញាណពីរ**ទឹកមាត់កាន់តែប្រែ** អំណាចជ្រៀវជ្រែខ្លាំងគ្មានទ្វេ

| | | |
|---|---|---|
| | ហាឡើងគេស្ដាប់មិនងាករេ | ងាយស្ដាប់ឆាប់ចេះ(យល់)ឆាប់បានការ ។ |
| ៣៧. | ញាណបីសំដៅយក**ត្រចៀក** | រួសខ្លាំងទោះប្រៀងខ្សឹបម្ដេចម្ដា |
| | ដឹងពាក្យខ្សឹបខ្សៀវស្រាលយ៉ាងណា | ត្រចៀកយកការណ៍បានទាំងអស់ ។ |
| ៣៨. | ញាណបួន**ច្រមុះងាយដឹងក្លិន** | ខ្លាំងស្រាលឆៅឆ្អិនមិនទើសសោះ |
| | ដឹងថាក្លិនអ្វីមិនចន្លោះ | ទោះនៅកៀនកោះក៏ស្រង់បាន ។ |
| ៣៩. | ញាណប្រាំគឺ**កាយរស់ឥតប្រៀប** | ដឹងអស់នៅទៀបជិតអង្គប្រាណ |
| | ទាំងនៅទីឆ្ងាយនៅប៉ុន្មាន | ក៏កាយវិញ្ញាណដឹងសព្វសារ។ |
| ៤០. | វិជ្ជានេះហើយដែលត្រូវស្វែង | គ្រេបយកកុំក្រែងមិនបានការ |
| | យកពីសៀវភៅគ្រូអាចារ្យ | បានច្រើនកាលណាល្អកាលហ្នឹង ។ |
| ៤១. | **ហេតុនេះមិនគួរនៅទំនេរ** | **រិះរេរកអានឱ្យចេះដឹង** |
| | **អានយកវិជ្ជាជាពុំនឹង** | **គ្រាន់បានពាក់ពឹងដល់ខ្លួនចាស់ ។** |

**លោក ឈា ឈៀន**
**( និវត្តជន អតីតអគ្គនាយករង គ.ប.ច. អយក.)**

*សូមសាកល្បងអានអត្ថបទខ្មែរបុរាណ* (ឆ្នាំ ១៨៨៦)

*ពាក្យប្ដឹងពីចោរផ្លន់កន្ដាលផ្លូវ*

*ថ្ងៃយ១៤៩ ឆ្នាំរ័កានុព្វសក្ស៣៨ សូម្ទានចៅវទ្យាលីវខ្ញុំប្របា្ទម្ចាស់ផ្ទះនៅភូមបាភ្នំក្នុងក្រុម៍មៀ្យងខ្ញុំប្របា្ទម្ចាសសូមផ្ញើដំណើរតាមចំណាំ ន្មាំមកក្រាបប្របនិបាត្តប្តឹងលោកអ្នកឲកញ៉ាយោមរាជ លោកអ្នកឲកញ៉ារត្តណាធិបតេ។ លោកអ្នកឲកញ៉ាធម្មានិករ ។ លោកអ្នកឲកញ៉ាពីរុបុលរាជ ។ នៅអ្យលោកចៅក្រកុងសីរ្យជុំនុំទំ្ទលូម្ទានប្រាប ដ្បិតខ្ញុំប្របា្ទម្ចាសិកេតទុក្ខំពុលុកចិត្រនឹងចៅម៉កនៅភូមបាភ្នំក្នុងក្រុំម៍មៀ្យងជាម្យូគ្នា កាលនៅថ្ងៃ១៣៩ នេះខ្ញុំប្របា្ទម្ចាសយកច្រាកហាសិបរៀលទៅទិញអង្ករ នៅភូមព្រៃព្រីងក្នុងខែតភ្នំមពេញ លុះដល់ទៅជិតភូម ចំងក្រានតាពុំ ពីលាម៉ោង ៥ ឯព្រឹក ស្រាបតែឃើញចៅម៉ក ។ និងកូវកនច្រាំនាក្នមកផ្លន់យកច្រាំកខ្ញុំប្របា្ទម្ចាសអ្យទៅ នេះអ្នកស្រុកសិងមានឈ្មោះបានដឹងបានឮបានឃើញផង ហែតនេះខ្ញុំប្របា្ទម្ចាះពុំកសុក្ខចិត្រសូមបំរើអ្យលោកប្របា្ទម្ចាះទៅរកចាប់យកខ្លួនចៅម៉ក ។ និងកូវកនមកជំនុំជំរាះឲ្យទានខ្ញុំប្របា្ទម្ចាសសុក្ខចិត្រត៏ទៅ សំាចក្តីខុសត្រូវខ្ញុំប្របា្ទម្ចាសទ៍ទួលតាមច្បាប់គ្រែងពុំប្រកត់ខ្ញុំប្របា្ទម្ចាស គូសថ្នាំងចំងឱលដែ្យឆ្វេងជំរាបជូនទុកជាចំណាំស្រាប ។*

# កតញ្ញូតាធម៌

(បទកាកគតិ)

១. កតញ្ញូតា មានន័យប្រាប់ថា ជនកតញ្ញូ
ត្រូវតែប្រព្រឹត្ត តាមបែបគំរូ ដែលព្រះបរមគ្រូ
ប្រាប់ឱ្យតបគុណ ។

២. មាតាបិតា គ្រូឧបជ្ឈាយ៍ សុទ្ធតែស្រែបុណ្យ
ជនណាក៏ដោយ ដែលគេមានគុណ ក៏ជាស្រែបុណ្យ
ដែលគេត្រូវព្រោះ ។

៣. បណ្ដុះពូជបុណ្យ ក្នុងស្រែជាគុណ កុំឱ្យមានមោះ
បុណ្យនឹងកើតកើន ចម្រើនឥតខ្វោះ ត្រូវមានចិត្តស្មោះ
កុំលុបគុណខោល ។

៤. កុំគ្រាន់តែថា មាតាបិតា មានគុណជាគោល
មាត់ថាត្រូវតប គុណកុំច្បោលៗ ធ្វើដែរស្រាលៗ
សោះតែគេថា ។

៥. ជនអ្នកតបគុណ ព្រះពុទ្ធមានបុណ្យ ទ្រង់ត្រាស់ទេសនា
សរសើរញឹកញយ មានក្នុងសាស្ត្រា គម្ពីរដីកា
គួរយើងចងចាំ។

៦. ចេះចាំហើយធ្វើ ដោយចិត្តអើពើ ឱ្យស៊ប់ឱ្យស៊ាំ
ឱ្យសុទ្ធនឹងគុណ គុណតែងថែទាំ ពុំមែនខ្វេចខ្វាំ
ព្រោះតបគុណទេ ។

៧. ជនមានចិត្តខ្សោយ ច្រើនតែធ្វេសធ្លោយ រមិលគុណគេ
អាងព្រេងសំណាង ពីក្នុងបុព្វេ ប្រហែសធ្វេសធ្វេ
ព្រងើយកន្តើយ ។

៨. អ្នកប្រាជ្ញប្រាប់ថា ជនប្រុសស្រីណា លុបគុណចោលហើយ
ជនប្រុសស្រីនោះ ពុំមានសុខស្បើយ យូរប៉ុន្មានឡើយ
រែងតែធ្លាក់ខ្លួន ។

៩. កំពុងមានសុខ ស្រាប់តែមានទុក្ខ ចេញមុខផ្ទួនៗ
ឱ្យផលកំណាច យោរយៅឥតសួន ទោសមកពីខ្លួន
រមិលគុណគេ ។

**ដកស្រង់ចេញពីសៀវភៅធម្មជីវិត (ព្រះមហាម៉ាសុនិវិសុទ្ធា)**



# ពុទ្ធសាសនានៅប្រទេសកម្ពុជា

ដូចបានរៀបរាប់មកហើយក្នុងវគ្គមុនៗថា ក្រោយពុទ្ធកាលគឺក្នុងសតវត្សទី ៣ នៃពុទ្ធសករាជ ព្រះមោគ្គល្លីបុត្តតិស្សត្ថេរ ដោយមានការឧបត្ថម្ភពីព្រះបាទអសោកមហារាជផងនោះ បានចាត់បញ្ជូនព្រះថេរៈ ២រូបគឺ ព្រះសោណត្ថេរនិងព្រះឧត្តរត្ថេរ ឱ្យទៅប្រកាសផ្សាយពុទ្ធសាសនានៅសុវណ្ណភូមិ ។ ដូច្នេះនាំឱ្យឆ្ងល់ថា សុវណ្ណភូមិនោះនៅត្រង់ទីតំបន់ប្រទេសណា ? ម៉េចក៏ហៅសុវណ្ណភូមិ សុវណ្ណភូមិ និងសុវណ្ណទ្វីបដូចគ្នាឬផ្សេងគ្នា ?

ពាក្យថា «**សុវណ្ណភូមិ**» មកពីពាក្យបាលីថា សុវណ្ណ + ភូមិ ។ សុវណ្ណប្រែថា មាស , ភូមិប្រែថា ទីដី , ផែនដី, តំបន់ សំដៅយកប៉ែកផែនដីឬប៉ែកទីតំបន់ដែលកំណត់តាមតម្រាភូមិសាស្ត្រ ។ សុវណ្ណភូមិ ប្រែថាផែនដីមាស ឬទីកើតមាស ។ ឯពាក្យថា « ទ្វីប » ជាពាក្យសំស្ក្រឹត, បាលីថា « ទីប » ប្រែថា « កោះ » គឺសំដៅយកទីដីឬភ្នំដែលមានទឹកព័ទ្ធជុំវិញ ដូចកោះកុង កោះកាពិ, កោះស្រីលង្កា (លង្កាទ្វីប), កោះស៊ូមាត្រា, កោះហាវៃ។ល។ ដែលត្រូវនឹងពាក្យអង់គ្លេសថា Island ។ ម្យ៉ាងទៀតផ្ទៃនៃផែនដីដ៏ធំៗ ដែលភាសាអឺរ៉ុបហៅថា continent នោះក៏ហៅថា « ទ្វីប » ដែរគឺ ទ្វីបអាហ្វ្រិក, ទ្វីបអន្តាកទិក, ទ្វីបអាស៊ី, ទ្វីបអូស្ត្រាលី, ទ្វីបអឺរ៉ុប, ទ្វីបអាមេរិក ។

កាលពីបុរាណ មហាទ្វីបមាន ៤គឺ បុព្វវិទេហទ្វីប ១ ជម្ពូទ្វីប ១ អបរគោយានទ្វីប ១ ឧត្តរកុរុទ្វីប ១ ។ គេសម្គាល់ថាទ្វីបបុរាណទាំង ៤ នេះឋិតនៅជុំវិញជើងភ្នំហិមពាន្ត ជួនកាលហៅថា ហិមាល័យ, ហិមាលយា, សិនេរុ,សុម៉េរុ។ល។ គឺភ្នំ Everest នោះឯង។ ប៉ុន្តែភូមិសាស្ត្របច្ចុប្បន្ន មិនមាននិយាយពីមហាទ្វីបបុរាណ នេះទេ ។

សុវណ្ណភូមិ ជាឧបទ្វីបឋិតនៅក្នុងទ្វីបអាស៊ីភាគអាគ្នេយ៍ដែលក្នុងសតវត្សទី ៣ នៃពុទ្ធសករាជ មានប្រជាជាតិតែ ៣ គឺ ភាគខាងលិចប្រជាជាតិមន, ភាគកណ្ដាលប្រជាជាតិខ្មែរ, ភាគខាងកើតប្រជាជាតិចាម ។ ក្រោយមក សុវណ្ណភូមិមានឈ្មោះថា « ឥណ្ឌូចិន » ព្រោះនៅត្រង់ចន្លោះប្រទេសឥណ្ឌានិងប្រទេសចិន បានដល់ប្រទេសភូមា, ជ្រោយម៉ាលក្កា, សៀម, ខ្មែរ, លាវ, កូសាំងស៊ីន, អណ្ណាម, តុងកឹង។

ព្រះមហាវិរិយបណ្ឌិត ប៉ាងខាត់ បានខំប្រឹងព្យាយាមយ៉ាងមុតមាំក្នុងការស្រាវជ្រាវឱ្យដឹងប្រាកដថា សុវណ្ណភូមិឋិតនៅត្រង់តំបន់ប្រទេសណា ? មានអ្វីជាភ័ស្តុតាង ។ ព្រះថេរៈអង្គនោះ បានព្យាយាមពិនិត្យមើលប្រវត្តិសាស្ត្រភូមិសាស្ត្រនិងព្រឹត្តិប័ត្រនៃប្រទេសនានា ដែលគេសរសេរជាភាសាបារាំងក្ដី ភាសាអង់គ្លេសក្ដី សៀមក្ដី ដូចជាកំណត់ហេតុ ឬសេចក្ដីរាយការណ៍របស់អ្នកប្រាជ្ញល្បីឈ្មោះទាំងឡាយមានជាអាទិ៍ គឺលោក G.Coedes, J.tiliozat,Dr. P. Bapat, L. Finot, G. H. Luce, Briggs, P. Dupon។ ខ្ញុំសូមដកស្រង់អត្ថបទខ្លះៗ ដែលព្រះថេរៈជាអ្នកប្រាជ្ញខ្មែរអង្គនេះបានសរសេរនៅក្នុងសៀវភៅ ពុទ្ធសាសនា ២៥០០ ដើម្បីជាការចងចាំ និងជាការសិក្សាបន្ថែមដូចតទៅ ៖

ដើមហេតុដែលនាំឱ្យជនជាតិឥណ្ឌាមកកាន់សុវណ្ណភូមិក្នុងកាលនោះ គឺប្រាថ្នារកមាសជាធំ បានជាកើតពាក្យថា « សុវណ្ណភូមិ » នេះឡើង ។ ជនជាតិឥណ្ឌាក៏ដូចជាជនជាតិអឺរ៉ុបដែរ ដែលចេញទៅរកមាសនៅទ្វីបអាហ្វ្រិកខាងត្បូងក្ដី ទៅទ្វីបអាមេរិកខាងជើងត្រង់រដ្ឋកាលីហ្វ័រនាក្ដី មិនមែនដោយផ្លូវនយោបាយតែម្យ៉ាងទេ គឺដោយសារមានបំណងរកមាស

ជាហេតុធំផងដែរ ។ ភូមិប្រទេសណាមានមាស ភូមិប្រទេសនោះតែងតែមានមនុស្សធ្វើដំណើរទៅមក ហើយឱ្យឈ្មោះទីឋាននោះ បើជាភាគផែនដីធំហៅថា សុវណ្ណភូមិ បើជាកោះហៅថា សុវណ្ណទ្វីប ឬ អែដូរាដូ(Eldorado) តាំងពីកាលនោះមក ។ មិនមែនតែមាសទេ សូម្បីតែគ្រឿងទេស(Spices) ទាំងឡាយ ដូចជាក្រវាញ កំបូរ ខ្លឹមចន្ទន៍ក្រស្នា ដូងជាដើម ក៏ជនជាតិឥណ្ឌាត្រូវការដែរ បានជាកើតមានឈ្មោះថា តក្កោលៈ (ផ្សារលក់ក្រវាញ), កប៉ុរទ្វីប (កោះកប៉ូរ), នាឡិកេរទ្វីប (កោះដូង) ជាដើមឡើង ។

មិនមែនតែជនជាតិឥណ្ឌាទេដែលស្គាល់សុវណ្ណភូមិ ប៉្តូឡេមី (Ptolemy)ដែលជាអ្នកភូមិសាស្ត្រក្រិច គ.ស. ទី ២ អ្នកនិពន្ធជាតិចិនច្រើននាក់មាន កាំង-ថៃ(Kang- Thai)គ.ស.ទី ៣ ជាដើមក្តី ក៏បានស្គាល់សុវណ្ណភូមិនេះច្បាស់ណាស់។

ជនជាតិឥណ្ឌាអ្នកស្វែងរកមាស ធ្វើដំណើរដោយសំពៅ សមុទ្រ ចេញពីកំពង់ធំៗនៅត្រង់ឆ្នេរទក្ខិណទិសាភាគប្រទេសឥណ្ឌា ដូចកំពង់កមរៈនៅមាត់ទន្លេកវេរិ ១ កំពង់ប៉ូឌុកេ ១ កំពង់សោបត្តៈ ១ ឬតាមកំពង់ធំមួយទៀតនៅមាត់ទន្លេគង្គាឈ្មោះ តាម្រលិប្តិ សព្វថ្ងៃហៅ តាមលុក ឆ្ពោះទៅកាន់កំពង់តូចធំនៅឯសុវណ្ណភូមិ ។

(នៅមានត)

**(ដកស្រង់ពីសៀវភៅពន្លឺពុទ្ធសាសនា)**
**រៀបរៀងដោយ លោក សោម ងន**

✍📖✍

### *ឃ្មុំ និង រុយ*

*ឃ្មុំជាសត្វដែលមានសេចក្តីព្យាយាម ឆ្លាតក្នុងការសន្សំចូលចិត្តនឹងរបស់ស្អាត និយមការព្រមព្រៀង ថែមទាំងបានជាប្រយោជន៍ដល់មនុស្សច្រើនប្រការទៀតផង ។*

*រុយជាសត្វមានរូបរាងស្រដៀងគ្នានឹងឃ្មុំដែរ តែមានសភាពចរិតនិស្ស័យនិងការរកស៊ីខុសពីឃ្មុំដូចមេឃនិងដី ។ រុយចូលចិត្តតែរបស់ស្មោគគ្រោក ស្អុយរលួយ និងចម្លងមេរោគផ្សេងៗឱ្យដល់មនុស្សជាដើម ។*

*មនុស្សយើងកើតមក ក៏មានរូបរាងស្រដៀងៗគ្នាដែរ ប៉ុន្តែអ្វីដែលធ្វើឱ្យមនុស្សយើងមានសភាពផ្សេងគ្នានោះ គឺឧប្បនិស្ស័យពីអតីត និងការសេពគប់ក្នុងបច្ចុប្បន្ន ព្រមដោយការសិក្សា ។ ទើបធ្វើឱ្យមនុស្សយើងទៅជាមនុស្សប្រភេទឃ្មុំ ឬប្រភេទរុយនោះឯង។*

*រុយចូលចិត្តលាមក មនុស្សគម្រក់សេពអធម៌*
*ឃ្មុំចូលចិត្តកេសរ ជាតិមនុស្សល្អចូលចិត្តបុណ្យ ។*

***ដកស្រង់ចេញពីសៀវភៅ ៤៨ ធម្មទស្សន៍***

ទស្សនវិជ្ជាស្ត្រី

# សាលារៀនជាគ្រឹះស្ថានសង្គមមួយ

**ក. សារៈប្រយោជន៍នៃសាលារៀន** ( Importance of the school )

លោក (S.Bala Krishna Joshi) បានសរសេរថា ការអភិវឌ្ឍនៃជាតិសាសន៍មួយគឺត្រូវបានគេសម្រេចចិត្តនិងកំណត់មិនត្រឹមតែលើនីតិបញ្ញត្តិប៉ុណ្ណោះទេ ដែលជាកន្លែងមានមហិច្ឆតា និងមានបុរេវិនិច្ឆ័យ សុកវិនិច្ឆ័យ និងអនុវត្តផ្នែកច្បាប់ដែលបានគ្របដណ្ដប់ ហើយមិនត្រឹមតែតុលាការទេ ដែលជាកន្លែងដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ ហើយក៏មិនមែននៅក្នុងរោងចក្រទេ ដែលជាកន្លែងធ្វើឱ្យមនុស្សជំនួសដោយគ្រឿងយន្តនិងគំនិតរបស់បុគ្គលម្នាក់ៗ ប៉ុន្តែនៅក្នុងសាលាដែលជាកន្លែងអប់រំចិត្ត និងផ្ដល់គំរូដល់មនុស្ស ហើយក៏ជាកន្លែងដែលទម្លាប់ អាកប្បកិរិយា ទស្សនវិស័យរបស់មនុស្សដែលត្រូវបានបង្កើត និងជាអធិបតីលើវាសនានៃជាតិសាសន៍នោះ ។

លោក (H.G.Well) បានសង្កេតឃើញថា ពិភពសាលារៀនដែលមិនត្រូវបានគេផ្លាស់ប្ដូរ ក៏គេមិនអាចផ្លាស់ប្ដូរពិភពលោកបានដែរ ។

សាលារៀន គឺជាភ្នាក់ងារដ៏មានសារៈសំខាន់ផ្លូវការមួយនៃការអប់រំ ។ វាអាចដើរតួយ៉ាងចម្បងក្នុងការផ្ដល់គំរូគំនិត ទម្លាប់ ឥរិយាបថ ចំពោះកុមាររួមជាមួយទស្សនៈបណ្ដុះបណ្ដាលបុគ្គលិកលក្ខណៈ ពង្រឹងរូបកាយ កែប្រែចិត្តគំនិតលំនឹងអារម្មណ៍ វក្សាវប្បធម៌ និងប្រសិទ្ធភាពសង្គម ។ ភ្នាក់ងារមិនផ្លូវការមួយនៃការអប់រំដូចជាជំនឿនៅព្រះវិហារ និងគេហដ្ឋានត្រូវបានគេលើកទឹកចិត្តដើម្បីបង្កើនតម្រូវការអប់រំនៃភាពស្មុគស្មាញរបស់សង្គម ។ ក្នុងសម័យទំនើប សាលារៀនត្រូវបានគេសន្មត់ថា មានសារៈសំខាន់ណាស់។

សាលារៀន គឺជាគ្រឹះស្ថានសង្គមមួយដែលបង្កើតឡើងតាមរយៈសង្គម ដើម្បីបម្រើសង្គមរហូតមកដល់ទីបញ្ចប់យោងតាមលោក (Nunn)បានមានប្រសាសន៍ថា សាលារៀនរបស់ជាតិមួយ គឺជាសរីរាង្គ និងជីវិតរបស់ជាតិសាសន៍នោះដែលមុខងាររបស់វាជួយពង្រឹងស្មារតី រក្សានូវនិរន្តរភាពប្រវត្តិសាស្ត្រ ធានានូវសមិទ្ធិផលអតីតកាល និងធានានូវអនាគតរបស់ជាតិ ។ តាមរយៈនេះសាលារៀនរបស់ជាតិមួយ គួរប្រែក្លាយទៅជាមនសិការជាប្រភពមិនចេះដាច់ បានមកពីចលនាដ៏ល្អបំផុតនៃបទពិសោធន៍ក្នុងជីវិត ។

លោក (John Dewey) បានគិតថា សាលារៀន គឺជាគ្រឹះស្ថានសង្គមមុនគេបង្អស់ ។ ការអប់រំគឺជាដំណើរការសង្គមមួយ ។ សាលារៀនគឺជាលំនាំធម្មតាមួយដែលទម្រង់នៃជីវិតក្នុងសហគមន៍ជាភ្នាក់ងារដែលគេយកចិត្តទុកដាក់ ។ និងមានប្រសិទ្ធភាពបំផុតក្នុងការនាំកុមារ ដើម្បីចែករំលែកធនធានមរតករបស់ជាតិសាសន៍មួយក្នុងការប្រើអំណាចដើម្បីអភិវឌ្ឍសង្គម ។

**ខ. សាលារៀនបែបប្រពៃណី** ( The Tranditional school )

ក្នុងសម័យបុរាណ សាលារៀនត្រូវបានគេពិចារណាថា ជាកន្លែងចំណេះដឹង ។ ចំណេះដឹងត្រូវគេផ្ទេរឱ្យសិស្សតាមរយៈការអានឯកសារ យន្តការផ្សេងៗ និងស្ដាប់ព័ត៌មាន ។ ការអប់រំគឺជាទម្រង់មួយដែលគ្មានតួនាទីសំខាន់ក្នុងការភ្ជាប់ទៅកាន់បុគ្គលខុសៗគ្នានិងតម្រូវការនៃសិស្សនោះទេ ។ ការចងចាំបានយូរ និងការទទួលព័ត៌មានសង្គមគឺជាផ្នែកមួយដែលសិស្សត្រូវតែចូលរួម ។ កុមារត្រូវបានគេគិតថា ប្រៀបដូចជាដឹកមនុស្សគ ដឹកសត្វគោក្របី ចូលទៅកាន់ប្រព័ន្ធអប់រំ ។ រំពាត់(Rod) គឺជាអាវុធដ៏សំខាន់ ដើម្បីយកមកអប់រំហើយក្លាយទៅជា ជ័យជំនះនៅក្នុងបរិយាកាសភ័យខ្លាចមួយក្នុងសាលារៀន ។ គ្រូបង្រៀនត្រូវបានគេហៅថា ជាប៉ូលីសម្នាក់ទៅបង្ខឹកនៅក្នុងថ្នាក់រៀន ។ សកម្មភាពនៃកម្មវិធីសិក្សាមិនត្រូវបានគេដឹងឡើយ ។តម្លៃប្រជាធិបតេយ្យ ត្រូវបានគេស្គាល់យ៉ាងពិបាក តម្រូវការចាំបាច់នៃកិច្ចប្រតិបត្តិការរវាងឪពុកម្ដាយត្រូវបានដឹងយ៉ាងពិបាក ។

**គ. ការផ្លាស់ប្តូរបរិយាកាស និងមុខងារសាលារៀនពេលបច្ចុប្បន្ន ៖**

(Change Circumstances and the functions of the present day School)

ការផ្លាស់ប្តូរមុខងារសាលារៀនផ្សារភ្ជាប់ជាមួយនឹងការផ្លាស់ប្តូរបរិយាកាសសង្គម ។ ការអប់រំត្រូវបានគេនិយាយថាមានជើងពីរ គឺជើងទី ១ ផ្នែកទស្សនវិជ្ជា និងជើងទី២ផ្នែកចិត្តវិជ្ជា ។

-ទស្សនវិជ្ជាមានការទ្រទ្រង់យ៉ាងសម្បើមដល់គោលដៅនៃការអប់រំ ។

- ចិត្តវិជ្ជាគឺជាការកំណត់លើវិធីសាស្ត្រនៃការអប់រំ

ជាមួយការចាប់អារម្មណ៍លើចិត្តវិជ្ជា ក្នុងវិស័យអប់រំនិងការផ្លាស់ប្តូរទស្សនវិជ្ជាក្នុងខណៈពេលដែលមុខងារសាលារៀនបច្ចុប្បន្នទទួលបាននូវការប្រែប្រួលព័ត៌មានយ៉ាងខ្លាំងនៅលើពិភពលោក ។ ទស្សនៈនេះត្រូវបានផ្តល់ជាសម្បទាដែលបោះពុម្ពឡើងដោយអង្គការ(UNESCO)។ មុខងារនៃគ្រឹះស្ថានអប់រំ គឺបានជួយមនុស្សប្រុស ស្រីឱ្យរស់មានសេចក្តីថ្លៃថ្នូរ និងរស់មានសុភមង្គលក្នុងភាពសមរម្យជាមួយការផ្លាស់ប្តូរបរិស្ថាន ដើម្បីអភិវឌ្ឍសេដ្ឋកិច្ចក្នុងពិភពលោកទំនើប និងចេះរស់នៅរួមគ្នាក្នុងសុខសន្តិភាព ។

ទស្សនៈនៃគណៈកម្មការអប់រំមធ្យមសិក្សា ស្តីពីសាលាមធ្យមសិក្សាក្នុងពេលអនាគតត្រូវតែមានការផ្លាស់ប្តូរនៅក្នុងសកម្មភាពសាលារៀន ។ យើងមិនអាចបើកភ្នែកមើលសាលារៀនដែលចាត់ទុកថា ជាកន្លែងមានព្រំដែននៃការបណ្តុះបណ្តាលផ្លូវការដែលទាក់ទងសំខាន់ៗជាមួយចំណេះដឹង ប៉ុន្តែវាប្រសើរជាងការរស់នៅ និងការរៀបចំសហគមន៍ជាមួយចំណាប់អារម្មណ៍ដំបូង ក្នុងកាបណ្តុះបណ្តាលសិស្សនូវអ្វីដែលយើងហៅថា សិល្បៈនៃការរស់នៅ ។

**មុខងារសាលារៀនបច្ចុប្បន្នត្រូវបានគេកំណត់ដូចតទៅ ៖**

**•ការអប់រំមានលក្ខណៈគ្រប់ជ្រុង**(Many sided Educatoin)

សាលារៀនបែបបុរាណគឺបង្រៀនឱ្យចេះ (3R's)។ ចំណែកពាក្យស្លោកសាលារៀនបច្ចុប្បន្នគឺបង្រៀនឱ្យចេះ (7R's)

- អាន(Reading)
- សរសេរ(Writing)
- គណិតសាស្ត្រ(Arithmetic)
- វិស្សមកាល (Recreation)
- សិទ្ធិ(Right)
- ការទទួលខុសត្រូវ (Responsibilities)
- ភាពទំនាក់ទំនង (Relationship)

**•បណ្តុះបណ្តាលដើម្បីប្រជាធិបតេយ្យ** (Training for democracy) ៖

សាលារៀនបច្ចុប្បន្ន ត្រូវតែរៀបចំសិស្សសម្រាប់សង្គមប្រជាធិបតេយ្យ តាមរយៈការផ្តល់ឱ្យពួកគេនូវលទ្ធិប្រជាធិបតេយ្យ ។ សិស្សគួរតែរៀបចំហ្វឹកហាត់សិល្បៈនៃការរស់នៅរួមគ្នា (Arts of living together)និងធ្វើឱ្យពួកគេទទួលស្គាល់ការពិត ។ សិទ្ធិនិងកាតព្វកិច្ចនៃសមាជិកដែលទទួលខុសត្រូវសម្រាប់សង្គមប្រជាធិបតេយ្យ ។ ការអប់រំនៅមធ្យមសិក្សាត្រូវផ្តោតយ៉ាងខ្លាំងទៅលើសារៈប្រយោជន៍សមភាពរបស់សិស្សជាមួយការទទួលខុសត្រូវផ្នែកពលរដ្ឋវិជ្ជា ។

**•អភិរក្សលើវប្បធម៌**(Conservation of Culture)៖

សាលារៀនជាគ្រឹះស្ថានដ៏សំខាន់មួយដែលអភិរក្សនូវសីលធម៌ ប្រពៃណី ទំនៀមទម្លាប់ និងមធ្យោបាយនៃជីវិតរស់នៅក្នុងសង្គម ព្រមទាំងការតម្រង់ទិសសម្រាប់សិស្ស ។ មិនអាចកាត់ផ្តាច់ចេញរវាងសង្គមរបស់យើង និងបរិស្ថានវប្បធម៌ពីជំនាន់មួយទៅជំនាន់មួយផ្សេងទៀត ។

**•សាលារៀនគឺជាភ្នាក់ងារនៃកំណែទម្រង់សង្គម**(School as an agency social Reform) ៖

ការអភិរក្សនៃវប្បធម៌វាមិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ លោក (Rybuurn) បានចាប់អារម្មណ៍ថា ការអភិវឌ្ឍសាលារៀនមិនអាចផ្ទុកនូវតម្លៃសម្រាប់មនុស្សបច្ចុប្បន្នបានទេ គេគួររក្សាទុកនូវមត៌ករបស់ឪពុកម្តាយរបស់គេនិងការអភិ - វឌ្ឍសាលារៀន គួរមានគោលដៅសម្រាប់ផលិតអ្វីផ្សេងៗ ។ បណ្ឌិត (K.L. Shrimal) បានសង្កេតឃើញថា ជាដំបូង

សាលារៀនខ្លួនឯងត្រូវតែប្រែក្លាយទៅជាកន្លែងរៀបចំវិចិត្រករ និងជាមន្ទីរពិសោធន៍សម្រាប់សមត្ថភាពកម្រិតខ្ពស់នៃការរស់នៅបែបប្រជាធិបតេយ្យ ។

**•អភិវឌ្ឍឥរិយាបថបែបវិទ្យាសាស្ត្រ** ( Development of a scientific attitude ) ៖

សាលារៀនគួរអភិវឌ្ឍស្មារតីតម្រូវការបែបវិទ្យាសាស្ត្រដល់សិស្ស ។ សមត្ថភាពរបស់ពួកគេក្នុងការប្រើព័ត៌មានត្រូវបានអភិវឌ្ឍ ។ ពួកគេត្រូវបានទទួលការបណ្តុះបណ្តាល ដើម្បីស្វែងរកការងារធ្វើ និងចេះវិនិច្ឆ័យទៅលើសកម្មភាពដែលបានបណ្តុះបណ្តាល ចេះដោះស្រាយបញ្ហា មានគំនិតច្នៃប្រឌិត ។

**•ការសិក្សាអំពីជីវិតនៅក្នុងសាលាត្រូវទាក់ទងជាមួយជីវិតខាងក្រៅ ៖**

( School life closely connected with life outside )

ការសិក្សាអំពីជីវិតនៅក្នុងសាលារៀនត្រូវទាក់ទងជាមួយជីវិតពិតនៅក្នុងសហគមន៍ដូចដែលសិស្សធ្លាប់បានហ្វឹកហាត់នៅក្នុងសាលារៀន ដើម្បីដោះស្រាយបញ្ហាដែលពួកគេបានជួបក្នុងការរស់នៅប្រចាំថ្ងៃ ។ លោកបណ្ឌិត( Saiyidain ) បានកត់សម្គាល់ថា គ្មានសាលារៀននៅក្នុងជនបទណាមួយអាចដណ្តើមយកភាពស្មោះត្រង់ឬក្តីស្រមៃរបស់អ្នកភូមិបានទេ ប្រសិនបើ វាត្រូវបានផ្តាច់ចេញពីទិដ្ឋភាពជាក់ស្តែងនៃជីវិត និងចំណាប់អារម្មណ៍សំខាន់ៗ និងវិជ្ជាជីវៈរបស់វា ។

**លោក គួយ សុគាន**

សាស្ត្រាចារ្យវិទ្យាស្ថានជាតិអប់រំ

## គួរខ្វល់ និងមិនគួរខ្វល់

ស្អែកគង់ថ្ងៃរះនៅតែស្អែក
គ្រប់យ៉ាងកើតឡើងពេលហេតុគ្រប់
ប្រែជាតិសមុទ្រនៅតែប្រៃ
ស្ងួយឱ្យវាសាបមិនអាចស្ងួយ
ខ្វល់រឿងស្រាយបានមិនត្រូវខ្វល់
ក្បួនជាសំពៅនៅតែក្បួន
គិតអ្វីធ្វើអ្វីត្រូវតែគិត
ថាគិតនឹងធ្វើ ធ្វើគិតនឹងថា
អ្វីស្រាយមិនបានខ្វល់ធ្វើអ្វី
សុំព្រះឱ្យជួយមិនត្រូវសុំ

យប់ទោះខំស្រែកនៅតែយប់
ព្រួយទប់ព្រួយទល់នាំតែព្រួយ ។
ជួយឆ្មើមជួយឆ្មៃមិនអាចជួយ
កូនទោះហៅក្មួយនៅតែកូន ។
សូន្យនឹងមកដល់ពេលត្រូវសូន្យ
តាថាជីដូននៅតែតា ។
ការឆ្ងាយការជិតខំធ្វើការ
កុំខ្វល់កិច្ចការដែលត្រូវកុំ។
ផ្ដុំផ្ដើមនាំក្ដីមិនត្រូវផ្ដុំ
ធ្វើទើបច្នើងចុំមកពីធ្វើ ។

**ខៀន សាឃាន**




# អំពីរបាប់ ថ្ងៃ ខែ ឆ្នាំ ចន្ទគតិ និង សុរិយគតិ

តាមការសង្កេតឃើញថា កូនខ្មែរចាប់ពីអាយុ១ឆ្នាំ រហូតដល់អាយុ៣ឆ្នាំ មិនបានចេះរាប់ថ្ងៃ ខែ ឆ្នាំចន្ទគតិសោះ។ ឯរបាប់ ថ្ងៃ ខែ ឆ្នាំ តាមសុរិយគតិវិញ កូនខ្មែរក៏បានចេះរាប់ថ្ងៃ ខែ ឆ្នាំ តាមសុរិយគតិយ៉ាងស្ទាត់ជំនាញវិញ ។ គួរឱ្យខ្មាស់គេណាស់ អរិយធម៌របស់ខ្លួន ខ្លួនមិនចេះ បែរជាចេះអរិយធម៌គេយ៉ាងស្ទាត់ជំនាញទៅវិញ ។ តើរបាប់ ថ្ងៃ ខែ ឆ្នាំ តាមចន្ទគតិមានលក្ខណៈខុសគ្នាពីសុរិយគតិបែបណា ?

## របាប់ថ្ងៃចន្ទគតិ

អាទិត្យ ច័ន្ទ អង្គារ ពុធ ព្រហស្បតិ៍ សុក្រ សៅរ៍ ។

## របាប់ខែចន្ទគតិ

មិគសិរ បុស្ស មាឃ ផល្គុន ចេត្រ ពិសាខ ជេស្ឋ អាសាឍ ស្រាពណ៍ ភទ្របទ អស្សុជ កត្តិក។

## របាប់ឆ្នាំចន្ទគតិ

ជូត ឆ្លូវ ខាល ថោះ រោង ម្សាញ់ មមី មមែ វក រកា ច កុរ ។

## របាប់ថ្ងៃសុរិយគតិ

ច័ន្ទ អង្គារ ពុធ ព្រហស្បតិ៍ សុក្រ សៅរ៍ អាទិត្យ ។

## របាប់ខែសុរិយគតិ

មករា កុម្ភៈ មីនា មេសា ឧសភា មិថុនា កក្កដា សីហា កញ្ញា តុលា វិច្ឆិកា ធ្នូ ។

## របាប់ឆ្នាំសុរិយគតិ

របាប់ឆ្នាំសុរិយគតិ មិនមានឈ្មោះឆ្នាំសម្រាប់រាប់ដូចជាឆ្នាំចន្ទគតិឡើយ ។ លោកបានរាប់ថា ១, ២, ៣, .... រហូតដល់រយ ពាន់ ម៉ឺន ឆ្នាំតែម្ដង ។

សូមចុះនៅក្នុងទស្សនាវដ្ដីសិន បើលោកទាំងអស់បានយល់ដូចខ្ញុំដែរ សូមកែសម្រួលយកទៅចុះនៅក្នុងសៀវភៅសិក្សា ក្នុងថ្នាក់ណាមួយ ដើម្បីឱ្យកូនខ្មែរ បានចេះរបាប់ ថ្ងៃ ខែ ឆ្នាំ តាមចន្ទគតិដែលជាអរិយធម៌ខ្មែរ ដូចជាខ្មែរដទៃទៀតផង។

**លោក លី សុវីរ**
**និវត្តជន នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា**

# ក្រុង ស្រុក ខណ្ឌ-ឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១២(ត)

## V. បញ្ជីឈ្មោះឃុំតាមស្រុក(ចុងឆ្នាំ២០១១)

| ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ | ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ | ល.រ | ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ |
|---|---|---|---|---|---|
| ០៨ | **ខេត្តកណ្ដាល** | ០៣ | **ស្រុកខ្សាច់កណ្ដាលមាន ១៨ឃុំ** | | ១០. ព្រែកថ្មី |
| ០១ | **ស្រុកកណ្ដាលស្ទឹង មាន ១៨ ឃុំ** | | ១. បាក់ដាវ | | ១១. សំពៅពូន |
| | ១. អំពៅព្រៃ | | ២. ជ័យធំ | ៥ | **ស្រុកលើកដែកមាន៧ ឃុំ** |
| | ២. អន្លង់រមៀត | | ៣. កំពង់ចម្លង | | ១. កំពង់ភ្នំ |
| | ៣. បារគូ | | ៤. កោះចូរ៉ាម | | ២. ក្អមសំណរ |
| | ៤. បឹងខ្យាង | | ៥. កោះឧកញ៉ាតី | | ៣. ខ្ពបអាទាវ |
| | ៥. ជើងកើប | | ៦. ព្រះប្រសប់ | | ៤. ពាមរាំង |
| | ៦. ដើមឫស | | ៧. ព្រែកអំពិល | | ៥. ព្រែកដាច់ |
| | ៧. កណ្ដោក | | ៨. ព្រែកលួង | | ៦. ព្រែកទន្លាប់ |
| | ៨. ថ្មី | | ៩. ព្រែកតាកូវ | | ៧. សណ្ដារ |
| | ៩. គោកត្រប់ | | ១០. ព្រែកតាមាក់ | ០៦ | **ស្រុកល្វាឯម មាន ១៥ ឃុំ** |
| | ១០. ព្រះពុទ្ធ | | ១១. ពុកឫស្សី | | ១. អរិយក្សត្រ |
| | ១១. ព្រែរកា | | ១២. រកាជន្លឹង | | ២.បារុង |
| | ១២. ព្រែកស្លែង | | ១៣. សន្លុង | | ៣. បឹងគ្រំ |
| | ១៣. រកា | | ១៤. ស៊ីធរ | | ៤. កោះកែវ |
| | ១៤. រលាំងកែន | | ១៥. ស្វាយជ្រុំ | | ៥. កោះរះ |
| | ១៥. សៀមរាប | | ១៦. ស្វាយរមៀត | | ៦. ល្វាសរ |
| | ១៦. ត្បែង | | ១៧. តាឯក | | ៧. ពាមឧកញ៉ាអុង |
| | ១៧. ត្រពាំងវែង | | ១៨. វិហារសួរ | | ៨. ភូមិធំ |
| | ១៨. ទ្រា | ០៤ | **ស្រុកកោះធំមាន ១១ ឃុំ** | | ៩. ព្រែកក្មេង |
| ០២ | **ស្រុកកៀនស្វាយ មាន ៨ ឃុំ** | | ១. ឈើខ្មៅ | | ១០. ព្រែករៃ |
| | ១. បន្ទាយដែក | | ២. ជ្រោយតាកែវ | | ១១. ព្រែកឫស្សី |
| | ២. ឈើទាល | | ៣. កំពង់កុង | | ១២. សំបួរ |
| | ៣. ដីឥដ្ឋ | | ៤. កោះធំ « ក » | | ១៣. សារិកាកែវ |
| | ៤. កំពង់ស្វាយ | | ៥. កោះធំ « ខ » | | ១៤.ថ្មគរ |
| | ៥. គគីរ | | ៦. លើកដែក | | ១៥. ទឹកឃ្លាំង |
| | ៦. គគីរធំ | | ៧. ពោធិបាន | ០៧ | **ស្រុកមុខកំពូលមាន៧ ឃុំ** |
| | ៧. ភូមិធំ | | ៨. ព្រែកជ្រៃ | | ១. ព្រែកអញ្ចាញ |
| | ៨. សំរោងធំ | | ៩. ព្រែកស្ដី | | ២.ព្រែកដំបង |

| | | | | | |
|---|---|---|---|---|---|
| | ៣. រកាកោងទី ១ | | ៩. រកាខ្ពស់ | **០៧** | **ស្រុកថ្មបាំង មាន ៦ ឃុំ** |
| | ៤. រកាកោងទី ២ | | ១០.ស្អាងភ្នំ | | ១. តាទៃលើ ឬតាតៃ |
| | ៥. ឫស្សីជ្រោយ | | ១១. សិត្បូ | | ២. ប្រឡាយ |
| | ៦. សំបួរមាស | | ១២. ស្វាយប្រទាល | | ៣. ជំនាប់ |
| | ៧. ស្វាយអំពារ | | ១៣. ស្វាយរលំ | | ៤. ឫស្សីជ្រុំ |
| **០៨** | **ស្រុកអង្គស្នួល មាន ១០ឃុំ** | | ១៤. តាលន់ | | ៥. ជីផាត |
| | ១.បែកចាន | | ១៥. ត្រើយស្លា | | ៦. ថ្មដូនពៅ |
| | ២. ឆក់ឈើនាង | | ១៦. ទឹកវិល | **១០** | **ខេត្តក្រចេះ** |
| | ៣. ដំណាក់អំពិល | **១១** | **ក្រុងតាខ្មៅមាន ៦ សង្កាត់** | **០១** | **ស្រុកឆ្លូង មាន ៨ ឃុំ** |
| | ៤. ក្រាំងម្កាក់ | **០៩** | **ខេត្តកោះកុង** | | ១. ឆ្លូង |
| | ៥. លំហាច | **០១** | **ស្រុកបុទុមសាគរ មាន ៤ឃុំ** | | ២. ដំរីផុង |
| | ៦. ម្កាក់ | | ១. អណ្ដូងទឹក | | ៣. ហាន់ជ័យ |
| | ៧. ពើក | | ២. កណ្ដោល | | ៤. កំពង់ដំរី |
| | ៨. ព្រៃពួច | | ៣. តានូន | | ៥. កញ្ជរ |
| | ៩. សំរោងលើ | | ៤. ថ្មស | | ៦. ខ្សាច់អណ្ដែត |
| | ១០. ទួលព្រេជ | **០២** | **ស្រុកគីរីសាគរ មាន៣ ឃុំ** | | ៧. ពង្រ |
| **០៩** | **ស្រុកពញាឮ មាន ១១ឃុំ** | | ១.កោះស្ដេច | | ៨. ព្រែកសាម៉ាន់ |
| | ១.ឈ្វាំង | | ២. ភ្ញីមាស | **០២** | **ក្រុងក្រចេះមាន ៥សង្កាត់** |
| | ២. ជ្រៃលាស់ | | ៣. ព្រែកខ្សាច់ | **០៣** | **ស្រុកព្រែកប្រសព្វ មាន ៨ ឃុំ** |
| | ៣. កំពង់លួង | **០៣** | **ស្រុកកោះកុង មាន ៤ ឃុំ** | | ១. ចំបក់ |
| | ៤. កំពង់អុស | | ១. ជ្រោយប្រស់ | | ២. ជ្រោយបន្ទាយ |
| | ៥. កោះចិន | | ២. កោះកាពិ | | ៣. កំពង់គរ |
| | ៦. ភ្នំបាត | | ៣. តាតៃក្រោម | | ៤. កោះតាស៊ុយ |
| | ៧. ពញាឮ | | ៤. ត្រពាំងរូង | | ៥. ព្រែកប្រសព្វ |
| | ៨.ព្រែកតាទែន | **០៤** | **ក្រុងខេមរៈភូមិន្ទមាន ៣ សង្កាត់** | | ៦. ឫស្សីកែវ |
| | ៩. ផ្សារដែក | **០៥** | **ស្រុកមណ្ឌលសីមា មាន ៣ ឃុំ** | | ៧. សោប |
| | ១០. ទំនប់ធំ | | ១. ប៉ាក់ខ្លង | | ៨. តាម៉ៅ |
| | ១១. វិហារលួង | | ២. ពាមក្រសោប | **០៤** | **ស្រុកសំបូរមាន ១០ ឃុំ** |
| **១០** | **ស្រុកស្អាងមាន ១៦ ឃុំ** | | ៣. ទួលគគីរ | | ១. បឹងចារ |
| | ១. ខ្ពប | **០៦** | **ស្រុកស្រែអំបិល មាន ៦ឃុំ** | | ២. កំពង់ចាម |
| | ២. កោះអន្លង់ចិន | | ១. បឹងព្រាវ | | ៣. ក្បាលដំរី |
| | ៣. កោះខែល | | ២. ដី ឧក្រោម | | ៤. កោះខ្ញែរ |
| | ៤. កោះខ្សាច់ទន្លា | | ៣. ដី ឧ លើ | | ៥. អូរគ្រៀង |
| | ៥. ក្រាំងយ៉ូវ | | ៤. ជ្រោយស្វាយ | | ៦. រលួសមានជ័យ |
| | ៦. ប្រាសាទ | | ៥. ដងពែង | | ៧. សំបូរ |
| | ៧. ព្រែកអំបិល | | ៦. ស្រែអំបិល | | ៨. សណ្ដាន់ |
| | ៨. ព្រែកគយ | | | | ៩. ស្រែជិះ |

| | | | | | |
|---|---|---|---|---|---|
| | ១០. វង្គ្លនៈ | | ៧. សំបុក | | ៣. រយ៉ |
| **០៥** | **ស្រុកស្នួល មាន ៥ឃុំ** | | ៨. ថ្មអណ្ដើក | | ៤.សុខសាន្ត |
| | ១. យៀម | | ៩. ថ្មគ្រែ | | ៥. ស្រែហ៊ុយ |
| | ២. ពីរធ្នូ | | ១០. ថ្មី | | ៦. ស្រែសង្គម |
| | ៣. ស្នួល | **១១** | **ខេត្តមណ្ឌលគិរី** | **០៣** | **ស្រុកអូររាំងមាន ២ ឃុំ** |
| | ៤. ស្រែចារ | **០១** | **ស្រុកកែវសីមា មាន ៥ ឃុំ** | | ១. ដាក់ដាំ |
| | ៥. ស្វាយជ្រះ | | ១. ចុងផ្លាស់ | | ២. សែនមនោរម្យ |
| **០៦** | **ស្រុកចិត្របុរី មាន ១០ ឃុំ** | | ២. មេម៉ង់ | **០៤** | **ស្រុកពេជ្រាដាមាន ៤ឃុំ** |
| | ១. បុសលាវ | | ៣. ស្រែឈូក | | ១. ក្រង់តេះ |
| | ២. ចង្ក្រង់ | | ៤.ស្រែខ្ទម | | ២. ពូជ្រៃ |
| | ៣. ដារ | | ៥. ស្រែព្រះ | | ៣. ស្រែអំពូម |
| | ៤. កន្ទួត | **០២** | **ស្រុកកោះញែក មាន៦ ឃុំ** | | ៤. ប៊ូស្រា |
| | ៥. គោលាប់ | | ១. ណងឃីលិក | **០៥** | **ក្រុងសែនមនោរម្យមាន៤សង្កាត់** |
| | ៦. កោះច្រែង | | ២. អបួនលើ | | |

(នៅមានត)

លោកស្រី**គុយ ផល្លា**

*កូនសិស្សល្អ*

*ចៅកែវឧស្សាហ៍*
*នៅក្នុងថ្នាក់រៀន*

*ប្រឹងធ្វើកិច្ចការ*
*ស្ដាប់គ្រូពន្យល់*
*ពីកិច្ចដទៃ ។*

*ចាំចប់ឥតសល់*
*ឥតមានអំពល់*

*គួរចេះកោតខ្លាច*
*ចិត្តធ្ងន់ស្លូតត្រង់*

*លុះដោយអំណាច*
*នឹងក្មេងដទៃ*
*យកតម្រាប់តាម ។*

*នៃគ្រូពោលស្ដី*
*កូនសិស្សប្រុសស្រី*

*មេសូត្ររត់មាត់*

*ដកស្រង់ចេញពីទស្សនាវដ្ដីសម្រាប់គ្រូបង្រៀនលេខ*
*ឆ្នាំទី ៤ មិថុនា-កក្កដា ឆ្នាំសិក្សា ១៩៩២-១៩៩៣*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សមាគមបុគ្គលិកសិក្សាខ្មែរ**
**គណៈកម្មាធិការកណ្តាល**
**លេខ: ០១/១៤ គ.ក**

## សេចក្តីជូនដំណឹងមរណភាពប្រចាំខែ មករា ឆ្នាំ២០១៤

តាងនាមសមាគមបុគ្គលិកសិក្សាទាំងមូលគណៈកម្មធិការកណ្តាលនៃ ស.ប.ស.ខ.
សូមសំដែងសេចក្តីសោកស្តាយជាទីបំផុត ចំពោះការបាត់បង់ជីវិតនៃមិត្តយើង និងគ្រួសារ
ហើយសូមចូលរួមកាន់ទុក្ខមរណៈសញ្ញាជាមួយគ្រួសារនៃសពទាំងនោះ

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបំរើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | | **ក.មរណៈភាពសមាជិក** | | | | **សពទី** |
| ១ | ម៉ៅ ច័ន្ទណា | ៦០ | ស | គ្រូ. | និវត្តជន សាលាគរុកោសល្យនិងវិក្រឹតការ ខេត្តតាកែវ | ០៩.១១.១៣ | រោគគាពាធ | ១០៣២ ត.ក | ៩៣២៥ |
| ២ | រ៉ិត សុវណ្ណ | ៧០ | ប | គ្រូ. | និវត្តជន ស្រុកទ្រាំង ខេត្តតាកែវ | ០២.១១.១៣ | មហារីសួត | ០៦០០ ត.ក | ៩៣២៦ |
| ៣ | គិត ធុំ | ៤៣ | ប | បឋម | បឋម អណ្តូងសំរិត ស្រុកកោះអណ្តែត ខេត្តតាកែវ | ២៤.១០.១៣ | គ្រោះថ្នាក់ចរាចរ | ២១៩៦ ត.ក | ៩៣២៧ |
| ៤ | វ៉ា អៀន | ៦៨ | ប | បឋម | បឋម គោកបន្ទាយ ស្រុករលាបៀរ ខេត្តកំពង់ឆ្នាំង | ០១.១១.១៣ | ជំងឺថ្លើម | ០២៤០៣ ក.ឆ | ៩៣២៨ |
| ៥ | ជូ ហុង | ៧២ | ប | បឋម | អនុ. កំពង់ត្រឡាច ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង | ១០.១១.១៣ | រោគគាពាធ | ០៧៧៦ ក.ឆ | ៩៣២៩ |
| ៦ | ហ៊ីង សុផល | ៧៤ | ប | បឋម | ការិយាល័យអយកស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង | ២៨.០៩.១៣ | រោគាពាធ | ០៧៥៩ ក.ឆ | ៩៣៣០ |
| ៧ | ហង់ ហូ | ៥៧ | ប | បឋម | បឋម ព្រះឥន្ទ្រទេព ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង | ០២.១០.១៣ | គ្រោះថ្នាក់ចរាចរ | ០២១៥៦ ក.ឆ | ៩៣៣១ |
| ៨ | បឿ ធុន | ៦១ | ប | បឋម | បឋម ល្បើករង្សី ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង | ១៤.០៨.១៣ | ចុកពោះ | ០២១៩២ ក.ឆ | ៩៣៣២ |
| ៩ | កើ យោប | ៦៦ | ប | បឋម | បឋមស្វាយបាការ ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង | ១៩.០៩.១៣ | រោគាពាធ | ០១១១៧ ក.ឆ | ៩៣៣៣ |
| ១០ | ម៉ប់ ស៊ុនលី | ៤៤ | ប | បឋម | បឋម អណ្តូងរៀង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង | ១២.០៩.១៣ | គ្រុនឈាម | ០២១៤៩ ក.ឆ | ៩៣៣៤ |
| ១១ | ហោ អៀង | ៤៨ | ប | បឋម | បឋម ត្រាង ស្រុកបាកាន ខេត្តពោធិ៍សាត់ | ២៩.១០.១៣ | គាំងបេះដូង | ២០០៧ ព.ស | ៩៣៣៥ |
| ១២ | អ៊ុក សុខជី | ៣៨ | ប | មធ្យម | វិទ្យាល័យ កណ្តៀង ខេត្តពោធិ៍សាត់ | ២៥.១០.១៣ | មហារីក ក | ២៧២៩ ព.ស | ៩៣៣៦ |
| ១៣ | គល់ ខឿន | ៤៤ | ប | បឋម | បឋម ទួលតាធន់ ស្រុករមាសហែក ខេត្តស្វាយរៀង | ២៤.១១.១៣ | តម្រងនោម | ១០២៧ ស្វ.រ | ៩៣៣៧ |
| ១៤ | ខៀវ ផេង | ៧២ | ប | បឋម | និវត្តជន ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង | ២៦.១១.១៣ | លើសឈាម | ១៦៨៨ ស្វ.រ | ៩៣៣៨ |
| ១៥ | ប្រាំង សុវ៉ាន់ | ៦៩ | ប | បឋម | និវត្តជន ស្រុស្វាជ្រុំ ខេត្តស្វាយរៀង | ០២.១២.១៣ | រលាកសួត | ៦០៦ ស្វ.រ | ៩៣៣៩ |
| ១៦ | មែក ប៊ុន | ៧៩ | ប | គ្រូ. | និវត្តជន ស្រុករំដួល ខេត្តស្វាយរៀង | ២២.១២.១៣ | រោគាពាធ | ៣៦៥៤ ស្វ.រ | ៩៣៤០ |
| ១៧ | មូ ចន្ថា | ៦១ | ប | បឋម | និវត្តជន ក្រុងបាវិត ខេត្តស្វាយរៀង | ២៩.១១.១៣ | លើសឈាម | ៨៨១ ស្វ.រ | ៩៣៤១ |
| ១៨ | ចាន់ សាង | ៦១ | ប | បឋម | និវត្តជន បឋម ជ្រៃថ្មី ស្រុកពាមជរ ខេត្តព្រៃវែង | ៣០.០៩.១៣ | មហារីកក្រពះ | ៣៤៤៤ ព.វ | ៩៣៤២ |
| ១៩ | តូច សាវ៉ាន់ | ៦៤ | ប | មូលដ្ឋាន | និវត្តជន វិ. ស្រុកកំចាយមារ ខេត្តព្រៃវែង | ២៥.១០.១៣ | រោគាពាធ | ២៨០៨ ព.វ | ៩៣៤៣ |
| ២០ | ឈុន គាន | ៥៩ | ប | បឋម | បឋម ឬស្សីជុំកត្បូង ស្រុកពារាំង ខេត្តព្រៃវែង | ០២.១១.១៣ | លើសឈាម | ៦០២៩ ព.វ | ៩៣៤៤ |
| ២១ | សួន សុភាព | ៣៧ | ប | បឋម | បឋម មេសាង ស្រុកមេសាង ខេត្តព្រៃវែង | ១៧.១១.១៣ | គាំងបេះដូង | ៧៩៥៧ ព.វ | ៩៣៤៥ |
| ២២ | សួន យា | ៧១ | ប | បឋម | និវត្តជន បឋម អង្គក្អោត ស្រុកមេសាង ខេត្តព្រៃវែង | ២៨.០៩.១៣ | រោគាពាធ | ៥៧០៥ ព.វ | ៩៣៤៦ |
| ២៣ | ហុង យ៉ាន | ៧៦ | ប | បឋម | និវត្តជន បឋម រក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង | ២៤.០៩.១៣ | របេង | ៤៤៨៥ ព.វ | ៩៣៤៧ |
| ២៤ | មាស សីយ៉ានី | ៦១ | ប | បឋម | និវត្តជន បឋម ខ្ញុំ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង | ២៩.១០.១៣ | ខ្យល់គរ | ១៦៩០ ព.វ | ៩៣៤៨ |
| ២៥ | កុយ វិរៈ | ៥៨ | ប | មូលដ្ឋាន | វិទ្យាល័យ ពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង | ១១.១០.១៣ | រោគាពាធ | ៤៨២៨ ព.វ | ៩៣៤៩ |
| ២៦ | អុន សុខា | ៥០ | ប | បឋម | បឋម ទ្រង់ខ្លា ស្រុកបាភ្នំ ខេត្តព្រៃវែង | ០៧.១១.១៣ | គាំងបេះដូង | ៤៧១៦ ព.វ | ៩៣៥០ |
| ២៧ | សំ គឹមសាន | ៦៥ | ប | បឋម | និវត្តជន បឋម ភ្លើងរាយ ស្រុកកញ្ជៀច ខេត្តព្រៃវែង | ១១.១១.១៣ | រោគាពាធ | ១៦៤៤ ព.វ | ៩៣៥១ |
| ២៨ | ញឹក ផាត់ | ៧៤ | | មូលដ្ឋាន | និវត្តជន អនុ. ហៅក់កញ្ចុំ ស្រុកពារាំង ខេត្តព្រៃវែង | ១៧.១១.១៣ | រោគាពាធ | ៥៩៩០ ព.វ | ៩៣៥២ |
| ២៩ | ឆោម ជា | ៥៧ | ប | បឋម | បឋម បូកគងថ្មី ស្រុកស្វាយអន្ទរ ខេត្តព្រៃវែង | ១៣.១១.១៣ | រោគាពាធ | ៣៩១២ ព.វ | ៩៣៥៣ |
| ៣០ | ស៊ូ ស្រេង | ៧៣ | ប | បឋម | និវត្តជនបឋមព្រែកសណ្តែកស្រ.ស៊ីធរកណ្តាលខ.ព្រៃវែង | ២៣.១១.១៣ | រោគាពាធ | ២៩៣៥ ព.វ | ៩៣៥៤ |
| ៣១ | ឯក ស៊ីថូ | ៧១ | ប | ម.ប.ភ | និវត្តជន វិទ្យាល័យ ព្រះស៊ីសុវត្ថិ រាជធានីភ្នំពេញ | ០៧.០៥.១៣ | រោគាពាធ | ២១៥០ ភ.ព | ៩៣៥៥ |
| ៣២ | ឆាយ សុខ | ៧០ | ប | ម.ប.ភ | និវត្តជន វិទ្យាល័យ ទួលទំពូង រាជធានីភ្នំពេញ | ២៦.១០.១៣ | ទឹកនោមផ្អែម | ៤៩៦៨ ភ.ព | ៩៣៥៦ |
| ៣៣ | គឹម សោមម៉ាលី | ៦០ | ស | ម.ប.ភ | និវត្តជន វិទ្យាល័យឫស្សីកែវ រាជធានីភ្នំពេញ | ១០.១០.១៣ | ក្រិនថ្លើម | ២១៥៦ ភ.ព | ៩៣៥៧ |
| ៣៤ | ហ៊ី ចន្ថា | ៤៥ | ស | ម.ទ.ភ | និវត្តជន វិ. ជា ស៊ីម សន្ធរម៉ុក រាជធានីភ្នំពេញ | ៣០.១០.១៣ | ក្រិនថ្លើម | ៨០៧៣ ភ.ព | ៩៣៥៨ |
| ៣៥ | ឃឹម ចាន់ថន | ៦៥ | ស | បឋម | និវត្តជន ទួលទំពូង រាជធានីភ្នំពេញ | ១៨.០៣.១៣ | លើសឈាម | ៤៤៦៦ ភ.ព | ៩៣៥៩ |
| ៣៦ | ពិន សុនី | ៧៧ | ស | ម.ទ.ភ | និវត្តជន វិ.ព្រែកឯង ខណ្ឌមានជ័យ រាជធានីភ្នំពេញ | ២៤.១១.១៣ | រោគាពាធ | ១១៧៤៩ ភ.ព | ៩៣៦០ |
| ៣៧ | អ៊ុន ប្រកប | ៣៣ | ប | ម.ទ.ភ | វិទ្យាល័យ ជា ស៊ីម សន្ធរម៉ុក រាជធានីភ្នំពេញ | ២៨.១១.១៣ | រោគាពាធ | ១០២១៣ ភ.ព | ៩៣៦១ |
| ៣៨ | ផល ចំរើន | ៤៣ | ប | បឋម | បឋម មិត្តភាពកម្ពុជាចិនឃ្មួញ រាជធានីភ្នំពេញ | ០៣.១២.១៣ | រោគាពាធ | ៦៥៤១ ភ.ព | ៩៣៦២ |
| ៣៩ | ស ជាមង្គល | ៤៣ | ប | ម.ទ.ភ | វិទ្យាល័យ ឥន្ទ្រទេវី រាជធានីភ្នំពេញ | ០៩.១២.១៣ | គាំងបេះដូង | ២៤២២ ភ.ព | ៩៣៦៣ |
| ៤០ | អ៊ឹង ស៊ីមន | ៧០ | ប | បឋម | និវត្តជន ឃុំដារ ស្រុកចិត្របុរី ខេត្តក្រចេះ | ១៣.១១.១៣ | រោគាពាធ | ០៩៨៤ ក្រ.ច | ៩៣៦៤ |
| ៤១ | មិន ចំរើន | ៦៨ | ប | បឋម | និវត្តជន ឃុំគោលាប់ ស្រុកចិត្របុរី ខេត្តក្រចេះ | ១៧.១១.១៣ | រោគាពាធ | ០៩៨១ ក្រ.ច | ៩៣៦៥ |
| ៤២ | តាក់ រ៉េត | ៥៥ | ប | បឋម | បឋម គោកធ្លក ស្រុកជីក្រែង ខេត្តសៀមរាប | ០៤.១១.១៣ | របេងសួត | ២៣៧៩ ស.រ | ៩៣៦៦ |
| ៤៣ | អ៊ិត ហាន់ | ៨៥ | ប | គ្រូ. | និវត្តជន អនុប្រធាន មអយក ខេត្តកំពត | ១៧.១០.១៣ | រោគាពាធ | ៤០.៣៨ ក.ព | ៩៣៦៧ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៤៤ | ខែម ផា | ៦៨ | ប | គ្រូបឋម | និវត្តជន បឋមខ្វាវ ស្រុកអង្គរជ័យ ខេត្តកំពត | ១៨.០៩.១៣ | រោគាពាធ | ១៦៣៤ ក.ព | ៩៣៦៨ |
| ៤៥ | ឡេង ទីវ | ៦៣ | ប | ម.ទ.ភ | និវត្តជន វិ. ទូកមាស ស្រុកបន្ទាយមាស ខេត្តកំពត | ២៩.១០.១៣ | រោគាពាធ | ២៩៤៧ ក.ព | ៩៣៦៩ |
| ៤៦ | លឿង បូរិន | ៦៦ | ប | គ្រូបឋម | និវត្តជន បឋមព្រះពន្លាស្រ.សិរីសោភ័ណខ.ប.មានជ័យ | ១១.១២.១៣ | លើសឈាម | ២១៤៧ ក.ព | ៩៣៧០ |
| ៤៧ | ផន ផេង | ៥៨ | ប | គ្រូ. | នា. យុវជន ការគ្រប់គ្រងគ/ការកណ្តាល ស.ប.ស.ខ. | ០៨.១១.១៣ | រោគាពាធ | ២១៤៦ គ.ក | ៩៣៧១ |
| ៤៨ | ចាន់ផា | ៧៤ | ប | គ្រូ. | និវត្តជនស.វិ.ភូមិន្ទភ្នំពេញ គ/ការកណ្តាល ស.ប.សខ. | ០១.១២.១៣ | រោគាពាធ | ២៦៥២ គ.ក | ៩៣៧២ |
| ៤៩ | ង៉ែត សាម៉ុន | ៥៧ | ប | គ្រូ. | នា. យុវជន គណៈកម្មាធិការកណ្តាល ស.ប.ស.ខ. | ២២.១០.១៣ | រោគាពាធ | ៣៤៤៩ គ.ក | ៩៣៧៣ |
| ៥០ | ទេព មៀច | ៨០ | ប | គ្រូបឋម | និវត្តជន បឋមទួលស្វាព្រៃ គ/ការកណ្តាល ស.ប.ស.ខ. | ០៩.១២.១៣ | រោគាពាធ | ១០៩២ គ.ក | ៩៣៧៤ |
| ៥១ | ម៉ី សុវុឌ្ឍី | ៤៧ | ប | គ្រូ. | សាកល វិទ្យាល័យភូមិន្ទភ្នំពេញ គ/ការកណ្តាលស.ប.ស.ខ. | ១០.១២.១៣ | រោគាពាធ | ១៥០៨ គ.ក | ៩៣៧៥ |
| ៥២ | យង់ ជិន | ៧១ | ប | បឋម | និវត្តនជន ស្រុកល្វាឯម ខេត្តកណ្តាល | ២៣.១១.១៣ | លើសឈាម | ២៧៦៤ ក.ណ | ៩៣៧៦ |
| ៥៣ | ជួន រិនធឿន | ៤៤ | ប | បឋម | បឋម ដំណាក់ព្រីង ស្រុកពញាឮ ខេត្តកណ្តាល | ១៨.១១.១៣ | រោគាពាធ | ១៧៨៧ ក.ណ | ៩៣៧៧ |
| ៥៤ | សុខ សែន | ៥៣ | ប | ម.ប.ភ | អនុវិទ្យាល័យ គគីរធំ ស្រុកគៀនស្វាយ ខេត្តកណ្តាល | ២៦.១១.១៣ | រោគាពាធ | ៦៨៣៥ ក.ណ | ៩៣៧៨ |
| ៥៥ | ហាក់ ប៊ុណ្ណារិទ្ធ | ៥១ | ប | ម.ប.ភ | អនុវិទ្យាល័យកំពង់ចម្លង ស្រុកលើកដែក ខេត្តកណ្តាល | ២៥.១១.១៣ | ដាច់សរសៃឈាម | ១៩២៧ ក.ណ | ៩៣៧៩ |
| ៥៦ | ឥន្ទ សុរិន | ៦៣ | ប | គ្រូបឋម | និវត្តជន បឋម ឈើខ្មៅ ស្រុកកោះធំ ខេត្តកណ្តាល | ២១.១២.១៣ | រោគាពាធ | ៧១៥ ក.ណ | ៩៣៨០ |
| ៥៧ | ស៊ាន សុផល | ៧៣ | ប | គ្រូបឋម | និវត្តជន បឋមខ្ពប ស្រុកស្អាង ខេត្តកណ្តាល | ០៥.១២.១៣ | រោគាពាធ | ៦២០០ ក.ណ | ៩៣៨១ |
| ៥៨ | សុខ ចន្ថា | ៦៨ | ប | គ្រូ បឋម | និវត្តជន បឋមស្រែប្រាំង-តំបែរ - កំពង់ចាម | ១៨.១១.១៣ | រោគាពាធ | ៦២១២ កច. | ៩៣៨២ |
| ៥៩ | ឱន គឹម ស្រ៊ី | ៥៩ | ប | គ្រូ បឋម | បឋម ពើក - អូរាំងឪ - កំពង់ចាម | ០៦.១១.១៣ | រលោកសន្លាក់ឆ្អឹង | ១០៤០ កច. | ៩៣៨៣ |
| ៦០ | ហ៊ូ សុង | ៦៤ | ប | គ្រូ បឋម | និវត្តជន បឋមពាមជាំង - អូរាំងឪ - កំពង់ចាម | ១៨.១១.១៣ | លើសឈាម | ១០០២១ កច. | ៩៣៨៤ |
| ៦១ | ឃិន លួន | ៨១ | ប | គ្រូ បឋម | និវត្តជន បឋម ចក - អូរាំងឪ - កំពង់ចាម | ៣០.១១.១៣ | រោគាពាធ | ១៧៦៦ កច. | ៩៣៨៥ |
| ៦២ | ស៊ូ សុភាព | ៥៩ | ប | គ្រូ បឋម | បឋម គោករវៀង - ជើងព្រៃ - កំពង់ចាម | ១៨.១២.១៣ | រោគាពាធ | ២១០៩ កច. | ៩៣៨៦ |
| ៦៣ | អ៊ឹង វុត្ថា | ៧៥ | ប | គ្រូ បឋម | និវត្តជន បឋម ទួលវិហារ - ត្បូងឃ្មុំ - កំពង់ចាម | ២៣.១២.១៣ | គ្រោះថ្នាក់ចរាចរ | ៩៤៦០ កច. | ៩៣៨៧ |
| ៦៤ | ឆាយ ហួត | ៤៥ | ប | គ្រូ បឋម | បឋម ប៉ើស២ - ក្រូចឆ្មារ - កំពង់ចាម | ២៤.១២.១៣ | លើសឈាម | ៦៥២១ កច. | ៩៣៨៨ |
| ៦៥ | យស គុយ | ៧៣ | ប | គ្រូ បឋម | និវត្តជនសាលាគុរុកោសល្យខេត្តបន្ទាយមានជ័យ | ១៨.១២.១៣ | រោគាពាធ | ២២២៦ បជ | ៩៣៨៩ |
| ៦៦ | ឈឿង ធិន | ៦៥ | ប | គ្រូ បឋម | និវត្តជន បឋមព្រីងកោងក្រ.សិរីសោភ័ណខ.ប.មានជ័យ | ២០.១២.១៣ | រោគាពាធ | ០៣០០ បជ | ៩៣៩០ |
| ៦៧ | អៀង ពិចិត្រ | ៤១ | ប | ម.ទ.ភ | វិទ្យាល័យ ភ្នំធំ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ | ២៣.១២.១៣ | រោគាពាធ | ៣៥៤៧ បជ | ៩៣៩១ |

| ល.រ | គោត្តនាម-នាម | អាយុ | ភេទ | ក្របខ័ណ្ឌ | អង្គភាពបំរើការ | ថ្ងៃខែឆ្នាំមរណៈ | មូលហេតុ | លេខប័ណ្ណ | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | | **ខ.មរណៈភាពគ្រួសារ** | | | | **សពទី** |
| ១ | ភី វណ្ណា | ៥៥ | ស | កសិករ | ប្រពន្ធលោកគ្រូ រស់ សាមាន បឋមអង្គស្វាយស្រ.ស្វាយទាប ខេត្តស្វាយរៀង | ២១.១១.១៣ | រលោកក្រពះ | ១៩៧៤ ស្វ.រ | ៥៥១១ |
| ២ | ហ៊ុយ នឹម | ៦៤ | ស | កសិករ | និវត្ត បឋម ជ្រួលថ្មី ស្រុកបាភ្នំ ខេត្តព្រៃវែង | ២៣.១០.១៣ | រោគាពាធ | ៤៤៩១ ព.វ | ៥៥១២ |
| ៣ | ជុំ មនីរតន៍ | ៤៥ | ប | កសិករ | ប្រពន្ធលោក ហ៊ិន ពៅ អនុ. កំពង់ត្របែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង | ២០.១០.១៣ | រោគាពាធ | ១៣៤១ ព.វ | ៥៥១៣ |
| ៤ | ឡុង សាម៉េត | ៦១ | ស | កសិករ | ប្តីអ្នកស្រី ទូច សារ៉ែន បឋមជ្រៃឧត្តម ស្រុកបាភ្នំ ខេត្តព្រៃវែង | ២៨.១០.១៣ | គាំងបេះដូង | ៤៥៦៩ ព.វ | ៥៥១៤ |
| ៥ | ឡេង សាអ៊ាន | ៥៣ | ស | កសិករ | ប្រពន្ធលោក សុខ វន្ថា បឋម សិម្ពលី ស្រុកបាភ្នំ ខេត្តព្រៃវែង | ០៤.១០.១៣ | រោគាពាធ | ៤៧២៤ ព.វ | ៥៥១៥ |
| ៦ | នាង ដៀន | ៥៩ | ប | កសិករ | ប្តីអ្នកគ្រូ គង់ ចាន់ណុន មត្តេយ្យព្រាល ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង | ២៤.១០.១៣ | រោគបេះដូង | ០១៦៩៣ ក.ឆ | ៥៥១៦ |
| ៧ | អៅ គឹម | ៥៥ | ប | កសិករ | ប្តីអ្នកគ្រូ ស៊ិន សារួង បឋម ព្រះទ្វារ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង | ០១.១១.១៣ | ជំងឺសួត | ០១៨០៩ ក.ឆ | ៥៥១៧ |
| ៨ | វ៉ា អៀន | ៦៨ | ប | គ្រូ. | ប្តីអ្នកគ្រូ ហួន វ៉ាន់នី វិទ្យាល័យ ប រ ហស ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង | ០១.១១.១៣ | ជំងឺថ្លើម | ០២៤០៣ ក. | ៥៥១៨ |
| ៩ | អឿង ដាលីន | ៣០ | ស | កសិករ | ប្រពន្ធលោក សាត សាវុធ វិ. សម្តេចបរមនាថនរោត្តមសីហមុនី ខេត្តកំពង់ឆ្នាំ | ១១.១១.១៣ | រោគាពាធ | ០៣៤៧៦ ក.ឆ | ៥៥១៩ |
| ១០ | ស៊ីវ សណាង | ៣៣ | ស | កសិករ | ប្រពន្ធលោក ស៊ីវ សំណាង បឋម មេលំ ស្រុបរិបូរណ៍ ខេត្តកំពង់ឆ្នាំង | ០៩.១០.១៣ | ធ្លាក់ឈាម | ០២៩៤០ ក.ឆ | ៥៥២០ |
| ១១ | ផាន់ សារឿន | ៤៨ | ស | កសិករ | ប្រពន្ធលោកគ្រូ ឡាក់ ទូច បឋមកោះខ្សាច់ ស្រុកបាកាន ខេត្តពោធិ៍សាត់ | ១១.១០.១៣ | ទឹកនោមផ្អែម | ២០៤៣ ក.ធ | ៥៥២១ |
| ១២ | សុខ ខេន | ៤០ | ស | កសិករ | ភរិយាលោក គិត ធុំ បឋម អណ្តូងសំរិត ស្រុកកោះអណ្តែតខេត្តតាកែវ | ០១.០៩.១៣ | រោគាពាធ | ២១៩៦ ត.ក | ៥៥២២ |
| ១៣ | ប៊ុត សុខន | ៥៣ | ស | កសិករ | ភរិយាលោក ប៉ែន រ៉ី បឋម ភ្នំតូច ស្រុកបាទី ខេត្តតាកែវ | ១១.១១.១៣ | គ្រោះថ្នាក់ចរាច | ១៧៨៩ ត.ក | ៥៥២៣ |
| ១៤ | អ៊ឹង ឌី | ៤៥ | ប | កសិករ | ប្តីអ្នកស្រី មុំ សុភី បឋម អង្គមេត្រី ក្រុងដូនកែវ ខេត្តតាកែវ | ១៧.១១.១៣ | ចង ក | ៥៩៣៤ ត.ក | ៥៥២៤ |
| ១៥ | អ៊ូ ចាន់ | ៥០ | ស | កសិករ | ភរិយាលោក ប៊ូ គឹមហុង បឋមត្នោត ស្រុកបាទី ខេត្តតាកែវ | ០១.១១.១៣ | រោគាពាធ | ១៩៩៤ ត.ក | ៥៥២៥ |
